សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

## អានុភាពនៃកិច្ចសន្យាលក់ទំនិញអន្តរជាតិ យោងតាមអនុសញ្ញាអង្គការសហប្រជាជាតិCISG

ស្រាវជ្រាវចាប់ពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៨ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **សោម ហ៊ុនកញ្ញា**

**ឡុង ម៉ារ៉ាឌី**

សាស្ត្រាចារ្យណែនាំ

**លោក ឌិន ចន្ទ្ធារ៉ា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី១៨

ឆ្នាំចូលសិក្សា ២០១៤

ឆ្នាំសរសេរសារណា ២០១៨

# លិខិតថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **សោម ហ៊ុនកញ្ញា** និង **ឡុង ម៉ារ៉ាឌី** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ជំនាន់ទី១៨ ក្រុម$L_4B_3$ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា ២០១៧-២០១៨។

## សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ

- លោកឪពុក អ្នកម្តាយ និងលោកតា លោកយាយ ដែលចិញ្ចឹមបីបាច់ថែរក្សា អប់រំប្រៀនប្រដៅ និងផ្តត់ផ្គង់គ្រប់យ៉ាងទាំងស្មារតី ទាំងសម្ភារៈ និងឧបត្ថម្ភជាថវិការតាំងពីតូចរហូតមកដល់រូបខ្ញុំបានទទួលចំណេះដឹងដ៏ខ្ពង់ខ្ពស់ និងបានទទួលលទ្ធផលជាផ្លែផ្កាដូចសព្វថ្ងៃ។
- **ឯកឧត្តម សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស សាស្ត្រាចារ្យ និង បុគ្គលិក** ទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានដឹកនាំពង្រឹងវិន័យ និងបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត ក្នុងការបង្ហាត់បង្រៀនដល់ខ្ញុំបាទទាំងពីរនាក់។
- លោកសាស្ត្រាចារ្យ **ខិន វណ្ណារ៉ា** ជាសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានបង្ហាត់បង្រៀន និងបានចំណាយពេលវេលាដ៏មានតម្លៃរបស់លោកក្នុងការពន្យល់ណែនាំ ផ្តល់ចំណេះដឹង និងបទពិសោធន៍ល្អៗក្នុងការធ្វើសារណានេះ។ យើងខ្ញុំទាំងពីររូបសូមថ្លែងអំណរគុណជាពិសេស ចំពោះការខិតខំប្រឹងប្រែងរបស់លោកសាស្ត្រាចារ្យ។
- លោកសាស្ត្រាចារ្យ **យ៉ុង និល** ដែលបានចំណាយពេលវេលាក្នុងការផ្តល់ព័ត៌មាន និងការប្រឹក្សា ព្រមទាំងបង្ហាញ និង ជួយត្រួតពិនិត្យ និងរៀបចំសារណាឲ្យមានលក្ខណៈត្រឹមត្រូវតាមក្បួនខ្នាតផងដែរ។

ជាទីបញ្ចប់ ខ្ញុំបានសូមប្រសិទ្ធិពរជ័យសិរីមង្គលដល់ លោក អ្នកដែលមានគុណទាំងអស់ខាងលើឲ្យទទួលបាននូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ ព្រមទាំងសម្រេចបាននូវគោលបំណង និងទទួលបាននូវសេចក្តី ចម្រើន និងជោគជ័យគ្រប់បែបយ៉ាង ក្នុងការបំពេញការងារកុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្នុងការសិក្សាស្រាវជ្រាវថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ តាមការស្វែងយល់សារណានានាដែលទាក់ទងនឹងវិធានគតិយុត្តពាណិជ្ជកម្ម និង កិច្ចសន្យាផ្សេងៗរួចមក យើងខ្ញុំបានឃើញថាបណ្តាសារណាដែលតម្កល់ទុកនៅសាកលវិទ្យាល័យពុំសូវមានសារណាដែលសរសេរពីប្រធានបទទាក់ទងទៅនឹងជំនួញអន្តរជាតិ ជាពិសេសទាក់ទងទៅនឹងកិច្ចសន្យាអន្តរជាតិក៏ពុំសូវមាន។ ដូចនេះទើបយើងខ្ញុំជ្រើសរើសយកប្រធានបទដែរទាក់ទងនឹងកិច្ចសន្យាលក់ទំនិញអន្តរជាតិសម្រាប់ការស្រាវជ្រាវដល់និស្សិតជំនាន់ក្រោយ។

ម្យ៉ាងទៀតមូលហេតុដែលជំរុញឲ្យយើងខ្ញុំបានជ្រើសរើសយកប្រធានបទស្តីពី “ **អានុភាពនៃកិច្ចសន្យាលក់ទំនិញអន្តរជាតិ យោងតាមអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការលក់ទំនិញអន្តរជាតិ** ” គឺដើម្បីទុកឯកសារនេះជាជំនួយផ្នែកស្មារតីសម្រាប់និស្សិតទាំងឡាយដែលមានបំណងសិក្សាស្រាវជ្រាវ និងចង់ដឹងអំពីអានុភាពនៃកិច្ចសន្យាលក់ទំនិញអន្តរជាតិ។ ប្រធានបទនេះផ្តល់ជាមូលដ្ឋាននៃចំណេះដឹងមួយផ្នែក ក្នុងគោលបំណងដ៏សំខាន់សម្រាប់អ្នកវិនិយោគទុនបរទេសមានទំនុកចិត្តក្នុងការជ្រើសរើសប្រទេសកម្ពុជាជាដៃគូវិនិយោគទុន និងមកវិនិយោគនៅប្រទេសកម្ពុជាប្រកបដោយការទុកចិត្ត មានជំនឿជឿជាក់ថាការវិនិយោគនឹងទទួលបានជោគជ័យខ្ពស់។

ដូច្នេះហើយយើងខ្ញុំសង្ឃឹមយ៉ាងម៉ត់មាំថា ការស្រាវជ្រាវអំពីអានុភាពនៃកិច្ចសន្យាលក់ទំនិញអន្តរជាតិនេះ គឺដើម្បីរួមចំណែកផ្តល់ជាចំណេះដឹងពីការលក់ទំនិញអន្តរជាតិ និងកាតព្វកិច្ចរបស់គូរភាគី ក៏ដូចជាជួយពង្រឹងនូវច្បាប់ពាណិជ្ជកម្មរបស់កម្ពុជា ជាពិសេសសារៈសំខាន់នៃវិស័យពាណិជ្ជកម្មដែលជាសរសៃឈាមជួយឲ្យប្រទេសកម្ពុជាជាប្រទេសកំពុងអភិវឌ្ឍន៍មានការរីកចម្រើនបន្ថែមទៀត។ ទាក់ទងនឹងការសិក្សាស្រាវជ្រាវយើងខ្ញុំ ពិតជានូវមានចំណុចខ្វះខាតដែលមិនបានវិភាគលម្អិតសព្វជ្រុងជ្រោយនោះទេ ដោយហេតុថារយៈពេលនៃការស្រាវជ្រាវ ការស្នើសុំពត៌មានពីក្រុមហ៊ុនឯកជននានា និងការចងក្រងមានការពិបាក និងរយៈពេលខ្លី ហើយការយល់ដឹងភាសាបរទេស(អង់គ្លេស) ក្នុងការបកប្រែឯកសារដែលជាភាសាអង់គ្លេស របស់យើងខ្ញុំនៅមានកម្រិតនៅឡើយ។ ម្យ៉ាងទៀតយើងខ្ញុំទាំងពីរនាក់ក៏សូមអះអាងថាសារណាដែលបានសរសេរនេះពុំមានចំលងពីស្នាដៃរបស់បុគ្គលណាម្នាក់ឡើយ។

# មាតិកា

**សេចក្តីផ្តើម** ..... ១

**ជំពូកទី១ កាតព្វកិច្ចចំពោះគូភាគី**

**ផ្នែកទី១ កាតព្វកិច្ចចំពោះអ្នកលក់** ..... ៣

**កថាខណ្ឌទី១ ការប្រគល់ទំនិញ និងការប្រគល់សំណុំឯកសារ** ..... ៣

ក. ការប្រគល់ទំនិញ ..... ៤

១. ទីកន្លែងប្រគល់ទំនិញ ..... ៤

២. ពេលវេលាប្រគល់ទំនិញ ..... ៥

ខ. ការប្រគល់សំណុំឯកសារ ..... ៦

១. ឯកសារដែលត្រូវប្រគល់ និងការផ្ទេរកម្មសិទ្ធិនៃទំនិញ ..... ៦

១.១ ឯកសារដែលត្រូវប្រគល់ ..... ៧

១.២ ការផ្ទេរកម្មសិទ្ធិនៃទំនិញ ..... ៧

២. ពេលវេលានៃការប្រគល់សំណុំឯកសារ ..... ៨

**កថាខណ្ឌទី២ អនុលោមភាពនៃទំនិញ** ..... ៨

ក. ការធានានូវកម្មវត្ថុមុនទៅដល់អ្នកទិញ ..... ៩

ខ. ការផ្តល់ព័ត៌មានទាក់ទងទៅនឹងទំនិញទៅដល់អ្នកទិញ ..... ១០

គ. ការធានាពីការរំខាន ..... ១១

**ផ្នែកទី២ កាតព្វកិច្ចចំពោះអ្នកទិញ** ..... ១៣

**កថាខណ្ឌទី១ កាតព្វកិច្ចបង់ប្រាក់** ..... ១៣

ក. ទីកន្លែងនៃកាតព្វកិច្ចបង់ប្រាក់ ..... ១៣

ខ. ពេលវេលានៃកាតព្វកិច្ចបង់ប្រាក់ ..... ១៥

**កថាខណ្ឌទី២ ការទទួលយកការបញ្ជូនទំនិញ** ..... ១៦

ក. ត្រួតពិនិត្យទំនិញ ..... ១៦

ខ. ការជូនដំណឹងពីវិការៈ និងការបដិសេធការទទួលយកទំនិញ ..... ១៧

១. ការជូនដំណឹងពីវិការៈ ..... ១៧

២. ការបដិសេធការទទួលយកទំនិញ ..... ១៨

**ផ្នែកទី៣ ការទទួលខុសត្រូវចំពោះហានិភ័យ** ..... ១៩

**កថាខណ្ឌទី១ ការទទួលខុសត្រូវចំពោះហានិភ័យពីអំពើរបស់គូរភាគី និង អំពើរបស់តតិយជន** ........ ១៩
ក. ករណីមានអំពើរបស់គូរភាគី ........ ២០
ខ. ករណីមានអំពើរបស់តតិយជន ........ ២២

**កថាខណ្ឌទី២ ករណីប្រធានសក្តិ** ........ ២៣

## ជំពូកទី២ ការទទួលខុសត្រូវរបស់គូរភាគី

**ផ្នែកទី១ ការទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ចរបស់ភាគី** ........ ២៤
**កថាខណ្ឌទី១ ការទទួលខុសត្រូវដោយឡែកចំពោះការមិនអនុវត្តកាតព្វកិច្ចដោយអ្នកលក់** ........ ២៤
ក. ការប្រគល់នូវទំនិញជំនួស ........ ២៤
ខ.ការរំលាយកិច្ចសន្យាដោយអ្នកទិញ ........ ២៥
១. ការរំលោភបំពានជាមូលដ្ឋាននៃកិច្ចសន្យា ........ ២៦
២. ការកំណត់រយៈពេលបន្ថែមដោយអ្នកទិញ ........ ២៧
គ. ការកាត់បន្ថយតម្លៃ ........ ២៨
**កថាខណ្ឌទី២ ការទទួលខុសត្រូវដោយឡែកចំពោះការមិនអនុវត្តកាតព្វកិច្ចដោយអ្នកទិញ** ........ ២៩
ក. ការទទួលយកទំនិញដែលខ្លួនបានទិញ ........ ២៩
ខ. ការរំលាយកិច្ចសន្យាដោយអ្នកលក់ ........ ៣០
១. ការរំលោភបំពានជាមូលដ្ឋាននៃកិច្ចសន្យា ........ ៣១
២. ការកំណត់រយៈពេលបន្ថែមដោយអ្នកលក់ ........ ៣១
**ផ្នែកទី២ បទបញ្ញត្តិរួមសម្រាប់កាតព្វកិច្ចរបស់អ្នកលក់ និងអ្នកទិញ** ........ ៣៣
**កថាខណ្ឌទី១. ការបំពានកាលានិករណ៍ និងកិច្ចសន្យាប្រគល់ទំនិញជាបន្តបន្ទាប់** ........ ៣៣
ក. ការបំពានកាលាទិករណ៍ ........ ៣៣
ខ. កិច្ចសន្យាប្រគល់ទំនិញជាបន្តបន្ទាប់ ........ ៣៥
**កថាខណ្ឌទី២ ការខូចខាត និងការបង់ការប្រាក់** ........ ៣៥
ក. ការខូចខាត ........ ៣៦
ខ. ការបង់ការប្រាក់ ........ ៣៦
**កថាខណ្ឌទី៣ ការរក្សាទុកទំនិញ និងការរួចផុតពីការទទួលខុសត្រូវ** ........ ៣៧
ក. ការរក្សាទុកទំនិញ ........ ៣៧

ខ. ការរួចផុតពីការទទួលខុសត្រូវ ........ ៣៨
**កថាខណ្ឌទី៤ ការរំលាយកិច្ចសន្យា** ........ ៣៩
**សេចក្តីសន្និដ្ឋាន** ........ ៤១
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

សេដ្ឋកិច្ចជាកត្តាសំខាន់មួយសម្រាប់អភិវឌ្ឍប្រទេស។ បើនិយាយពីសេដ្ឋកិច្ចគេមិនត្រូវរំលងវិស័យពាណិជ្ជកម្មទេ ព្រោះពាណិជ្ជកម្មជាវិស័យមួយជំរុញអោយសេដ្ឋកិច្ចរីកចម្រើនទាំងចំពោះប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍។ ប្រទេសទាំងនោះសុទ្ធតែមានសកម្មភាពពាណិជ្ជកម្មទាំងក្នុង និងក្រៅប្រទេស។ ក្រៅពីការធ្វើជំនាញក្នុងស្រុកប្រទេសនីមួយៗតែងតែខិតខំស្វះស្វែងរកដៃគូទំនាក់ទំនងពីប្រទេសខាងក្រៅដើម្បីដោះដូរទំនិញ និងបំពេញតម្រូវការរបស់ប្រជាពលរដ្ឋ។ ការវិនិយោគឆ្លងដែនដែលបង្កើតអោយមានការផលិត និងការដោះដូរទំនិញជាការឆ្ពោះទៅរកការធ្វើពាណិជ្ជកម្មអន្តរជាតិកាន់តែទូលំទូលាយ និងការបង្កើតអោយមានឱកាសទីផ្សារការងារនៅក្នុងប្រទេសដែលបានទទួលពីការវិនិយោគអន្តរជាតិ។ តួយ៉ាងដូចជាប្រទេសកម្ពុជាដែលជាប្រទេសកំពុងអភិវឌ្ឍន៍ ដូចនេះការធ្វើពាណិជ្ជកម្មកាន់តែមានសារៈប្រយោជន៍ពីព្រោះថាភាពរស់រវើកនៃពាណិជ្ជកម្មនឹងធ្វើអោយមានការទាក់ទាញក្រុមហ៊ុនបរទេសជាច្រើនមកបណ្តាក់ទុន និងប្រកបអាជីវកម្មនៅក្នុងប្រទេស នោះនឹងធ្វើអោយចំនួនការងារកើនឡើងដែលអាចកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋបានយ៉ាងច្រើនដែលរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាកំពុងយកចិត្តទុកដាក់ខ្ពស់បំផុត។

ជាការពិតណាស់ដើម្បីធ្វើអោយវិស័យសេដ្ឋកិច្ចមានការីកចម្រើន និងលូតលាស់ ការធ្វើសមាហរណកម្មចូលទៅក្នុងតំបន់ និងពិភពលោកគឺជារឿងមួយដែលមិនអាចមើលរំលងបានឡើយ។ ជាក់ស្តែងពាណិជ្ជកម្មអន្តរជាតិរបស់កម្ពុជាមានការប្រែប្រួលជាលំដាប់ ពិសេសលើការដោះដូរទំនិញ បន្ទាប់ពីកម្ពុជាបានក្លាយជាសមាជិកប្រជាជាតិអាស៊ីអាគ្នេយ៍ (ASEAN)[1] និងបានចូលជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក (WTO)[2]។ សមិទ្ធិផលដែលកើតឡើងយ៉ាងច្រើនដូចជាវិស័យ ហេដ្ឋរចនាសម្ព័ន្ធ ផ្លូវថ្នល់ ផ្លូវទឹក អគ្គិសនីផ្សេងៗដែលបម្រើអោយវិស័យពាណិជ្ជកម្មក្តី និងវិស័យផ្សេងៗក្តីមានការរីកចម្រើនយ៉ាងឆាប់រហ័ស។ ជាពិសេសនោះគឺប្រទេសកម្ពុជាទទួលបាននូវកូតាសម្រាប់នាំទំនិញចេញចូលទៅសហរដ្ឋអាមេរិក និងសហគមអឺរ៉ុបក៏ដូចជាការទទួលបានប្រព័ន្ធអនុគ្រោះពន្ធគយសម្រាប់ទំនិញជាច្រើនមុខចេញពីកម្ពុជា និង

[1] កម្ពុជាបានក្លាយជាសមាជិកទី១០នៃប្រជាជាតិអាស៊ីអាគ្នេយ៍ (The Association of Southeast Asian Nations (ASEAN)) នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៩។ ប្រជាជាតិអាស៊ីអាគ្នេយ៍បានបង្កើតនៅថ្ងៃទី០៨ ខែសីហា ឆ្នាំ១៩៦៧ ក្នុងទីក្រុងបាងកក ប្រទេសថៃ បច្ចុប្បន្នមានសមាជិកចំនួន១០ប្រទេស។

[2] កម្ពុជាបានក្លាយជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក (The World Trade Organization (WTO)) នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៤។ អង្គការពាណិជ្ជកម្មពិភពលោកបានបង្កើតនៅថ្ងៃទី០១ ខែមករា ឆ្នាំ១៩៩០ ។ មកដល់ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦ មានសមាជិកចំនួន១៦៤ ប្រទេស។

ការដែលអាចនាំទំនិញទៅបណ្តាប្រទេសដែលជាសមាជិកនៃអង្គការ WTO ផងដែរ។ លទ្ធផលយ៉ាងប្រសើរទាំងអស់នោះក៏ដោយសារថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់នៃព្រះរាជាណាចក្រកម្ពុជាមានភាពឆ្លាតវៃក្នុងការដឹកនាំប្រទេសអោយចូលក្នុងសមាជិកប្រជាជាតិអាស៊ីអាគ្នេយ៍ក៏ដូចជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោកផងដែរ។

ទន្ទឹមនឹងមានការរីកចម្រើនលើវិស័យពាណិជ្ជកម្មអន្តរជាតិ យើងក៏ឃើញមានវិស័យផ្សេងៗទៀតក៏មានការរីកចម្រើនទៅតាមនោះដែរ ប៉ុន្តែអ្វីដែលជាបញ្ហាចោទឡើងក្នុងពេលបច្ចុប្បន្នសម្រាប់កម្ពុជានោះ គឺការប្រកួតប្រជែងថ្នាក់តំបន់ និងសកលលោកទាំងមូលថាតើប្រទេសកម្ពុជាយើងមានវិធានគតិយុត្តិសម្រាប់គ្រប់គ្រងអោយអ្នកវិនិយោគបរទេសកាន់តែមានទំនុកចិត្តមកលើកម្ពុជាកាន់តែខ្លាំងឡើង។ បន្ថែមពីលើនេះទៅទៀត ការធ្វើពាណិជ្ជកម្មនីមួយៗយើងតែងតែសង្កេតឃើញថាអ្នកលក់ និងអ្នកទិញបង្កើតកិច្ចសន្យាលក់ទំនិញជាមួយគ្នា នោះបញ្ហាចោទសួរថា បន្ទាប់ពីបង្កើតកិច្ចសន្យានោះរួចហើយ តើភាគីទាំងពីរមានកាតព្វកិច្ច និងសិទ្ធិអ្វីខ្លះ? តើអានុភាពនៃកិច្ចសន្យារបស់ពួកគាត់មានអ្វីខ្លះ?

ដោយសារតែវិស័យពាណិជ្ជកម្មមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងជួយជំរុញអោយមានការរីកចម្រើនលើគ្រប់វិស័យ ដូចនេះហើយបានជាក្រុមយើងខ្ញុំសម្រេចចិត្តធ្វើការស្រាវជ្រាវលើប្រធានបទ " **អានុភាពនៃកិច្ចសន្យាលក់ទំនិញអន្តរជាតិដោយយោងតាមអនុសញ្ញាអន្តរជាតិCISG**"។ ដើម្បីធ្វើការបង្ហាញពីប្រធានបទដែលបានជ្រើសរើសនេះ ក្រុមយើងខ្ញុំនឹងធ្វើការលើកយកមាត្រាមួយចំនួនក្នុងអន្តរជាតិ (អនុសញ្ញាCISG) មកធ្វើការពន្យល់ដោយយោងតាមអត្ថបទសង្ខេបរឿងក្តីនៃអនុសញ្ញាCISGឆ្នាំ២០១៦ (Digest of Case Law on the United Nation Convention on Contracts for the Intenational Sale of Goods 2016 Edition) និងលើកយកឧទាហរណ៍មួយចំនួនយកបញ្ជាក់។ មុននឹងធ្វើការអធិប្បាយ យើងខ្ញុំសូមបង្ហាញប្លង់ដែលមានវិសាលភាពកំណត់ជាក់លាក់មួយដែលមានពីរជំពូកធំៗគឺៈ

**ជំពូកទី១ កាតព្វកិច្ចចំពោះគូភាគី**

**ជំពូកទី២ ការទទួលខុសត្រូវចំពោះគូភាគី**

**ឥឥឥ📖ឥឥ**

# ជំពូកទី១ កាតព្វកិច្ចចំពោះគូរភាគី

ជាទូទៅកិច្ចសន្យាលក់ទំនិញត្រូវបានបង្កើតឡើង ដោយសារជំនួបរវាងសំណើ និងស្ទីការត្រូវគ្នាតាមរយៈការព្រមព្រៀងរបស់គូរភាគីដែលហៅថា អ្នកលក់ និងអ្នកទិញ។ ដូច្នេះបន្ទាប់ពីបង្កើតកិច្ចសន្យា ភាគីមានកាតព្វកិច្ចត្រូវអនុវត្តតាមការកំណត់ដូចដែលបានព្រមព្រៀងគ្នា ដោយរួមមានផ្នែកទី១ កាតព្វកិច្ចចំពោះអ្នកលក់ ដែលកំណត់ពីសកម្មភាពរបស់អ្នកលក់ក្នុងការអនុវត្តនូវកាតព្វកិច្ចរបស់ខ្លួន ចំណែកផ្នែកទី២ កាតព្វកិច្ចចំពោះអ្នកទិញ ដែលតម្រូវឲ្យអនុវត្តនូវសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួនដើម្បីសហការជាមួយនឹងការបំពេញមុខងាររបស់អ្នកលក់ និងផ្នែកទី៣ ការទទួលខុសត្រូវចំពោះហានិភ័យ ដែរកើតមានឡើងដោយសារសកម្មភាពរបស់គូរភាគី ឬតតិយជន ហើយនាំឲ្យមានព្យសនកម្មកើតឡើង ដែលតម្រូវឲ្យមានការទទួលខុសត្រូវចំពោះហានិភ័យនោះ។

## ផ្នែកទី១ កាតព្វកិច្ចចំពោះអ្នកលក់

ជាទូទៅនៅក្នុងកិច្ចសន្យាលក់ទំនិញបានចងភ្ជាប់នូវកាតព្វកិច្ចរបស់អ្នកលក់ និងអ្នកទិញដើម្បីឲ្យពួកគាត់បំពេញនូវមុខងាររបស់ខ្លួនតាមការព្រមព្រៀងនោះ។ ចំណែកឯកិច្ចសន្យាលក់ទំនិញអន្តរជាតិក៏តម្រូវឲ្យភាគីមានកាតព្វកិច្ចអនុវត្តតាមឆន្ទៈរបស់ខ្លួនដូចគ្នាដែល ដោយអ្នកលក់ទំនិញមានកាតព្វកិច្ចប្រគល់ទំនិញទៅអោយភាគីអ្នកទិញ និងប្រគល់នូវឯកសារទាំងឡាយដែលពាក់ព័ន្ធនឹងទំនិញនោះ រួមបញ្ចូលទាំងការផ្ទេរកម្មសិទ្ធិដែលមាននៅក្នុងទំនិញ តាមការកំណត់ដោយកិច្ចសន្យា ប៉ុន្តែប្រសិនបើកិច្ចសន្យាមិនបានកំណត់ទេ ភាគីត្រូវអនុវត្តតាមអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីកិច្ចសន្យាលក់ទំនិញអន្តរជាតិ (អនុសញ្ញាCISG)។[3] អ្នកលក់ទំនិញក៏ត្រូវតែធានាចំពោះអ្នកទិញ អំពីទំនិញដែលខ្លួនបានបញ្ជូនទៅនោះដោយអនុលោមទៅតាមអ្វីដែលបានកំណត់នៅក្នុងកិច្ចសន្យា រួមមានទាំងគុណភាព បរិមាណ ការពិពណ៌នានូវវិធីនៃការប្រើប្រាស់ និងការវេចខ្ចប់នូវទំនិញតាមកិច្ចសន្យាដែលមានបានព្រមព្រៀងគ្នា។

### កថាខណ្ឌទី១ ការប្រគល់ទំនិញ និងការប្រគល់សំណុំឯកសារ

បន្ទាប់ពីបង្កើតកិច្ចសន្យា អ្នកលក់មានកាតព្វកិច្ចប្រគល់នូវទំនិញ និងឯកសារដែលជាប់ពាក់ព័ន្ធទៅនឹងទំនិញដែលខ្លួនបានលក់ទៅឲ្យភាគីអ្នកទិញ។[4] កាតព្វកិច្ចនៃការប្រគល់នេះតម្រូវឲ្យ

[3] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីកិច្ចសន្យាលក់ទំនិញអន្តរជាតិ (អនុសញ្ញាCISG) ត្រូវបានអនុម័តនៅថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៨០ និងចូលជាធរមាននៅថ្ងៃទី០១ ខែមករា ឆ្នាំ១៩៨៨ នៅទីក្រុងវីយែន ប្រទេសអូទ្រីស។ សព្វថ្ងៃមានប្រទេសចំនួន៨៩ជាសមាជិក។

[2] យោងតាម មាត្រា៣០ នៃអនុសញ្ញាCISG

មានការកំណត់ក្នុងកិច្ចសន្យាយ៉ាងច្បាស់លាស់ពីទំនិញ និងឯកសារ ជៀសវាងមានការរំលោភបំពានក្នុងករណីណាមួយកើតឡើង។ ម្យ៉ាងវិញទៀត ក្នុងករណីដែលគូភាគីមិនបានកំណត់ ឬកំណត់មិនច្បាស់លាស់ក្នុងកិច្ចសន្យា ភាគីត្រូវប្រើប្រាស់នូវគោលការណ៍ដែលកំណត់ក្នុងអនុសញ្ញាCISG ជាជំនួយសម្រាប់ដោះស្រាយនូវកង្វះខាតនោះ។

### ក. ការប្រគល់ទំនិញ

ចំពោះការប្រគល់ទំនិញ ភាគីត្រូវកំណត់ឲ្យបានច្បាស់លាស់នូវទីកន្លែងប្រគល់ទំនិញ និងពេលវេលាសម្រាប់ការប្រគល់ទំនិញ។ ម្យ៉ាងវិញទៀត ប្រសិនបើឯកសារផ្សេងៗត្រូវបានផ្លាស់ប្តូររវាងភាគីដែលមានលក្ខខណ្ឌផ្សេងគ្នា ឬមានកិច្ចព្រមព្រៀងផ្ទាល់មាត់ជាមួយនឹងការអនុវត្តរបស់គូភាគីអំពីការកំណត់ទីកន្លែងនៃការប្រគល់ទំនិញ និងឯកសារនោះ ភាគីអាចប្រើនូវគោលការណ៍នៃអនុសញ្ញាCISG ដើម្បីបង្កើតកន្លែងនៃការបំពេញកាតព្វកិច្ចរបស់អ្នកលក់ក្នុងការដឹកជញ្ជូនទំនិញ។[5]

#### ១. ទីកន្លែងប្រគល់ទំនិញ

ក្នុងកិច្ចសន្យាត្រូវកំណត់ពីទីកន្លែងនៃការអនុវត្តការប្រគល់ទំនិញ និងឯកសារឲ្យបានច្បាស់លាស់សម្រាប់អ្នកលក់អនុវត្តនូវកាតព្វកិច្ចរបស់ខ្លួន ប៉ុន្តែប្រសិនបើទីកន្លែងមិនបានកំណត់ក្នុងកិច្ចសន្យានោះទេ ដំណោះស្រាយនូវការកំណត់ពីទីកន្លែងនៃការអនុវត្តមានបីកន្លែងគឺ[6]៖

- អ្នកលក់ត្រូវប្រគល់ទំនិញទៅឱ្យក្រុមហ៊ុនទីមួយសម្រាប់ការដឹកជញ្ជូនទៅឱ្យអ្នកទិញ ប្រសិនបើកិច្ចសន្យានោះទាក់ទងនឹងការដឹកជញ្ជូនទំនិញ។

- ប្រសិនបើក្នុងករណីមិនមានចែងខាងលើទេ ហើយកិច្ចសន្យាទាក់ទងនឹងទំនិញជាក់លាក់ ឬទំនិញមិនជាក់លាក់ណាមួយ ការប្រគល់ទំនិញត្រូវបានគេប្រគល់នៅកន្លែងស្តុកទំនិញរបស់អ្នកទិញ ឬក៏នៅរោងចក្ររបស់អ្នកទិញ។

- ប្រសិនបើក្នុងករណីដែលអ្នកទិញមិនមានកន្លែងធ្វើអាជីវកម្មច្បាស់លាស់ ឬមិនមានស្តុកដាក់ទំនិញ ឬមិនមានរោងចក្រទេ ត្រូវដាក់ទំនិញនៅទីកន្លែងធ្វើអាជីវកម្មរបស់លក់ដូច្នេះមានន័យថាតម្រូវឲ្យអ្នកទិញមកទទួលទំនិញនៅទីកន្លែងនោះ នាំឲ្យអ្នកលក់បានបំពេញកាតព្វកិច្ចប្រគល់ទំនិញរបស់ខ្លួន ។

---

[5] *'Rights and Obligations of the Seller and Buyer'* (Lawteacher.net, May 2018) <https://www.lawteacher.net> accessed 30 May 2018.

[6] យោងតាម មាត្រា៣១ នៃអនុសញ្ញាCISG

ប្រសិនបើកិច្ចសន្យាតម្រូវអោយអ្នកលក់ធ្វើការរៀបចំនូវការដឹកជញ្ជូន ប៉ុន្តែមិនបានកំណត់ឲ្យបានច្បាស់ពីក្រុមហ៊ុនដឹកជញ្ជូនទេ អ្នកលក់ត្រូវជ្រើសរើសយកមធ្យោបាយដឹកជញ្ជូនអោយបានសមស្របតាមកាលៈទេសៈ បន្ទាប់មកត្រូវធ្វើការប្រគល់ទំនិញទៅតាមសេចក្តីបង្គាប់ដែលវិធាននៃមធ្យោបាយដឹកជញ្ជូននោះតម្រូវ។ កាតព្វកិច្ចរបស់អ្នកលក់ត្រូវបានបំពេញ នៅពេលបានផ្ទេរទៅក្រុមហ៊ុនដឹកជញ្ជូនដំបូង ហើយម្យ៉ាងវិញទៀត អ្នកលក់ត្រូវផ្តល់ដំណឹងលម្អិតទៅឲ្យអ្នកទិញពីក្រុមហ៊ុនដឹកជញ្ជូន និងបញ្ជាក់ពីទំនិញ។[7] ចំពោះការទទួលខុសត្រូវក្នុងការខកខានមិនបានអនុវត្តកាតព្វកិច្ចរបស់អ្នកដឹកជញ្ជូននឹងមិនមានទំនាក់ទំនងជាមួយអ្នកលក់ទេ ប្រសិនបើអ្នកលក់បានគោរពកិច្ចសន្យាក្នុងការដឹកជញ្ជូនទំនិញ ដោយកាតព្វកិច្ចរបស់អ្នកលក់បានរៀបចំទំនិញ និងត្រៀមលក្ខណៈរួចរាល់សមស្របសម្រាប់ការដឹកជញ្ជូន រួមបញ្ចូលទាំងការវេចខ្ចប់ហើយបានបញ្ជូនទៅកាន់អ្នកដឹកជញ្ជូនរួចរាល់។

ប្រសិនបើកិច្ចសន្យាមិនតម្រូវអោយអ្នកលក់ធ្វើការទទួលខុសត្រូវចំពោះថ្លៃធានារ៉ាប់រងទំនិញទេ នោះអ្នកលក់ធ្វើតាមសំណើ និងត្រូវផ្តល់ឲ្យអ្នកទិញនូវព័ត៌មានដែលចាំបាច់ដើម្បីផ្តល់ជាលទ្ធភាពអោយអ្នកទិញ ទិញធានារ៉ាប់រងលើទំនិញនោះ។

### ២. ពេលវេលាប្រគល់ទំនិញ

ពេលវេលា និងទីកន្លែងនៃការដឹកជញ្ជូនត្រូវបានយល់ព្រមជាញឹកញាប់ដោយភាគីតាមរយៈកិច្ចសន្យា ឬដោយការបញ្ជាទិញជាបន្តបន្ទាប់ ដែលអ្នកលក់ទំនិញមានកាតព្វកិច្ចប្រគល់ទំនិញនៅកាលបរិច្ឆេទ ដូចដែលមានកំណត់នៅក្នុងកិច្ចសន្យា។[8] ប៉ុន្តែប្រសិនបើមិនមានចែងក្នុងកិច្ចសន្យានោះទេ អ្នកលក់ត្រូវធ្វើការប្រគល់ទំនិញទៅអោយអ្នកទិញក្នុងអំឡុងពេលវេលាណាមួយសមរម្យក្រោយពេលដែលកិច្ចសន្យាត្រូវបានបង្កើតហើយ ដោយការកំណត់ (ពេលវេលាសមរម្យ) ត្រូវយកចិត្តទុកដាក់ចំពោះ ចរិតលក្ខណៈនៃទំនិញ ចម្ងាយគ្របដណ្តប់ និងសេចក្តីថ្លែងការណ៍របស់ភាគីក្នុងអំឡុងពេលចរចា។ ប្រសិនបើកិច្ចសន្យាបានកំណត់ថាការប្រគល់ទំនិញក្នុងអំឡុងពេលណាមួយដោយអ្នកទិញបានជ្រើសរើសនូវកាលបរិច្ឆេទ (ឧទាហរណ៍៖ ការប្រគល់ទំនិញត្រូវប្រគល់នៅក្នុងខែមិថុនា) ប៉ុន្តែប្រសិនបើអ្នកទិញមិនបានជ្រើសរើសអោយបានច្បាស់លាស់ពីពេលវេលាជាក់លាក់ណាមួយទេនោះ អ្នកលក់ត្រូវអនុវត្តនូវកាតព្វកិច្ចរបស់ខ្លួននៅពេលដែលបានព្រមព្រៀងកំណត់ក្នុងកិច្ចសន្យា។

[7] យោងតាម មាត្រា៣២ នៃអនុសញ្ញាCISG

[8] យោងតាម មាត្រា៣៣ នៃអនុសញ្ញាដដែល

ប្រសិនបើភាគីបានព្រមព្រៀងគ្នាលើកាលបរិច្ឆេទច្បាស់លាស់ និងប្រសិនបើភាគីទាំងពីរបានដឹងច្បាស់អំពីកាលបរិច្ឆេទជាក់លាក់នៃការដឹកជញ្ជូននោះ តែមិនប្រគល់ទំនិញតាមកាលបរិច្ឆេទដែលបានកំណត់នោះ វាជាការរំលោភបំពានកាតព្វកិច្ចនូវពេលវេលានៃការដឹកជញ្ជូន។ ការរំលោភបំពានជាមូលដ្ឋានអាចកើតមានឡើងចំពោះការមិនផ្តល់ជូនការប្រគល់ បន្ទាប់ពីកាលបរិច្ឆេទដែលបានបញ្ជាក់ ឬការខកខានមិនបានដឹកជញ្ជូនបន្ទាប់ពីបានពន្យាពេលនៃការដឹកជញ្ជូនដែលអ្នកទិញបានផ្តល់ឲ្យនូវពេលវេលាសមរម្យមួយ។

ករណីអ្នកលក់បានប្រគល់ទំនិញមុនពេលកាលបរិច្ឆេទសម្រាប់ការដឹកជញ្ជូនដែលបានកំណត់ គាត់អាចផ្តល់នូវផ្នែកណាមួយដែលបាត់បង់ ឬបន្ថែមនូវកង្វះណាមួយនៅក្នុងបរិមាណនៃទំនិញដែលបានបញ្ជូន ឬផ្តល់ទំនិញជំនួសរាល់ទំនិញដែលមិនអនុលោមតាមលក្ខខណ្ឌត្រូវបានបញ្ជូន ឬដោះស្រាយរាល់កង្វះអនុលោមភាពនៃទំនិញដែលបានប្រគល់ទៅឲ្យអ្នកលក់រហូតដល់ថ្ងៃដែលបានកំណត់ក្នុងកិច្ចសន្យា ការអនុវត្តសិទ្ធិរបស់អ្នកលក់នឹងមិនបណ្តាលឱ្យអ្នកទិញមានការរអាក់រអួលមិនសមហេតុផល ឬការចំណាយគ្មានហេតុផល។ តែទោះជាយ៉ាងណាក៏ដោយអ្នកទិញនូវមានសិទ្ធិទាមទារសំណងខូចខាត ចំពោះការអនុវត្តរបស់អ្នកលក់។[9]

### ខ. ការប្រគល់សំណុំឯកសារ

នៅពេលធ្វើការប្រគល់ទំនិញទៅតាមពេលវេលា និងទីកន្លែងដែលបានព្រមព្រៀងហើយនោះ អ្នកលក់ត្រូវធ្វើការប្រគល់នូវឯកសារចាំបាច់ទាំងឡាយណា ដែលមានការទាក់ទងជាមួយទំនិញ។ ដោយផ្អែកលើឆន្ទៈរបស់គូរភាគី អ្នកលក់ត្រូវប្រគល់នូវសំណុំបែបបទដូចជា៖ បញ្ជីវាយមុខទំនិញ វិក័យប័ត្រ ប័ណ្ណធានារ៉ាប់រង វិញ្ញាបនបត្រដើម និងវិញ្ញាបនបត្រនៃការត្រួតពិនិត្យគុណភាព។ ដូច្នេះអ្នកលក់ត្រូវប្រគល់ឱ្យអ្នកទិញ នៅពេលវេលានិងទីកន្លែង និងតាមទម្រង់ដែលតម្រូវដោយកិច្ចសន្យា។

#### ១. ឯកសារដែលត្រូវប្រគល់ និង ការផ្ទេរកម្មសិទ្ធិនៃទំនិញ

ឯកសារដែលតម្រូវឲ្យប្រគល់រួមមានតែឯកសារដែលទាក់ទងនឹងទំនិញតែប៉ុណ្ណោះ ចំពោះឯកសារផ្សេងៗទៀតមិនតម្រូវឡើយ ជៀសវាងឯកសារក្លែងក្លាយដែលនាំឲ្យមានការរំលោភបំពានលើអ្នកទិញ។ អ្នកលក់ត្រូវប្រាកដថាឯកសារដែរខ្លួនបានប្រគល់ទៅ មានអត្ថប្រយោជន៍គ្រប់គ្រាន់សំរាប់អ្នកទិញប្រើប្រាស់ និងអាចយកទៅអះអាងពីម្ចាស់កម្មសិទ្ធិនៃទំនិញ។

[9] យោងតាម មាត្រា៣៧ នៃអនុសញ្ញាCISG

### ១.១. ឯកសារដែលត្រូវប្រគល់

តើឯកសារដែលត្រូវប្រគល់ឲ្យអ្នកទិញមានអ្វីខ្លះ? អ្នកលក់មានកាតព្វកិច្ចក្នុងការផ្តល់ឱ្យអ្នកទិញនូវវិក័យប័ត្របញ្ជាក់បរិមាណ និងតម្លៃរបស់ទំនិញ វិក័យប័ត្រដឹកជញ្ជូន បង្កាន់ដៃចូលផែ និងបង្កាន់ដៃឃ្លាំង ប៉ុន្តែពួកគេក៏រួមបញ្ចូលគោលការណ៍ការធានារ៉ាប់រងផងដែរ វិក្កយប័ត្រពាណិជ្ជកម្ម វិញ្ញាបនប័ត្រ (ឧទាហរណ៍៖ ប្រភពដើម ទម្ងន់ ខ្លឹមសារ ឬគុណភាព) និងឯកសារស្រដៀងគ្នាផ្សេងទៀត។[10] វាត្រូវបានគេរកឃើញថាអ្នកលក់ជាទូទៅមិនមានកាតព្វកិច្ច ដើម្បីទទួលបាននូវឯកសារគយសម្រាប់ការនាំចេញទំនិញ លុះត្រាតែភាគីទាំងព្រមព្រៀងគ្នាផ្សេងទៀតប៉ុណ្ណោះ។

ការប្រគល់ឯកសារដែលមិនស្របតាមលក្ខខណ្ឌ គឺជាការរំលោភលើកិច្ចសន្យាដែលមានដំណោះស្រាយសម្រាប់អនុវត្ត។ បញ្ញត្តិស្តីពីការរំលោភបំពានធ្ងន់ធ្ងរគ្រប់គ្រាន់ វាអាចជាការរំលោភបំពានជាមូលដ្ឋាន ដូច្នេះអនុញ្ញាតឱ្យអ្នកទិញប្រកាសរំលាយកិច្ចសន្យា ប៉ុន្តែការប្រគល់ឯកសារដែលមិនស្របតាមច្បាប់ (វិញ្ញាបនប័ត្រមិនត្រឹមត្រូវនៃប្រភពដើម) ហើយប្រសិនបើអ្នកទិញខ្លួនឯងអាចដោះស្រាយភាពខុសឆ្គងបានយ៉ាងងាយស្រួលដោយការស្នើសុំឯកសារត្រឹមត្រូវពីអ្នកផលិតនោះមិនចាត់ទុកថារំលោភបំពានទេ។ ចំពោះការធ្វេសប្រហែសនៃការប្រគល់នូវវិញ្ញាបនប័ត្របញ្ជាក់គុណភាពជីវសាស្ត្រនៃទំនិញ ត្រូវបានចាត់ទុកថាជាការរំលោភកិច្ចសន្យា។

### ១.២. ការផ្ទេរកម្មសិទ្ធិនៃទំនិញ

កាតព្វកិច្ចសំខាន់របស់អ្នកលក់គឺការត្រូវផ្ទេរកម្មសិទ្ធិនៃទំនិញទៅឱ្យអ្នកទិញ។ ប៉ុន្តែការផ្ទេរកម្មសិទ្ធិនៃទំនិញអន្តរជាតិមិនត្រូវបានគ្រប់គ្រងដោយអនុសញ្ញាCISGទេ វាត្រូវស្ថិតនៅក្រោមច្បាប់ដែលអនុវត្តនៅក្រោមកិច្ចប្រជុំនៃច្បាប់អន្តរជាតិឯកជន (private international law of the forum)។[11] តែទោះជាយ៉ាងណា ក៏ត្រូវបានកំណត់ដោយសេចក្តីយោងទៅនឹងច្បាប់នៃអនុសញ្ញានេះដែលតម្រូវឲ្យអ្នកលក់ផ្តល់ដូចជា ៖ វិញ្ញាបនបត្រ ប្រកាសនីយប័ត្រតក្កកម្ម និងសិទ្ធិកម្មសិទ្ធិបញ្ញារបស់អ្នកលក់ដែលត្រូវផ្តល់ទៅអ្នកទិញនៅក្រោមកិច្ចសន្យាលក់ទំនិញ។[12]

[10] យោងតាម កថាខណ្ឌ៤ នៃអត្ថបទសង្ខេបរឿងក្តីក្នុងអនុសញ្ញាអង្គការសហប្រជាជាតិនៃកិច្ចសន្យាលក់ទំនិញអន្តរជាតិ ឆ្នាំ២០១៦ (អត្ថបទសង្ខេបរឿងក្តីនៃអនុសញ្ញាCISG) ទំព័រទី ១៣៦

[11] យោងតាម កថាខណ្ឌ ៤ នៃអត្ថបទសង្ខេបនៃរឿងក្តីនៃអនុសញ្ញាCISG ឆ្នាំ២០១៦ ទំព័រទី ១២៦

[12] យោងតាម មាត្រា ៤២ នៃអនុសញ្ញា CISG

### ២. ពេលវេលានៃការប្រគល់សំណុំឯកសារ

ការប្រគល់ទំនិញ និងឯកសារត្រូវប្រគល់នៅពេលដែលបានកំណត់ក្នុងកិច្ចសន្យា ប៉ុន្តែប្រសិនបើមិនកំណត់ជាក់លាក់ក្នុងកិច្ចសន្យាទេ អ្នកលក់ត្រូវប្រគល់ឯកសារស្របនឹងទីកន្លែងប្រគល់ទំនិញដែលបានបញ្ជាក់ខាងលើ។[13] ប្រសិនបើគាត់បានប្រគល់ឯកសារមុនពេលកំណត់ គាត់អាចចាត់ចែងឯកសារនានាដែលខ្វះខាត ឬធ្វើការកែតម្រូវនូវចំណុចខ្វះខាតទាំងឡាយនូវសំណុំឯកសារដែលត្រូវប្រគល់មិនអនុលោមតាមអ្វីដែលបានតម្រូវនៅក្នុងកិច្ចសន្យា អ្នកលក់អាចបន្ថែមនូវចំណុចខ្វះខាតរហូតដល់ពេលវេលាដែលកំណត់បានមកដល់ ក្នុងលក្ខខណ្ឌនៃការអនុវត្តសិទ្ធិនោះមិនធ្វើឲ្យអ្នកទិញមានការលំបាក ឬមិនសមហេតុផល។ ទោះជាយ៉ាងណាក៏ដោយអ្នកទិញនៅតែមានសិទ្ធិទាមទារសំណងខូចខាត។[14] ម្យ៉ាងទៀតបន្ទាប់ពីកាលបរិច្ឆេទនៃការប្រគល់ឯកសារ អ្នកលក់មិនអាចប្រគល់ឯកសារទៅឲ្យអ្នកទិញ ចាត់ទុកថាជាការរំលោភបំពានកិច្ចសន្យា ប៉ុន្តែប្រសិនបើមានការព្រមព្រៀងគ្នានូវរយៈពេលបន្ថែមទាក់ទងនឹងការប្រគល់ឯកសាររវាងអ្នកលក់ និងអ្នកទិញក្រោយកាលបរិច្ឆេទ នោះមិនចាត់ទុកថារំលោភបំពានកិច្ចសន្យាទេ។

## កថាខណ្ឌទី២ អនុលោមភាពនៃទំនិញ

ចំណុចសំខាន់នៃបញ្ហាលក់ទំនិញជាច្រើនគឺត្រូវបានកត់សម្គាល់ថាតើទំនិញដែលប្រគល់ទៅឲ្យអ្នកទិញស្របតាមកិច្ចសន្យាឬទេ? មាត្រា៣៥ នៃអនុសញ្ញាCISG គឺជាស្នូលនៃការកំណត់ពីទំនិញដែលអ្នកលក់ត្រូវប្រគល់ និងត្រូវបានចាត់ទុកថាអនុលោមតាមកិច្ចសន្យា ក្នុងលក្ខខណ្ឌនៃប្រភេទ បរិមាណ គុណភាព និងការវេចខ្ចប់ ដើម្បីធានានូវកម្មវត្ថុមុនទៅដល់អ្នកទិញ។ ក្នុងករណីដែលទំនិញមានបញ្ហា ឬវិធីប្រើប្រាស់នៃទំនិញ អ្នកលក់ត្រូវអនុវត្តកាតព្វកិច្ចនៃការជូនដំណឹងពីព័ត៌មាននានាដែរទាក់ទងទំនិញ និងការធានាពីការរំខានរបស់តតិយជន។

ចំពោះគំនិតមូលដ្ឋាននៃកង្វះអនុលោមភាពនៃទំនិញ ដោយរួមបញ្ចូលមិនត្រឹមតែភាពខុសគ្នានៃគុណភាព ប៉ុន្តែរួមទាំងបរិមាណ ការដឹកជញ្ជូនទំនិញខុសពីកម្មវត្ថុក្នុងកិច្ចសន្យា និងកំហុសឆ្គងនៃការវេចខ្ចប់។ ចំណែកការដឹកជញ្ជូនទំនិញខុសពីប្រភេទដែលតម្រូវដោយកិច្ចសន្យា និងការប្រគល់ឯកសារក្លែងក្លាយទាក់ទងទៅនឹងប្រភពដើមនៃទំនិញគឺជាកង្វះអនុលោមនៃទំនិញ។[15] ការ

---

[13] យោងតាម មាត្រា៣១ នៃអនុសញ្ញាCISG

[14] យោងតាម មាត្រា៣៤ កថាខណ្ឌ២ នៃអនុសញ្ញាដដែល

[15] យោងតាម កថាខណ្ឌ១ នៃអត្ថបទសង្ខេបនៃរឿងក្ដីនៃអនុសញ្ញាCISG ឆ្នាំ២០១៦ ទំព័រទី ១៤០

រំលោភបំពានរបស់អ្នកលក់ចំពោះកាតព្វកិច្ចរបស់ខ្លួនក្នុងលក្ខខណ្ឌទាំងនេះ អាចស្ថិតក្នុងកាលៈទេសៈសមស្របចំពោះអ្នកទិញក្នុងការរំលោយកិច្ចសន្យា។

### ក. ការធានានូវទំនិញមុននៅដល់អ្នកទិញ

អ្នកលក់មានកាតព្វកិច្ចអនុវត្តតាមកិច្ចសន្យាក្នុងការប្រគល់នូវប្រភេទទំនិញ បរិមាណ គុណភាព ការពិពណ៌នា និងការវេចខ្ចប់យ៉ាងសមស្រប ជូនអ្នកទិញនៅកាលបរិច្ឆេទដែលបានកំណត់។ ចំពោះភាពខុសគ្នាក្នុងបរិមាណ និងតម្រូវការនៃកិច្ចសន្យាអាចត្រូវចាត់ទុកថាជាទំនិញមិនអនុលោម ប្រសិនបើវិការៈឈានដល់កម្រិតមួយធ្ងន់ធ្ងរជាក់លាក់ ដូចជាការដឹកទំនិញមានតិចជាងបរិមាណដែលបានបញ្ជាក់ក្នុងកិច្ចសន្យា ការខ្វះខាតនៃគុណភាពនៅក្នុងទំនិញដែលបានបញ្ជូនជាកង្វះនៃការអនុលោម។[16] ឧទាហរណ៍ៈ កន្លែងដែលកិច្ចសន្យាមួយតម្រូវឱ្យចាក់ដីមាន ៥០ គីឡូក្រាមនៃដីឥដ្ឋក្នុងមួយម៉ែត្រការ៉េនៃដីដែលចាក់ ប៉ុន្តែដីដែលបានបញ្ជូនមកមានសមាមាត្រខុសគ្នានៃដីឥដ្ឋ ត្រូវបានរកឃើញថាមិនអនុលោមតាមកិច្ចសន្យា។

បទដ្ឋានទាក់ទងនឹង គុណភាពនៃទំនិញ មុខងារ និងការវេចខ្ចប់ ដែលមិនបានកំណត់ក្នុងពេលបង្កើតកិច្ចសន្យា តម្រូវឱ្យអ្នកលក់ត្រូវប្រគល់ទំនិញសមស្របសម្រាប់គោលបំណងនៃទំនិញទូទៅដែលត្រូវបានប្រើ មានការពិពណ៌នាដូចគ្នា ដោយមិនតម្រូវឱ្យទំនិញនោះល្អឥតខ្ចោះនោះទេ ទំនិញអាចមានគុណភាពមធ្យម "គុណភាពសម្រាប់ទីផ្សារ" ឬគុណភាពសមរម្យ សំរាប់មនុស្សប្រើប្រាស់ជាទូទៅក្នុងប្រទេសនីមួយៗ និងមិនគួរមានគ្រោះថ្នាក់ដល់សុខភាព ឬមានការសង្ស័យថាជាទំនិញដែលបង្ករគ្រោះថ្នាក់ដល់សុខភាព ប៉ុន្តែប្រសិនបើការប្រគល់ទំនិញនាំឲ្យមានគ្រោះថ្នាក់នោះមានន័យថាកង្វះអនុលោមភាពនៃទំនិញ។[17] ម្យ៉ាងវិញទៀត ករណីទំនិញសម្រាប់គោលបំណងជាក់លាក់របស់អ្នកទិញបានបញ្ជាក់ដល់អ្នកលក់នៅពេលបង្កើតកិច្ចសន្យា អ្នកលក់មានកាតព្វកិច្ចផ្តល់ទំនិញដែលបានធ្វើតាមស្តង់ដារទាំងនោះ ប៉ុន្តែអ្នកលក់មិនត្រូវអនុវត្តនូវការប្រគល់ទំនិញតាមស្តង់ដានោះទេ ប្រសិនបើមានកាលៈទេសៈបង្ហាញថាអ្នកទិញមិនបានពឹងផ្អែក ឬវាជាការមិនសមហេតុផលសម្រាប់គាត់ដើម្បីពឹងផ្អែកលើជំនាញនិងការវិនិច្ឆ័យរបស់អ្នកលក់ ដែលអ្នកទិញខ្លួនឯងជាអ្នកនាំចូលទំនិញដ៏មានបទពិសោធន៍ស្មើ ឬធំជាងអ្នកលក់។ ក្នុងករណីមួយផ្សេងទៀត ដើម្បីអនុលោមតាមកិច្ចសន្យា ទំនិញដែលអ្នកលក់បានប្រគល់ទៅឲ្យអ្នកទិញ ត្រូវធ្វើឡើងតាមគំរូ ឬម៉ូត ដែរបានបញ្ជាក់ច្បាស់លាស់ក្នុងកិច្ចសន្យា លើកលែងតែភាគីបានព្រមព្រៀងនូវម៉ូត ឬគំរូ

[16] យោងតាម កថាខណ្ឌ ២ នៃអត្ថបទសង្ខេបនៃរឿងក្តីនៃអនុសញ្ញាCISG ឆ្នាំ២០១៦ ទំព័រទី១៥០

[17] យោងតាម មាត្រា៣៥ វាក្យខណ្ឌ១ នៃកថាខណ្ឌ២ ដោយអនុសញ្ញាCISG

ផ្សេងទៀត។ ចំពោះស្តង់ដារក្នុងការវេចខ្ចប់បានបង្ហាញថាទំនិញដែលមិនបានវេចខ្ចប់ត្រឹមត្រូវតាមលក្ខណៈ ឬលក្ខខណ្ឌនៃទំនិញ គឺមិនអនុលោមតាមកិច្ចសន្យា។ ដូចនេះ អ្នកលក់ត្រូវវេចខ្ចប់ទំនិញស្របតាមលក្ខខណ្ឌនូវទំនិញឲ្យបានត្រឹមត្រូវ និងមានលក្ខណៈនៃការពារទំនិញពីហានិភ័យនានាក្នុងអំឡុងពេលនៅការដឹកជញ្ជូន។

ការកាត់បន្ថយការទទួលខុសត្រូវរបស់អ្នកលក់ដែលបណ្តាលមកពីកង្វះនៃការអនុលោមក្នុងករណីដែលអ្នកទិញ "បានដឹង ឬមិនអាចមិនបានដឹង" ពីការមិនអនុលោមនៅពេលបង្កើតកិច្ចសន្យា ហើយអ្នកទិញនៅតែជ្រើសរើសទិញទំនិញនោះគឺត្រូវតែទទួលយកទំនិញ ចំណែកអ្នកលក់មិនទទួលខុសត្រូវទេ។

**ខ. ការផ្តល់ព័ត៌មានទាក់ទងទៅនឹងទំនិញទៅដល់អ្នកទិញ**

នៅពេលបង្កើតកិច្ចសន្យាលក់ទំនិញអ្នកលក់ត្រូវប្រាប់ពីព័ត៌មានទាក់ទងទៅនឹងទំនិញទៅអ្នកទិញដើម្បីជៀសវាងមានវិវាទ ចំណែកពេលប្រគល់ទំនិញទៅឲ្យអ្នកទិញ អ្នកលក់គួរប្រាប់ពីព័ត៌មានបន្ថែមនៅក្នុងសំណុំឯកសារដែលពាក់ព័ន្ធ ប្រសិនបើអ្នកលក់ដឹងពីភាពមិនប្រក្រតីនោះ។

ក្នុងករណីដែលអ្នកលក់បានដឹង ឬមិនអាចមិនបានដឹងពីកង្វះអនុលោមភាពនៃទំនិញមុនការប្រគល់នូវទំនិញ និងមិនបានបង្ហាញព័ត៌មានដល់អ្នកទិញ នោះនាំឲ្យអ្នកទិញទទួលរងនូវការខូចខាតបន្ទាប់ពីទំនិញត្រូវបានទទួលយក អ្នកលក់ត្រូវទទួលខុសត្រូវដោយមិនអាចសំអាងលើលក្ខខណ្ឌដែលអ្នកទិញមិនបានត្រួតពិនិត្យទំនិញ និងអ្នកទិញខកខានមិនបានផ្តល់ដំណឹងពីកង្វះអនុលោមភាពនៃទំនិញ។ ករណីនេះ បទបញ្ញត្តិគឺការពារអ្នកទិញ ដោយសារអ្នកលក់ដឹងពីភាពមិនប្រក្រតី ឬការខ្វះខាតនូវចំណេះដឹងរបស់ខ្លួននៃកំហុសដែលមិនអាចមិនដឹងរួមទៅនឹងគំនិតទុច្ចរិកដែរមិនផ្តល់ព័ត៌មានដល់អ្នកទិញពីកង្វះអនុលោមភាពនៃទំនិញ ។[18]

ដើម្បីការពារអ្នកលក់ពីការទទួលខុសត្រូវ អ្នកលក់ត្រូវលាតត្រដាងពីកង្វះអនុលោមភាពនៃទំនិញទៅអ្នកទិញនៅពេលបង្កើតកិច្ចសន្យា ឬនៅបន្ទាប់ពីអ្នកលក់ខ្លួនឯងបានរកឃើញនូវកង្វះអនុលោមភាពនៃទំនិញត្រូវជូនដំណឹងទៅដល់អ្នកទិញ ហើយប្រសិនបើអ្នកទិញនៅតែទទួលទំនិញដែលខ្វះការអនុលោម នោះអ្នកលក់មិនទទួលខុសត្រូវទេ ម្យ៉ាងវិញទៀតអ្នកទិញត្រូវបានបានលះបង់សិទ្ធិ នៅពេលដែលអ្នកទិញបានចរចាជាមួយអ្នកលក់ អំពីតំលៃការកាត់បន្ថយដោយផ្អែកលើកំហុសជាក់លាក់នៅក្នុងទំនិញ។

[18] យោងតាម មាត្រា៥០ នៃកថាខណ្ឌ ១ ដោយអត្ថបទសង្ខេបនៃរឿងក្តីនៃអនុសញ្ញាCISG ឆ្នាំ២០១៦ ទំព័រទី ១៩៨

**គ. ការធានាពីការរំខាន**

ជាទូទៅអ្នកលក់ត្រូវផ្តល់ទំនិញដែលមិនជាប់ពាក់ព័ន្ធនិងកម្មសិទ្ធិរបស់បុគ្គលណាផ្សេង និង ធានានូវសិទ្ធិលើទំនិញទៅដល់អ្នកទិញនៅពេលបង្កើតកិច្ចសន្យា និងក្រោយពីបង្កើតកិច្ចសន្យា លុះត្រាតែអ្នកទិញបានយល់ព្រមយកទំនិញទៅតាមសិទ្ធិ ឬការទាមទារនោះ។[19] មាត្រា ៤២នៃអនុសញ្ញា CISG បញ្ជាក់ពីកាតព្វកិច្ចទូទៅរបស់អ្នកលក់ដើម្បីប្រគល់ទំនិញដល់អ្នកទិញដែលរួចផុតពីសិទ្ធិ និង ការទាមទារលើទ្រព្យសម្បត្តិឧស្សាហកម្មរួមមាន (ការប្រកាសនីយប័ត្រតក្កកម្មគ្រប់ប្រភេទ និង ដំណើរការនៃការប្រកាសនីយប័ត្រតក្កកម្ម) និងកម្មសិទ្ធិបញ្ញារបស់តតិយជន។ ក្នុងករណីដែលអ្នកលក់បានដឹងពីអត្ថិភាពនៃសិទ្ធិ ឬការទាមទារសំណងនៅក្នុងស្ថានភាពនៃការលក់ ឬការប្រើប្រាស់ទំនិញលើទ្រព្យសម្បត្តិឧស្សាហកម្ម ឬកម្មសិទ្ធិបញ្ញាជារបស់តតិយជន ឬសិទ្ធិលើផ្នែកឧស្សាហកម្មណាមួយ ត្រូវបានគេបណ្តឹងទាមទារ នោះវាគឺជាផ្នែកមួយនៃដែនហានិភ័យរបស់អ្នកលក់ក្នុងការដោះស្រាយជាមួយតតិយជន។

ដូចគ្នានេះដែរ អ្នកលក់នឹងមិនទទួលខុសត្រូវទេ ប្រសិនបើអ្នកទិញដឹង ឬមិនអាចមិនដឹងអំពីសិទ្ធិឬការអះអាង។ម្យ៉ាងទៀតអ្នកទិញបាត់បង់សិទ្ធិទាមទារឲ្យអ្នកលក់ទទួលខុសត្រូវ ប្រសិនបើគាត់មិនផ្តល់ការជូនដំណឹងដល់អ្នកលក់បញ្ជាក់ពីលក្ខណៈនៃសិទ្ធិ ឬបណ្តឹងទាមទាររបស់តតិយជនក្នុងពេលវេលាសមហេតុផលមួយ បន្ទាប់ពីអ្នកទិញបានដឹង ឬគួរតែដឹងអំពីសិទ្ធិ ឬការទាមទារ។ តែទោះជាយ៉ាងណាក៏អ្នកទិញអាចទាមទារកាត់បន្ថយតម្លៃ ឬសំណងការខូចខាត លើកលែងតែការបាត់បង់ប្រាក់ចំណេញ ប្រសិនបើគាត់មានហេតុផលសមរម្យចំពោះការខកខានរបស់គាត់ក្នុងការផ្តល់ជូននូវសេចក្តីជូនដំណឹង។[20]

កាតព្វកិច្ចរបស់អ្នកលក់ដើម្បីផ្តល់ទំនិញដោយរួចផុតពីសិទ្ធិ ឬការអះអាងដោយផ្អែកលើកម្មសិទ្ធិបញ្ញារបស់តតិយជន គឺត្រូវស្របទៅនឹងដែនកំណត់បីសំខាន់ៗ[21]៖

- ទីមួយអ្នកលក់ត្រូវទទួលខុសត្រូវ ប្រសិនបើសិទ្ធិ ឬការអះអាងរបស់តតិយជនគឺជាផ្នែកមួយនៃការបង្កើតកិច្ចសន្យា ដែលអ្នកលក់បានដឹង ឬមិនអាចមិនដឹង។ ឧទាហរណ៍៖អ្នកលក់ប្រមូលកម្រៃដែលមិនទាន់បង់ប្រាក់សម្រាប់ប្លាស្ទិកទូរស័ព្ទដៃ(ស្រោមទូរស័ព្ទ) អ្នកទិញបានត្អូញត្អែរ

---

[19] បណ្ឌិតសាស្ត្រាចារ្យ Indeborg Schwenzer, Christiana Fountoulaks & Mariel Dimsey "*International Sales Law: A Guide to CISG*" 2nd edition បោះពុម្ពឆ្នាំ២០១២ ទំព័រទី ៣៣៣

[20] បណ្ឌិតសាស្ត្រាចារ្យ Ingeborg Schwenzer និង Christiana Fountoulakis "*International Sales Law*" បោះពុម្ពលើកទី១ នៅទីក្រុងញូយក ដោយ ក្នុងឆ្នាំ២០០៧ ទំព័រទី ៣៤១។

[21] យោងតាម មាត្រា៤២ នៃអនុសញ្ញាCISG

ផងដែរថា ទំនិញដែលបានផ្តល់ដោយអ្នកលក់បានរំលោភលើសិទ្ធិពាណិជ្ជសញ្ញារបស់តតិយជន ហើយជាលទ្ធផល"បរិមាណដ៏ធំ"នៃទំនិញត្រូវបានរឹបអូស។ ដោយផ្អែកនៅលើមូលដ្ឋានដែលអ្នកទិញបានខកខានក្នុងការផ្តល់ការជូនដំណឹងទៅអ្នកលក់ បញ្ជាក់ពីសិទ្ធិ ឬការអះអាងរបស់តតិយជននៅក្នុងពេលវេលាសមរម្យមួយ បន្ទាប់ពីអ្នកទិញបានដឹង នោះអ្នកលក់មិនទទួលខុសត្រូវ។

- ទីពីរអ្នកលក់ត្រូវទទួលខុសត្រូវ ប្រសិនបើសិទ្ធិ ឬការអះអាងរបស់តតិយជនត្រូវបានផ្អែកលើច្បាប់របស់រដ្ឋដែលអាចអនុវត្ត និងបញ្ញត្តិដែលថាគូរភាគីបានយករដ្ឋនេះមកពិចារណានៅពេលបង្កើតកិច្ចសន្យាលក់។ បណ្តឹងរបស់តតិយជនអាចមានការអះអាងពីកម្មសិទ្ធិលើទំនិញ និងលើកម្មសិទ្ធិបញ្ញាមានដូចជា ប្រកាសនីយប័ត្រតក្កកម្ម សិទ្ធិអ្នកនិពន្ធ និងម៉ាកជាដើម។ ការប្តឹងទាមទាររបស់តតិយជនដែលមានទាក់ទងនឹងកម្មសិទ្ធិបញ្ញា លើទំនិញជាក់លាក់ណាមួយ នោះមិនអាចអនុវត្តឡើយ ប៉ុន្តែអាចអនុវត្តបានដរាបណា ការទាមទារកើតឡើងនៅក្នុងរដ្ឋដែលទំនិញនោះត្រូវបានគេលក់ ឬស្ថិតនៅក្នុងរដ្ឋដែលអ្នកទិញទំនិញមានទីតាំងអាជីវកម្មរបស់គាត់នៅទីនោះ។

- ទីបីកាតព្វកិច្ចរបស់អ្នកលក់មិនទទួលខុសត្រូវទេ ប្រសិនបើសិទ្ធិ ឬការអះអាងរបស់តតិយជនគឺជាផ្នែកមួយនៃអ្នកទិញ "បានដឹង ឬមិនអាចមិនដឹង " នៅពេលដែលកិច្ចសន្យាត្រូវបានបង្កើត ឬប្រសិនបើសិទ្ធិ ឬការអះអាងរបស់តតិយជនបានកើតឡើងពីការអនុលោមរបស់អ្នកលក់ជាមួយនឹងលក្ខណៈបច្ចេកទេស (គំនូរបច្ចេកទេស រចនា រូបមន្ត ឬលក្ខខ័ណ្ឌផ្សេងទៀត) ដែលអ្នកទិញខ្លួនឯងផ្តល់ឱ្យទៅអ្នកលក់។[22] ឧទាហរណ៍៖ អ្នកលក់បានបញ្ជូនទំនិញជាមួយនិមិត្តសញ្ញាដែលបានរំលោភលើស្លាកសញ្ញាល្បីឈ្មោះរបស់តតិយជន ប៉ុន្តែត្រូវបានរកឃើញថាអ្នកលក់មិនទទួលខុសត្រូវចំពោះអ្នកទិញទេ ដោយសារតែអ្នកទិញមិនអាចមិនបានដឹងអំពីការរំលោភ ហើយអ្នកទិញមានបញ្ជាក់ឯកសារភ្ជាប់នៃនិមិត្តសញ្ញានៅក្នុងរចនាម៉ូតដោយផ្ទាល់របស់អ្នកទិញព្រមទាំងបានផ្តល់ទៅអ្នកលក់ អ្នកទិញមានសកម្មភាពក្នុងអង្គហេតុដោយមានចំណេះដឹងពេញលេញនៃសិទ្ធិនិក្ខិត្តសញ្ញា (សិទ្ធិលើសញ្ញាផលិតកម្ម) ទាំងនោះ។ អ្នកទិញអាចមិនទទួលបានមកវិញពីអ្នកលក់ នូវការបង់ប្រាក់ដែលអ្នកទិញបានបង់ទូទាត់សំណងនៃពាណិជ្ជសញ្ញានោះទេ។

[22] យោងតាម មាត្រា៤២ នៃអនុសញ្ញាCISG

## ផ្នែកទី២ ភាតព្វកិច្ចចំពោះអ្នកទិញ

នៅក្នុងកិច្ចសន្យាលក់ទំនិញ អ្នកទិញមានកាតព្វកិច្ចចម្បងចំនួនពីរគឺ គាត់ត្រូវតែបង់ថ្លៃទំនិញទៅអោយអ្នកលក់ និង ទទួលយកការប្រគល់ទំនិញពីអ្នកលក់។[23] កាតព្វកិច្ចរបស់អ្នកទិញក៏មិនសូវខុសពីអ្នកលក់ដែរ ពោលគឺបន្ទាប់ពីកិច្ចសន្យាត្រូវបានបង្កើតហើយ អ្នកទិញត្រូវតែបំពេញកាតព្វកិច្ចជាក់លាក់មួយចំនួនដែលមានចែងនៅក្នុងកិច្ចសន្យា និងវិធានច្បាប់ដែលទាក់ទងនឹងកិច្ចសន្យាលក់ទិញទំនិញអន្តរជាតិ។ ការអនុវត្តនូវសកម្មភាពរបស់អ្នកទិញទាក់ទងនឹងកាតព្វកិច្ចអ្នកលក់ ត្រូវបានគេយកអនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីកិច្ចសន្យាលក់ទំនិញអន្តរជាតិមកប្រើនៅពេលណាដែលកិច្ចសន្យាលក់ទំនិញអន្តរជាតិមិនបានចែងពីបញ្ហាទាំងនោះ។

### កថាខណ្ឌទី១ ភាតព្វកិច្ចបង់ប្រាក់

ជាការពិតណាស់ អ្នកទិញមានកាតព្វកិច្ចក្នុងការបង់ប្រាក់ នៅពេលវេលា និងទីកន្លែងដែលមានចែងនៅក្នុងកិច្ចសន្យា។ លើសពីនេះទៀត កាតព្វកិច្ចរបស់អ្នកទិញក្នុងការបង់ថ្លៃទំនិញក៏រួមបញ្ចូលទាំងការអនុវត្តជំហាន និងការអនុវត្តតាមបែបបទដែលទាមទារនៅក្រោមលក្ខខណ្ឌនៃកិច្ចសន្យា ក៏ដូចជាច្បាប់ និងបទបញ្ញាណាមួយដើម្បីបើកការទូទាត់។ ឧទាហរណ៍៖ អ្នកទិញត្រូវតែគោរពតាមការផ្លាស់ប្តូរ ការផ្ទេរ និងការទូទាត់ណាមួយ ឬសំណើរសុំការអនុញ្ញាតផ្នែករដ្ឋបាលណាមួយដែលតម្រូវសម្រាប់ការផ្ទេរប្រាក់ រួមមាន៖ ការចេញលិខិតធានា ឬលិខិតឥណទាន។

#### ក. ទីកន្លែងនៃភាតព្វកិច្ចបង់ប្រាក់

បន្ទាប់ពីបានកំណត់តម្លៃច្បាស់លាស់ក្នុងកិច្ចសន្យា អ្នកលក់មានកាតព្វកិច្ចបង់ប្រាក់នៅកន្លែងដែលកំណត់ក្នុងកិច្ចសន្យា ប៉ុន្តែប្រសិនបើមិនបានកំណត់ទីកន្លែងនៃការបង់ប្រាក់ត្រូវអនុវត្តតាមមាត្រា៥៧នៃអនុសញ្ញាCISGដែលមានដូចជា ៖

- ទីមួយអ្នកទិញអាចបង់ប្រាក់នៅកន្លែងអ្នកលក់
- ទីពីរករណីមិនមានការបញ្ជាក់ ឬជម្រើសជាក់លាក់ អ្នកទិញត្រូវតែបង់ថ្លៃនៅកន្លែងដែលប្រគល់ទំនិញ ឬឯកសារ ដូចនេះនាំឲ្យមានការប្រគល់ទំនិញ និងបង់ថ្លៃក្នុងពេលដំណាលគ្នានៅកន្លែងរបស់អ្នកទិញ។

[23] យោងតាម មាត្រា៥៣ នៃអនុសញ្ញាCISG

ប៉ុន្តែប្រសិនបើកន្លែងដែលភាគីមិនបានយល់ស្របលើទីកន្លែងបង់ប្រាក់ និងការទូទាត់មិនត្រូវបានធ្វើឡើងជំណាលគ្នានឹងការប្រគល់ទំនិញ ឬឯកសារ អ្នកទិញត្រូវតែបង់តម្លៃនៅទីកន្លែងធ្វើអាជីវកម្មរបស់អ្នកលក់ ឬប្រសិនបើអ្នកលក់ត្រូវតែអនុវត្តកាតព្វកិច្ចទាំងអស់ ឬផ្នែកនៃកាតព្វកិច្ចរបស់ខ្លួន មុនពេលតម្រូវឱ្យអ្នកទិញបង់ថ្លៃជាក្រោយនៅកន្លែងអ្នកទិញ។

ក្រោយពីបង្កើតកិច្ចសន្យាអ្នកលក់ផ្លាស់ប្តូរទីតាំងអាជីវកម្មរបស់ខ្លួន ការបង្កើនឡើងលើការចំណាយណាមួយដោយចៃដន្យចំពោះការទូទាត់បង់ថ្លៃទៅអាស័យដ្ឋានថ្មីរបស់អ្នកលក់ដោយអ្នកទិញ អ្នកលក់ត្រូវទទួលបន្ទុក។ អ្នកលក់ត្រូវជូនដំណឹងទៅអ្នកទិញឱ្យបានត្រឹមត្រូវនៃការផ្លាស់ប្តូរទីតាំងអាជីវកម្មរបស់ខ្លួនក្នុងពេលវេលាសមរម្យមួយ។ អ្នកលក់មិនអាចពឹងផ្អែកលើការពន្យាពេលក្នុងការទូទាត់តម្លៃ ដែលមានបណ្តាលមកពីការជូនដំណឹងយឺតយ៉ាវនៃការផ្លាស់ប្តូរអាស័យដ្ឋានរបស់ខ្លួនទេ។[24]

ក្នុងករណីកិច្ចសន្យាទាក់ទងនឹងការដឹកជញ្ជូនទំនិញ អ្នកលក់ជាទូទៅនឹងអនុវត្តកាតព្វកិច្ចប្រគល់ទំនិញមុនពេលអ្នកទិញបង់ថ្លៃ។ កាតព្វកិច្ចត្រូវផ្តល់មានការប្រគល់ទំនិញទៅក្រុមហ៊ុនដឹកជញ្ជូនលើកដំបូងសម្រាប់ការបញ្ជូនដល់អ្នកទិញ ចំណែកឯអ្នកទិញមិនបានតម្រូវឱ្យបង់ថ្លៃរហូតដល់ពេលដែលអ្នកលក់ដាក់ទំនិញ ឬឯកសាររបស់ខ្លួននៅកន្លែងរបស់អ្នកទិញ។ ទោះជាយ៉ាងណាក៏ដោយ អ្នកលក់អាចមិនបញ្ជូនទំនិញទៅតាមលក្ខខណ្ឌនៃទំនិញ ឬឯកសារ ទៅឱ្យអ្នកទិញលើកលែងតែមានការទូទាត់តម្លៃត្រូវបានបំពេញ។[25] ចំពោះការកំណត់ទីកន្លែងបង់ប្រាក់អាចមានផលវិបាកសំខាន់ៗចំនួនបួនចំពោះអ្នកទិញដូចជា[26]៖

- ទីមួយគាត់ត្រូវចាប់ផ្តើមការទូទាត់ឱ្យបានឆាប់រហ័សរហូតដល់បរិច្ឆេទនៃការថ្ងៃទូទាត់តម្លៃនៅកន្លែងបង់ប្រាក់។ ដូច្នេះគាត់អាចមានហានិភ័យនៃការពន្យារពេល។

- ទីពីរគាត់ត្រូវតែចាត់វិធានការទាំងអស់ និងអនុវត្តតាមបែបបទទាំងអស់នៅកម្រិតពាណិជ្ជកម្ម និងទៅអាជ្ញាធរ ដើម្បីឱ្យការទូទាត់អាចត្រូវបានធ្វើឡើងនៅកន្លែងបង់ប្រាក់។

- ទីបីគាត់ត្រូវទទួលខុសត្រូវចំពោះតម្លៃនៃនីតិវិធីនៃការទូទាត់រហូតមកដល់កន្លែងនៃការទូទាត់ប្រាក់សំរាប់អ្នកលក់។

[24] យោងតាម កថាខណ្ឌ៩ នៃអត្ថបទសង្ខេបនៃរឿងក្តីនៃអនុសញ្ញាCISG ឆ្នាំ២០១៦ ទំព័រទី២៦៦
[25] យោងតាម កថាខណ្ឌ៧ នៃអត្ថបទដដែល ទំព័រទី២៦៦
[26] យោងតាម មាត្រា៥៧ នៃអនុសញ្ញាCISG

- ទីបួនគាត់ក៏អាចមានគ្រោះថ្នាក់នៅពេលការទូទាត់ដែលបានផ្តួចផ្តើម នីតិវិធីមានការខកខានដោយសារតែភាពក្ស័យធននៃធនាគារដែលពាក់ព័ន្ធ ដូចនេះអ្នកទិញត្រូវធ្វើម្តងហើយម្តងទៀតដើម្បីបំពេញលក្ខខណ្ឌនៅក្នុងកិច្ចសន្យា។

**ខ. ពេលវេលានៃកាតព្វកិច្ចបង់ប្រាក់**

កាតព្វកិច្ចបង់ប្រាក់ជាទូទៅសំខាន់បំផុតគឺទីកន្លែង និងពេលវេលានៃការបង់ប្រាក់ ដូចនេះអ្នកទិញមានកាតព្វកិច្ចអនុវត្តតាមការកំណត់ក្នុងកិច្ចសន្យា។ ប៉ុន្តែក្នុងករណីមិនបានបញ្ជាក់ក្នុងកិច្ចព្រមព្រៀងណាមួយទេ ការប្រគល់ទំនិញ ឬឯកសារ និងការទូទាត់តម្លៃត្រូវធ្វើឡើងតំណាលគ្នាដោយអ្នកទិញត្រូវតែបង់ថ្លៃនៅពេលអ្នកលក់ប្រគល់ទំនិញ ឬឯកសារ។ [27]

ប្រសិនបើអ្នកលក់ត្រូវផ្តល់ទំនិញនៅកន្លែងលក់របស់អ្នកទិញ ឬកន្លែងណាមួយ ថ្លៃទំនិញត្រូវបានបង់នៅពេលទំនិញបានដាក់នៅទីកន្លែងរបស់អ្នកទិញ ឬនៅកន្លែងណាមួយផ្សេងដែលបានព្រមព្រៀង។ ចំណែកការលក់ពាក់ព័ន្ធនឹងការដឹកជញ្ជូនទំនិញ អ្នកលក់ត្រូវបំពេញនូវកាតព្វកិច្ចរបស់ខ្លួនក្នុងការចែកចាយទំនិញដោយប្រគល់ទំនិញទៅឲ្យក្រុមហ៊ុនដឹកជញ្ជូនលើកដំបូងសម្រាប់ការបញ្ជូនទៅឱ្យអ្នកទិញ ហើយអ្នកទិញមានកាតព្វកិច្ចបង់ថ្លៃនៅពេលដែលអ្នកលក់ប្រគល់ទាំងទំនិញ ឬឯកសារនៅកន្លែងរបស់អ្នកទិញដោយក្រុមហ៊ុនដឹកជញ្ជូនចុងក្រោយ។ អ្នកលក់គឺមិនមានសិទ្ធិប្រគល់ការដឹកទំនិញដល់ក្រុមហ៊ុនដឹកជញ្ជូនដំបូងទេ ក្នុងលក្ខខណ្ឌនៃការទូទាត់តម្លៃជាមុនដោយអ្នកទិញ។ អ្នកលក់មានសិទ្ធិរក្សាទុកទំនិញរហូតដល់អ្នកទិញបានបង់ថ្លៃ ហើយអ្នកលក់អនុវត្តសិទ្ធិដោយទាមទារឲ្យអ្នកទិញមានឱកាសពិនិត្យទំនិញ។[28]

ក្នុងករណីកំណត់ក្នុងកិច្ចសន្យា តម្លៃលក់ត្រូវបង់ដោយស្វ័យប្រវត្តិនៅកាលបរិច្ឆេទក្នុងកិច្ចសន្យា ពីព្រោះវាធូរស្រាលដល់អ្នកលក់នៃតម្រូវការចេញសេចក្តីជូនដំណឹង ឬអនុវត្តតាមបែបបទផ្សេងទៀតដូចជាផ្ញើវិក្កយបត្រជាមុនទៅអ្នកទិញឱ្យបង់ប្រាក់។ តម្លៃមិនត្រូវបង់ដោយស្វ័យប្រវត្តិទេប្រសិនបើនៅកាលបរិច្ឆេទ អ្នកទិញមិនដឹងពីចំនួនទឹកប្រាក់ពិតប្រាកដនៃតម្លៃដែលត្រូវបង់។[29] ការខកខានរបស់អ្នកទិញក្នុងការទូទាត់តម្លៃតាមកាលបរិច្ឆេទកំណត់ អ្នកលក់ត្រូវងាកទៅរកដំណោះស្រាយជាច្រើនទាក់ទងទៅនឹងការរំលោភកិច្ចសន្យាដោយអ្នកទិញក្នុងអនុសញ្ញាCISG។

[27] យោងតាម មាត្រា៥៨ នៃកថាខណ្ឌទី១ នៃអនុសញ្ញាCISG

[28] យោងតាម កថាខណ្ឌ៩ នៃអត្ថបទសង្ខេបនៃរឿងក្តីនៃអនុសញ្ញាCISG ឆ្នាំ២០១៦ ទំព័រទី២៧២

[29] យោងតាម កថាខណ្ឌ៣ នៃអត្ថបទសង្ខេបដដែល ទំព័រទី២៧៦

## កថាខណ្ឌទី២ ការទទួលយកការបញ្ជូនទំនិញ

កាតព្វកិច្ចរបស់អ្នកលក់គឺការប្រគល់ទំនិញ និងឯកសារ ចំណែកកាតព្វកិច្ចរបស់អ្នកទិញគឺការទទួលយកការដឹកជញ្ជូនទំនិញ និងឯកសារដែលជាមូលដ្ឋានមួយក្នុងចំណោមមូលដ្ឋានពីរនៃកាតព្វកិច្ចរបស់អ្នកទិញ។ អ្នកទិញមានកាតព្វកិច្ចសហការក្នុងការទទួលយកការដឹកជញ្ជូនពីអ្នកលក់ដូចដែរបានកំណត់នៅក្នុងកិច្ចសន្យា។ អ្នកទិញដែលមិនសហការក្នុងការអនុវត្តនូវកាតព្វកិច្ចរបស់ខ្លួនទេ ត្រូវទទួលខុសត្រូវចំពោះការខូចខាតទាំងឡាយដែលកើតមានឡើង និងប្រសិនបើអ្នកទិញខកខានក្នុងការកាន់កាប់ នៅពេលដែលទំនិញត្រូវបានបញ្ជូនដោយអ្នកលក់ នោះអ្នកលក់ត្រូវបានគេតម្រូវឱ្យយកចិត្តទុកដាក់ចំពោះទំនិញរហូតដល់អ្នកទិញទទួលយកការដឹកជញ្ជូន។ អ្នកទិញត្រូវទទួលខុសត្រូវក្នុងការបង់ប្រាក់ទៅដល់អ្នកលក់សម្រាប់ការចំណាយសមហេតុផលទាំងអស់ដែលទាក់ទងនឹងការថែរក្សា។[30] ការទទួលយកការបញ្ជូនទំនិញនេះគឺរួមបញ្ចូលទាំងការត្រួតពិនិត្យទំនិញ ការជូនដំណឹងពីវិការៈ និងការបដិសេដការទទួលយកទំនិញ។

### ក. ការត្រួតពិនិត្យទំនិញ

បន្ទាប់ពីទទួលយកការដឹកជញ្ជូន ឬមុនពេលការដឹកជញ្ជូនទំនិញ អ្នកទិញមានសិទ្ធិធ្វើការពិនិត្យទំនិញដែលអ្នកលក់បានបញ្ជូនមក ឬមុនពេលបញ្ជូនមក ក្នុងគោលដៅដើម្បីស្វែងរកនូវការខូចខាត ឬការបាត់បង់ផ្សេងៗ ឬការមិនអនុលោមនៃទំនិញ ប្រសិនបើមាន។[31] អ្នកទិញអាចពិនិត្យទំនិញក្នុងរយៈពេលខ្លី ត្រួតពិនិត្យជាសង្ខេប និងត្រួតពិនិត្យស៊ើៗនៃទំនិញបន្ទាប់ពីទទួលយកការបញ្ជូនទំនិញ ឬមុនពេលដឹកជញ្ជូន។

ប្រសិនបើទំនិញត្រូវបានដឹកជញ្ជូនតាមកាប៉ាល់ ឬការដឹកជញ្ជូនផ្សេងទៀត អ្នកទិញអាចពន្យាពេលក្នុងការត្រួតពិនិត្យរហូតទាល់តែទំនិញនោះទៅដល់ទិសដៅ។ ក្នុងករណីអ្នកទិញធ្វើការបង្គាប់អោយបញ្ជូនទំនិញបន្តចេញពីតំបន់ឆ្លងកាត់ ហើយអ្នកទិញគ្មានឱកាសសមរម្យសម្រាប់ការត្រួតពិនិត្យដោយខ្លួនគាត់ និងនៅពេលបង្កើតកិច្ចសន្យាអ្នកលក់ដឹង ឬគួរតែដឹងពីលទ្ធភាពនៃការបញ្ជូនបន្ត ហើយពន្យាពេលក្នុងការត្រួតពិនិត្យរហូតទាល់តែទំនិញនោះបានបញ្ជូនទៅដល់គោលដៅថ្មីរួចរាល់សិន ទើបអ្នកទិញអាចត្រួតពិនិត្យ ដូចនេះអ្នកលក់ទទួលខុសត្រូវរាល់កង្វះអនុលោមភាពនៃទំនិញ។ អ្នកលក់មិនទទួលខុសត្រូវឡើយ ប្រសិនបើអ្នកទិញមិនបានអនុវត្តការ

[30] យោងតាម មាត្រា៨៥ និង មាត្រា៨៧ នៃអនុសញ្ញា CISG

[31] យោងតាម មាត្រា៣៨ នៃអនុសញ្ញាដដែល

ត្រួតពិនិត្យ និងករណីដែលអ្នកទិញមិនអាចអះអាងពីហេតុផលសមរម្យក្នុងការមិនត្រួតពិនិត្យទំនិញ។

យោងតាមបទប្បញ្ញត្តិទូទៅអ្នកទិញត្រូវតែត្រួតពិនិត្យទំនិញ ដែលអាចធ្វើទៅបានក្រោមកាលៈទេសៈ ប្រសិនបើរកឃើញកំហុសឆ្គងត្រូវជូនដំណឹងដល់អ្នកលក់ឱ្យបានច្បាស់លាស់ក្នុងរយៈពេលសមហេតុផលដោយបញ្ជាក់ពីប្រភេទនៃកង្វះខាត។ អ្នកទិញមិនបាត់បង់សិទ្ធិក្នុងការពឹងផ្អែកលើកង្វះអនុលោមភាពនៃទំនិញ ដរាបណាភាពមិនត្រឹមត្រូវបានជូនដំណឹង (ទៅអ្នកលក់) ក្នុងលក្ខណៈទាន់ពេលវេលា។

### ខ. ការជូនដំណឹងពីវិការៈ និងការបដិសេធការទទួលយកទំនិញ

ការទទួលយកការដឹកជញ្ជូនមិនមានផលប៉ះពាល់ដល់សិទ្ធិរបស់អ្នកទិញក្នុងការផ្តល់សេចក្តីជូនដំណឹងពីកង្វះនៃអនុលោមភាពនៅក្នុងទំនិញ ឬឯកសារ ឬងាកទៅរកដំណោះស្រាយសម្រាប់អ្នកលក់ក្នុងការដឹកជញ្ជូនយឺត ឬការដឹកជញ្ជូននៅកន្លែងដែលមិនសមស្រប។[32] ចំណែកការមិនទទួលយកការដឹកជញ្ជូនទំនិញក៏មិនប៉ះពាល់ដល់ការជូនដំណឹងពីការបដិសេធរបស់អ្នកទិញក្នុងករណីដែលអ្នកលក់ផ្តល់នូវទំនិញច្រើនពេកដូចគ្នា។

#### ១. ការជូនដំណឹងពីវិការៈ

បន្ទាប់ពីអ្នកទិញទទួលយកទំនិញ និងត្រួតពិនិត្យរួចរាល់ ប្រសិនបើរកឃើញថាមានទំនិញមិនអនុលោមតាមកិច្ចសន្យាត្រូវផ្តល់ដំណឹងទៅអ្នកលក់ក្នុងរយៈពេលសមរម្យមួយ។ ក្នុងករណីដែលអ្នកទិញមិនបានជូនដំណឹងទៅអ្នកលក់ពីលក្ខណៈនៃការខ្វះខាតអនុលោមភាពនៃទំនិញតាមកិច្ចសន្យាក្នុងរយៈពេលសមស្របបន្ទាប់ពីអ្នកទិញមានបានរកឃើញ នោះអ្នកលក់ត្រូវបានចាត់ទុកថាបានអនុលោមតាមកិច្ចសន្យាហើយ ដូច្នេះអ្នកលក់មិនទទួលខុសត្រូវនូវការខូចខាតទេ ចំណែកអ្នកទិញក៏បានបាត់បង់សិទ្ធិក្នុងការពឹងផ្អែកលើកង្វះអនុលោមភាពនៃទំនិញ។[33] ប៉ុន្តែអ្នកលក់នឹងត្រូវតែទទួលខុសត្រូវ ប្រសិនបើអ្នកទិញមានហេតុផលសមរម្យចំពោះការខកខានក្នុងការផ្តល់ជូននូវ

[32] យោងតាម កថាខណ្ឌ៨ នៃអត្ថបទសង្ខេបនៃរឿងនៃអនុសញ្ញាCISG ឆ្នាំ២០១៦ ទំព័រទី២៨០

[33] យោងតាម មាត្រា៣៩ នៃអនុសញ្ញា CISG

សេចក្តីជូនដំណឹង ហើយអ្នកទិញអាចកាត់បន្ថយតម្លៃ ឬទាមទារសំណងការខូចខាត លើកលែងតែការបាត់បង់ប្រាក់ចំណេញ ។[34]

ចំពោះទម្រង់នៃការជូនដំណឹងពីការមិនអនុលោមតាមកិច្ចសន្យា ភាគីទាំងអស់មានសេរីភាពក្នុងការឯកភាពគ្នាលើទំរង់ណាមួយជាក់លាក់ ប្រសិនបើភាគីទាំងពីរចង់ប្រើប្រាស់នូវទម្រង់ណាមួយ។[35] ម្យ៉ាងទៀត ប្រសិនបើអ្នកទិញមិនបានផ្តល់ការជូនដំណឹងពីការមិនអនុលោមទំនិញដល់អ្នកលក់ យ៉ាងយូរក្នុងរយៈពេលពីរឆ្នាំចាប់ពីកាលបរិច្ឆេទដែលទំនិញត្រូវបានប្រគល់ទៅឱ្យអ្នកទិញ និងស្របជាមួយកិច្ចសន្យាធានាទំនិញ អ្នកលក់ត្រូវទទួលខុសត្រូវ។ ប៉ុន្តែប្រសិនបើរយៈពេលនៃការជូនដំណឹង មិនស្របជាមួយរយៈពេលនៃកិច្ចសន្យាធានាទំនិញ ដោយកិច្ចសន្យាធានាទំនិញមានរយៈពេលខ្លីជាងនោះ អ្នកលក់មិនទទួលខុសត្រូវទេ ចំណែកអ្នកទិញក៏បាត់បង់សិទ្ធិក្នុងការពឹងផ្អែកលើកង្វះអនុលោមភាពនៃទំនិញដែរ។

ការកំណត់រយៈពេលមិនមានបញ្ហាទេ ក្នុងករណីរយៈពេលដែលកំណត់ដោយច្បាប់ជាតិលើសពីដែនកំណត់រយៈពេលពីរឆ្នាំនៅក្រោមអនុសញ្ញាCISG។ ប៉ុន្តែអាចជាមានបញ្ហាក្នុងករណីដែលរយៈពេលកំណត់ក្នុងច្បាប់ជាតិមានរយៈពេលខ្លីជាងរយៈពេលពីរឆ្នាំសម្រាប់ការផ្តល់សេចក្តីជូនដំណឹងពីកង្វះអនុលោមភាព ឧទាហរណ៍៖ នៅក្រោមច្បាប់របស់ប្រទេសស្វ៊ីសកំណត់រយៈពេលនៃការជូនដំណឹងគឺមួយឆ្នាំ។[36] ដូច្នេះត្រូវអនុវត្តរយៈពេលពីរឆ្នាំដែលអនុសញ្ញាCISGបានកំណត់។

### ២. ការបដិសេធការទទួលយកទំនិញ

ករណីអ្នកលក់ផ្តល់ទំនិញឆាប់ពេក ឬការដឹកជញ្ជូនមុនពេលកំណត់ ប្រសិនបើកិច្ចសន្យាចែងពីកាលបរិច្ឆេទជាក់លាក់ ឬរយៈពេល ឬក្នុងកំឡុងពេលចែកចាយណាមួយត្រូវបានអនុវត្តអ្នកទិញមានសិទ្ធិត្រឹមត្រូវក្នុងការបដិសេធទំនិញដោយសារតែការដឹកជញ្ជូនមុនពេល អ្នកលក់ត្រូវតែផ្តល់ទំនិញឡើងវិញនៅពេលត្រឹមត្រូវ ប៉ុន្តែប្រសិនបើអ្នកទិញទទួលយកទំនិញដែលបានប្រគល់មុនពេល អ្នកទិញត្រូវមានកាតព្វកិច្ចបង់ថ្លៃតាមកិច្ចសន្យា បទបញ្ញត្តិទាក់ទងនឹងការដឹកជញ្ជូនមុនពេល ក៏ត្រូវបានអនុវត្តផងដែរប្រសិនបើឯកសារពាក់ព័ន្ធនឹងទំនិញត្រូវបានផ្តល់ជូនមុន។

[34] បណ្ឌិតសាស្ត្រាចារ្យ Ingeborg Schwenzer, Christiana Fountoulakis & Mariel Dimsey *"International Sales Law: A Guide to CISG"* បោះពុម្ពលើកទី២ ក្នុងឆ្នាំ២០១២ ទំព័រទី ៣៩១

[35] យោងតាម សៀវភៅដដែល បោះពុម្ពលើកទី១ នៅទីក្រុងញូយក ដោយRouledge-Cavendish ឆ្នាំ២០០៧ ទំព័រទី ៣២៣

[36] យោងតាម សៀវភៅដដែល បោះពុម្ពលើកទី១ ឆ្នាំ២០០៧ ទំព័រទី ៣២៤

(ឧទាហរណ៍៖ ការដឹកជញ្ជូនក្នុងអំឡុងពេលសប្តាហ៍ទី២៣ នៃឆ្នាំ ឬការដឹកជញ្ជូនរហូតដល់ថ្ងៃទី០១ ខែកញ្ញា)។

ចំពោះបញ្ជូនទំនិញច្រើនពេក អ្នកទិញមានសិទ្ធិបដិសេធក្នុងការទទួលយកការដឹកជញ្ជូនទំនិញច្រើនជាងការកំណត់ក្នុងកិច្ចសន្យា និងត្រូវជូនដំណឹងអំពីបរិមាណមិនត្រឹមត្រូវទៅអ្នកលក់។ បន្ទាប់ពីការបដិសេធត្រឹមត្រូវក្នុងការយកបរិមាណលើសនេះ អ្នកទិញត្រូវតែរក្សាទុកនូវទំនិញដែលហួស។ ប្រសិនបើអ្នកទិញទទួលយកបរិមាណទំនិញច្រើនជាងបរិមាណដែលមានក្នុងកិច្ចសន្យា អ្នកទិញត្រូវបានកំណត់ឱ្យបង់ថ្លៃកិច្ចសន្យាសម្រាប់បរិមាណលើសនោះ។ ប្រសិនបើការប្រគល់ទំនិញលើសបរិមាណ និងប្រសិនបើអ្នកទិញមិនអាចរំលាយកិច្ចសន្យា និងត្រូវតែយកការដឹកជញ្ជូនលើសអ្នកទិញត្រូវបង់លុយឱ្យអ្នកលក់ ប៉ុន្តែត្រូវជូនដំណឹងដល់អ្នកលក់ ហើយអាចទាមទារសំណងការខូចខាតណាមួយដែលគាត់ទទួលរងពីការរំលោភបំពាននេះ។

## ផ្នែកទី៣ ការទទួលខុសត្រូវចំពោះហានិភ័យ

ក្នុងកិច្ចសន្យាបានចងនូវកាតព្វកិច្ចរបស់ភាគី ដើម្បីទទួលខុសត្រូវរាល់ហានិភ័យណាមួយដែរកើតមានឡើងដូចជា៖ គុណភាព បរិមាណ ការពិពណ៌នា និងការវេចខ្ចប់នូវទំនិញ និងរួមទាំងការដឹកជញ្ជូនទំនិញទៅឲ្យភាគីមួយទៀតក្នុងកិច្ចសន្យា។ ការទទួលខុសត្រូវចំពោះហានិភ័យរួមមានភាគីក្នុងកិច្ចសន្យា និងតតិយជន ដែរធ្វើឲ្យខូចខាតនូវផលប្រយោជន៍ណាមួយពីការរំពឹងទុក ។ករណីផ្លាស់ប្តូរទីកន្លែងនាំឲ្យការដឹកជញ្ជូនមានហានិភ័យកើតឡើង ភាគីដែរផ្លាស់ប្តូរទីតាំងនៃការអនុវត្ត និងបានបង្កើនហានិភ័យនៃការដឹកជញ្ជូនត្រូវទទួលខុសត្រូវចំពោះហានិភ័យនោះ។

### កថាខណ្ឌទី១ ការទទួលខុសត្រូវចំពោះហានិភ័យពីអំពើរបស់គូរភាគី និង អំពើរបស់តតិយជន

ភាគីនៃកិច្ចសន្យាមានកាតព្វកិច្ចអនុវត្តតាមការព្រមព្រៀង ប៉ុន្តែប្រសិនបើមានភាគីណាមួយបានរំលោភបំពានលើកិច្ចសន្យាដោយសារការធ្វេសប្រហែស ឬកង្វះនូវចំណេះដឹង ភាគីនោះត្រូវទទួលខុសត្រូវនូវសកម្មភាពនៃការរំលោភបំពាន។ មិនត្រឹមតែប៉ុណ្ណោះ ប្រសិនបើការខូចខាតកើតឡើងដោយសារសកម្មភាពរបស់តតិយជន នោះតតិយជនក៏ត្រូវតែទទួលខុសត្រូវដូចគ្នា។

**ក. ករណីមានអំពើរបស់គូរភាគី**

ការខូចខាតដល់ទំនិញរួមមានដូចជា៖ ការបំផ្លិចបំផ្លាញទាំងស្រុង ការខូចខាតខាងរូបរាង ការខ្សោះជីវជាតិ និងការថយចុះនៃទំនិញក្នុងអំឡុងពេលដឹកជញ្ជូន ឬការផ្ទុកនូវទំនិញដោយការធ្វេសប្រហែស ឬដោយកង្វះចំណេះដឹងរបស់ភាគីណាមួយ។

ប្រសិនបើទំនិញបានបាត់បង់ ឬខូចខាតមុនពេលហានិភ័យផ្ទេរ ឬការដឹកជញ្ជូនទំនិញឆ្លងទៅអ្នកទិញ អ្នកទិញមិនត្រូវធ្វេសប្រហែសពីកាតព្វកិច្ចបង់ថ្លៃ ចំណែកក៏អ្នកលក់ត្រូវទទួលខុសត្រូវចំពោះការបាត់បង់ ឬការខូចខាត ដោយសារអ្នកលក់រំលោភកាតព្វកិច្ចក្នុងការផ្តល់ទំនិញអនុលោមតាមកិច្ចសន្យា។ កាតព្វកិច្ចបង់ថ្លៃរបស់អ្នកទិញអាចនឹងត្រូវរំសាយ ប្រសិនបើអ្នកទិញរំលាយកិច្ចសន្យា ឬតម្លៃអាចត្រូវបានកាត់បន្ថយ។ ម្យ៉ាងវិញទៀតករណីដែលអ្នកទិញអាចរកភស្តុតាងបញ្ជាក់ពីហានិភ័យបានកើតឡើងមុនពេលការទទួលយកទំនិញ និងការខូចខាតមិនបណ្តាលមកពីសកម្មភាពរបស់អ្នកទិញទេ អ្នកទិញមិនមានកាតព្វកិច្ចត្រូវបង់ថ្លៃទំនិញដែលបាត់បង់ ឬខូចខាត។

វិធានដាច់ដោយឡែកសម្រាប់ពីរស្ថានភាពផ្សេងៗគ្នាដែលគ្រប់គ្រងពេលវេលាដែលហានិភ័យនៃការបាត់បង់ ឬការខូចខាតផ្ទេរទៅឲ្យអ្នកទិញមានដូចជា[37] ៖

- ទីមួយប្រសិនបើកិច្ចសន្យាលក់ពាក់ព័ន្ធ នឹងការដឹកជញ្ជូនទំនិញ ហើយអ្នកលក់មិនត្រូវបានចងភ្ជាប់ឲ្យប្រគល់ទំនិញទៅឱ្យក្រុមហ៊ុនដឹកជញ្ជូនណាមួយនៅកន្លែងជាក់លាក់ ជាទូទៅហានិភ័យបញ្ជូនទៅអ្នកទិញ នៅពេលអ្នកលក់ប្រគល់ទំនិញទៅក្រុមហ៊ុនដឹកជញ្ជូនដំបូង។ កិច្ចសន្យាអាចបញ្ជាក់យ៉ាងច្បាស់ថាទំនិញត្រូវបានដឹកជញ្ជូនតាមរយៈក្រុមហ៊ុនដឹកជញ្ជូន ដោយរាប់បញ្ចូលទាំងព័ត៌មានលម្អិត និងគោរពតាមលក្ខណៈនៃការដឹកជញ្ជូន។ កិច្ចសន្យាដែលផ្តល់សម្រាប់ការដឹកជញ្ជូន (ដោយឥតគិតថ្លៃ) គឺនៅតែជាកិច្ចសន្យាទាក់ទងនឹងការដឹកជញ្ជូនដោយសារតែអ្នកទិញបានទិញទំនិញភ្ជាប់ជាមួយការដឹកជញ្ជូន ចំណែកអ្នកលក់ត្រូវបានគិតថ្លៃទំនិញរួមបញ្ចូលសម្រាប់ការដឹកជញ្ជូន។ អ្នកលក់ត្រូវបានអនុញ្ញាតឱ្យរក្សាទុកឯកសារដែលគ្រប់គ្រងការកំណត់ទំនិញដោយមិនប៉ះពាល់ដល់ការឆ្លងនៃហានិភ័យនោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ ហានិភ័យនឹងមិនហុចដល់អ្នកទិញទេ រហូតដល់ទំនិញត្រូវបានកំណត់យ៉ាង

[37] យោងតាម មាត្រា៦៧ នៃអនុសញ្ញាCISG

ច្បាស់លាស់ក្នុងកិច្ចសន្យា ដោយសញ្ញាណសម្គាល់លើទំនិញ ឬដោយឯកសារដឹកជញ្ជូន ឬតាមការជូនដំណឹងដែលបានផ្តល់ឱ្យអ្នកទិញ ឬផ្សេងពីនេះ។

- ទីពីរប្រសិនបើអ្នកលក់ត្រូវបានចងភ្ជាប់ពីទីកន្លែងធ្វើពាណិជ្ជកម្មគឺជាដីគោកដើម្បីបញ្ជូនទំនិញពីកំពង់ផែ នោះអ្នកលក់ត្រូវបញ្ជូនតាមការកំណត់ក្នុងកិច្ចសន្យា ហើយហានិភ័យអាចផ្ទេរនៅពេលដែលសកម្មភាពនៃការដឹកជញ្ជូនទំនិញត្រូវបានបំពេញ។ ប្រសិនបើអ្នកលក់មិនភ្ជាប់នូវកាតព្វកិច្ចដឹកជញ្ជូនទេ ចំណែកអ្នកទិញមកទទួលយកទំនិញដោយខ្លួនឯង នោះហានិភ័យត្រូវបានឆ្លងទៅអ្នកទិញនៅពេលដែលអ្នកទិញទទួលយកទំនិញនៅទីកន្លែងធ្វើអាជីវកម្មរបស់អ្នកលក់ អ្នកលក់ត្រូវទទួលខុសត្រូវប្រសិនបើអ្នកទិញផ្តល់ដំណឹងទាន់ពេល។

ការខូចខាតដែលបង្កឡើងដោយការផ្ទុកមិនត្រឹមត្រូវដោយអ្នកលក់ទៅឡានមួយដែលបានរៀបចំដោយអ្នកទិញ ហានិភ័យមិនផ្ទេរនៅពេលដែលទំនិញត្រូវបានបញ្ជូនទៅក្រុមហ៊ុនដឹកជញ្ជូនទេ តែមកពីសកម្មភាពរបស់អ្នកលក់នៃផ្ទុកទំនិញមិនត្រឹមត្រូវ។ ប្រសិនបើអ្នកលក់ខកខានក្នុងការបង្ហាញពីធនាគារដែលចេញលិខិតឥណទានសម្រាប់ការទូទាត់ក្នុងរយៈពេលដែលមានចែងនៅក្នុងកិច្ចសន្យានៅលើវិក័យប័ត្រដាក់លក់ទៅអ្នកទិញ នោះអ្នកទិញមិនអាចធ្វើការទូទាត់ឲ្យទាន់ពេលវេលាបានទេ អ្នកលក់មានបន្ទុកបង្ហាញភស្តុតាងសម្រាប់ការប្រគល់ទំនិញ និងផ្តល់នូវរយៈពេលបន្ថែមនៃការអនុវត្តកាតព្វកិច្ចបង់ថ្លៃទៅអ្នកទិញ។

ហានិភ័យអាចផ្ទេរពេលដែលកិច្ចសន្យាលក់ត្រូវបានបង្កើត កាលៈទេសៈនេះបង្ហាញថាហានិភ័យត្រូវបានចាត់ទុកថា បានផ្ទេរទៅនៅពេលដែលទំនិញត្រូវបានប្រគល់ទៅឱ្យក្រុមហ៊ុនដឹកជញ្ជូន។ បើសិនជាអ្នកលក់ដឹង ឬក៏គួរតែបានដឹងថាទំនិញត្រូវបានបាត់បង់ ឬខូចខាតនៅពេលដែលកិច្ចសន្យាត្រូវបានបង្កើត ហើយមិនបានប្រាប់ ឬផ្តល់ព័ត៌មានដល់អ្នកទិញ នោះហានិភ័យនៅតែមានចំពោះអ្នកលក់។[38] ហានិភ័យនឹងធ្លាក់ទៅអ្នកទិញនៅពេលគាត់ទទួលយកទំនិញ ឬប្រសិនបើអ្នកទិញមិនទទួលយកទំនិញតាមពេលកំណត់ ប៉ុន្តែទំនិញត្រូវបានទុកនៅកន្លែងគាត់ ហើយគាត់ក៏រំលោភបំពានកិច្ចសន្យាដោយការមិនទទួលយកការដឹកជញ្ជូនទំនិញនោះ ដូចនេះអ្នកទិញត្រូវទទួលខុសត្រូវទទួលយកទំនិញ។[39] ប្រសិនបើអ្នកទិញត្រូវទទួលយកទំនិញនៅកន្លែងណាមួយក្រៅពីកន្លែងធ្វើពាណិជ្ជកម្មរបស់អ្នកលក់ នោះហានិភ័យនឹងកើតឡើងនៅពេល

[38] យោងតាម មាត្រា៦៨ នៃអនុសញ្ញាCISG

[39] យោងតាម មាត្រា៦៩ នៃអនុសញ្ញាដដែល

ការដឹកជញ្ជូនមកដល់ទីកន្លែងដែលកំណត់ ដោយអ្នកទិញដឹងពីថាទំនិញនឹងត្រូវបានដាក់នៅទីកន្លែងរបស់គាត់។[40]

ករណីអ្នកទិញរៀបចំការដឹកជញ្ជូនទំនិញជាបន្តបន្ទាប់ដោយក្រុមហ៊ុនដឹកជញ្ជូនរបស់តតិយជន ដើម្បីដឹកទំនិញជៀសវាងមានហានិភ័យកើតឡើង ការប្រើប្រាស់របស់អ្នកទិញនៃក្រុមហ៊ុនដឹកជញ្ជូនដើម្បីទទួលយកទំនិញ មិនបានការពារការផ្ទេរហានិភ័យដែរកើតឡើងមានមុនពេលដឹកជញ្ជូនឲ្យអ្នកទិញទេ។

### ខ. ករណីមានអំពើរបស់តតិយជន

ចំពោះការដឹកជញ្ជូនទំនិញដោយអ្នកលក់ និងការទូទាត់នូវតម្លៃដោយអ្នកទិញ អាចមាន ហានិភ័យកើតឡើងដែរបណ្តាលមកពីតតិយជន។ ក្នុងករណីមានអំពើរបស់តតិយជន អនុសញ្ញាCISGមិនមានចែងច្បាស់លាស់នោះទេ ប៉ុន្តែអាចធ្វើការសម្រេចទៅលើភស្តុតាងរបស់ភាគីក្នុងកិច្ចសន្យាដើម្បីបញ្ជាក់ពីការបំពេញនូវកាតព្វកិច្ចរបស់ខ្លួន ក្នុងគោលដៅស្វែងរកអ្នកទទួលខុសត្រូវ។

ចំពោះហានិភ័យនៃការពន្យារពេលដោយក្រុមហ៊ុនដឹកជញ្ជូនបន្ទាប់ពីអ្នកលក់បានប្រគល់ទំនិញទៅក្រុមហ៊ុនដឹកជញ្ជូន តាមលក្ខខណ្ឌត្រឹមត្រូវដើម្បីដឹកជញ្ជូនទំនិញទៅឲ្យអ្នកទិញ ប៉ុន្តែក្រុមហ៊ុនដឹកជញ្ជូនមិនបានបំពេញនូវកាតព្វកិច្ចរបស់ខ្លួននៅពេលកំណត់ ដូចនេះក្រុមហ៊ុនដឹកជញ្ជូនជាអ្នកទទួលខុសត្រូវក្នុងការដឹកជញ្ជូនយឺតយ៉ាវ ឬមិនបានប្រគល់ទំនិញតាមពេលវេលាដែរបានកំណត់ មិនជាប់ពាក់ព័ន្ធនឹងអ្នកលក់ឡើយ។

ចំណែកការពន្យាពេលផ្តល់ការទូទាត់ជាសាច់ប្រាក់ទៅដល់អ្នកលក់ បន្ទាប់ពីអ្នកទិញបានធ្វើការទូទាត់តាមលក្ខខណ្ឌនៃនីតិវិធីដែរតម្រូវដោយធានាគាររួចរាល់ ហើយតម្រូវឲ្យធានាគារធ្វើការបញ្ជូននូវការទូទាត់ទៅកាន់អ្នកលក់តាមការកំណត់ ប៉ុន្តែធានាគារមិនបានបំពេញនូវកាតព្វកិច្ចរបស់ខ្លួននៅពេលកំណត់ ដូចនេះធានាគារជាអ្នកទទួលខុសត្រូវក្នុងការទូទាត់សាច់ប្រាក់ឲ្យឆាប់រហ័សបន្ទាប់ពីកាតព្វកិច្ចរបស់អ្នកទិញបានបំពេញ មិនជាប់ពាក់ព័ន្ធនឹងអ្នកទិញទៀតឡើយ។

[40] យោងតាម មាត្រា៦៨ នៃអនុសញ្ញាCISG

## កថាខណ្ឌទី២ ករណីប្រធានសក្តិ

ការរំលោភបំពានលើកិច្ចសន្យាដែលធ្វើឡើងដោយភាគីណាមួយមានសារៈសំខាន់ជាមូលដ្ឋាន ប្រសិនបើភាគីមួយធ្វើឲ្យមានការខូចខាតដល់ភាគីមួយផ្សេងទៀត ដោយភាគីបានបាត់បង់នូវអ្វីដែលគាត់មានសិទ្ធិរំពឹងទុកនៅក្រោមកិច្ចសន្យា ចំណែកឯភាគីនៃការរំលោភបំពានកិច្ចសន្យាមិនអាចមើលឃើញពីការខូចខាតដែរកើតពីធម្មជាតិ ដោយពុំដឹងទុកជាមុន ម្យ៉ាងវិញក៏បានព្យាយាមទប់ស្កាត់តែមិនអាចស្រោចស្រង់បាននោះទេ ។ ភាគីដែលបានរំលោភបំពានមិនទទួលខុសត្រូវពីហានិភ័យដែលកើតឡើងពីប្រធានសក្តិឡើយ។ ឧទាហរណ៍៖ ទឹកជំនន់ គ្រោះរាំងស្ងួត រញ្ជួញដីមានលក្ខណៈធ្ងន់ធ្ងរជាដើម និងមិនអាចគ្រប់គ្រងពីហានិភ័យនោះបានឡើយ។

ក្នុងករណីដែរប្រធានសិក្តបានបង្ករអោយមានព្យសនកម្មរួចហើយ ប៉ុន្តែភាគីនៃការរំលោភបំពានមិនធ្វើការទប់ស្កាត់នូវបញ្ហានានាដែរអាចដឹងទុកជាមុនថានឹងកើតមាន បន្ទាប់ពីព្យសនកម្ម។ នោះភាគីនៃការរំលោភបំពានត្រូវទទួលខុសត្រូវនូវផលដែរបាត់បង់ ឬខូចខាតដោយគិតតែក្នុងអំឡុងពេលបន្ទាប់ប្រធានសិក្តប៉ុណ្ណោះ។ ភាគីរងគ្រោះពីការបាត់បង់នូវផលប្រយោជន៍នៃកិច្ចសន្យានៅតែអាចធ្វើការទាមទារសំណងនៃការខូចខាត ប្រសិនបើបានរកឃើញភស្តុតាងផ្សេងៗ ប៉ុន្តែវាពិបាកដូចគ្នាក្នុងការស្វែងរកភស្តុតាង។ ឧទាហរណ៍៖ ករណីភ្លៀងទឹកជំនន់ដែរបានកើតឡើងក្នុងប្រទេសជប៉ុននៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៨ នៅតំបន់អូរការយ៉ាម៉ា ធ្វើឲ្យខូចខាតទ្រព្យសម្បត្តិផ្សេងៗ និងបាត់បង់ជីវិតមនុស្សជាច្រើននាក់ ចំណែកការវិនិយោគទុនផ្សេងៗមួយចំនួនដែលទាក់ទងនឹងតំបន់ដែរត្រូវទឹកជំនន់ក៏ត្រូវផ្អាកជាបណ្តោះអាសន្ន ព្រោះវាពិបាកក្នុងការទប់ស្កាត់គ្រោះធម្មជាតិភ្លាមៗ។ ដូចនេះភាគីដែលទទួលរងគ្រោះពីការបាត់បង់នៃប្រយោជន៍ពីកិច្ចសន្យាលក់ទំនិញ ក៏ពុំអាចប្តឹងទាមទារឲ្យភាគីដែរបានរំលោភបំពាន ពីមូលហេតុនៃគ្រោះធម្មជាតិឲ្យទទួលខុសត្រូវបានទេ។

# ជំពូកទី២
# ការទទួលខុសត្រូវចំពោះភាគី

ភាគីនីមួយៗនៅក្នុងកិច្ចសន្យាត្រូវទទួលខុសត្រូវរាល់ការមិនអនុវត្តនូវកាតព្វកិច្ចរបស់ខ្លួន។ ចំពោះការដោះស្រាយនូវបញ្ហាផ្សេងៗដល់ភាគីគឺស្ថិតនៅក្នុងជំពូកទី២នេះ វាធ្វើការបកស្រាយដូចជា៖ ផ្នែកទី១ ការទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ចរបស់ភាគី និងផ្នែកទី២ បទបញ្ញត្តិរួមសម្រាប់កាតព្វកិច្ចរបស់អ្នកលក់ និងអ្នកទិញ។

## ផ្នែកទី១ ការទទួលខុសត្រូវដោយឡែកចំពោះការមិនអនុវត្តកាតព្វកិច្ចរបស់ភាគី

នៅក្នុងកិច្ចសន្យា ប្រសិនបើមានភាគីណាមួយមិនបំពេញកាតព្វកិច្ចរបស់ខ្លួន នឹងធ្វើអោយប៉ះពាល់ដល់ភាគីម្ខាងទៀត ដូច្នេះភាគីដែលមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួនត្រូវតែទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន។ អ្នកដែលមិនអនុវត្តកាតព្វកិច្ចអាចជាអ្នកលក់ និងអ្នកទិញ។

### កថាខណ្ឌទី១ ការទទួលខុសត្រូវដោយឡែកចំពោះការមិនអនុវត្តកាតព្វកិច្ចដោយអ្នកលក់

ដំណោះស្រាយរបស់អ្នកទិញទាក់ទងនឹងការរំលោភបំពាន ឬមិនអនុវត្តកាតព្វកិច្ចរួមមាន៖ ការប្រគល់ទំនិញជំនួស ការរំលាយកិច្ចសន្យាដោយអ្នកទិញ ការកាត់បន្ថយតម្លៃ ដោយផ្តោតទៅលើការខូចខាត និងការអនុវត្តក្នុងករណីដែលមិនមានការដឹកជញ្ជូននិង ករណីផ្សេងទៀតក្រៅពីការប្រគល់ទំនិញមិនអនុលោមតាមកិច្ចសន្យា។ អ្នកទិញក៏អាចទាមទារសំណងខូចខាតបានដែរ ប្រសិនបើគាត់បានជួសជុលពីភាពមិនប្រក្រតីនៃការប្រគល់ទំនិញដែលអ្នកលក់មិនបានជួសជុល ការទាមទារសំណងការខូចខាតរួមមានការចំណាយសម្រាប់ការជួសជុលសមហេតុផលមួយ។

#### ក. ការប្រគល់នូវទំនិញជំនួស

ជាទូទៅអ្នកទិញមានសិទ្ធិ ក្នុងការទាមទារឲ្យអ្នកលក់ត្រូវបំពេញកាតព្វកិច្ចតាមកិច្ចសន្យារបស់ខ្លួន ដោយដោះស្រាយជាមួយការជំនួស និងការជួសជុលទំនិញដែលមិនអនុលោមភាពនៃទំនិញ។ សម្រាប់ដំណោះស្រាយរបស់អ្នកទិញ អ្នកលក់តម្រូវឱ្យមានការអនុវត្តច្បាស់លាស់ក្នុងកាតព្វកិច្ចដែលមានបញ្ហា ដោយត្រូវបានផ្តល់ក្នុងរយៈពេលបន្ថែមទៀតសមរម្យ សម្រាប់ការអនុវត្ត។

អ្នកទិញអាចបញ្ចូលការស្នើសុំការអនុវត្ត និងការទាមទារសម្រាប់ការខូចខាតណាមួយដែលនៅសល់ និងបណ្តាលមកពីការអនុវត្តយឺតយ៉ាវ។[41]

ប្រសិនបើអ្នកលក់បានប្រគល់ទំនិញដែលមិនអនុលោម ដែរបង្កើតការរំលោភបំពានកិច្ចសន្យាជាមូលដ្ឋាន និង អ្នកទិញមានបានស្នើសុំការផ្លាស់ប្តូរទំនិញដែលមិនស្របតាមលក្ខខណ្ឌដោយភ្ជាប់ជាមួយសេចក្តីជូនដំណឹង ឬមានហេតុផលសមរម្យ នោះអនុញ្ញាតឱ្យអ្នកទិញស្នើឱ្យមានការប្រគល់ទំនិញជំនួស ។ កង្វះនៃអនុលោមភាពទំនិញរួមមានៈ ទំនិញមានគុណភាពខុសពីទំនិញដែលត្រូវកំណត់ក្នុងកិច្ចសន្យា ការវេចខ្ចប់មិនត្រឹមត្រូវ ឬការខ្វះខាតបរិមាណ។

អ្នកទិញមានសិទ្ធិទាមទារការជួសជុល ប្រសិនបើទំនិញដែលដឹកជញ្ជូនមិនអនុលោមតាមកិច្ចសន្យា ចំណែកសំណើសុំជួសជុលមួយនឹងមិនសមហេតុផល ប្រសិនបើអ្នកទិញអាចជួសជុលទំនិញខ្លួនឯងបានយ៉ាងងាយស្រួល ប៉ុន្តែអ្នកលក់នៅតែទទួលខុសត្រូវចំពោះតម្លៃនៃការជួសជុលបែបនេះ។ ប្រសិនបើទំនិញដែលជំនួសជាបន្តបន្ទាប់មានភាពមិនប្រក្រតី អ្នកទិញត្រូវជូនដំណឹងអំពីមិនប្រក្រតីទៅអ្នកលក់ក្នុងរយៈពេលសមរម្យបន្ទាប់ ដើម្បីជួសជុលភាពមិនប្រក្រតីថ្មីមួយទៀត។ បន្ទាប់ពីការជូនដំណឹងដោយសារកង្វះអនុលោមភាពនៃទំនិញ អ្នកទិញអាចទាមទារសំណងខូចខាត និងមិនមានកាតព្វកិច្ចស្នើសុំជួសជុល បន្ទាប់ពីបានផ្តល់ឱកាសឱ្យអ្នកលក់ដោះស្រាយរាល់ការមិនអនុលោម។ សិទ្ធិក្នុងការតម្រូវឱ្យមានការប្រគល់ទំនិញជំនួសគឺស្របទៅតាមកាតព្វកិច្ចរបស់អ្នកទិញដើម្បីប្រគល់ទំនិញត្រឡប់ទៅវិញនូវទំនិញដែលមិនអនុលោមតាមកិច្ចសន្យា។ ប្រសិនការប្រគល់នូវទំនិញជំនួសត្រូវបានបញ្ជូន អ្នកទិញត្រូវតែពិនិត្យមើល និងជូនដំណឹងអំពីកំហុសឆ្គងណាមួយ ។

### **ខ. ការរំលាយកិច្ចសន្យាដោយអ្នកទិញ**

បន្ទាប់ពីអ្នកទិញផ្តល់នូវដំណោះស្រាយដើម្បីអនុគ្រោះដល់អ្នកលក់អនុវត្តនូវកាតព្វកិច្ចរបស់ខ្លួន ប៉ុន្តែអ្នកលក់នូវតែមិនអនុវត្តនោះអ្នកទិញមានសិទ្ធិរំលាយកិច្ចសន្យាក្នុងករណីពីរយ៉ាង[42] ៖

- ទីមួយ អ្នកលក់រំលោភបំពានកិច្ចសន្យាជាមូលដ្ឋាន
- ទីពីរ អ្នកលក់មិនអនុវត្តនូវកាតព្វកិច្ចរបស់ខ្លួនក្នុងកំឡុងរយៈពេលបន្ថែមជាក់លាក់ដែរផ្តល់ដោយអ្នកទិញ។

[41] យោងតាម មាត្រា៤៦ នៃអនុសញ្ញាCISG

[42] យោងតាម មាត្រា៤៩ នៃអនុសញ្ញាដដែល

### ១. ការរំលោភបំពានជាមូលដ្ឋាននៃកិច្ចសន្យា

ការរំលោភបំពានរបស់ភាគីនៃកិច្ចសន្យាអាចមិនត្រូវបានរំលាយ ប្រសិនបើភាគីអាចអនុវត្តនូវដំណោះស្រាយផ្សេងៗ ប៉ុន្តែប្រសិនបើការរំលោភបំពានជាមូលដ្ឋានភាគីអាចរំលាយកិច្ចសន្យាដូចបានកំណត់ដូចជា ៖

- ការមិនអនុលោមនៃទំនិញ ទាក់ទងនឹងគុណភាពមិនមែនជាការរំលោភកិច្ចសន្យាជាមូលដ្ឋានទេ ប្រសិនបើទំនិញដែលមិនស្របតាមស្តង់ដារតែអាចប្រើ ឬលក់បន្ត ហើយអ្នកទិញគ្មានភាពរអាក់រអួល តែបើវាធ្វើឲ្យអ្នកទិញមានភាពខូចខាតណាមួយ នោះវាជាការរំលោភបំពានជាមូលដ្ឋាន។ នៅពេលដែលទំនិញមានបញ្ហា ឬភាពមិនប្រក្រតីធ្ងន់ធ្ងរ ប៉ុន្តែអាចជួសជុលបានយ៉ាងងាយស្រួលដោយអ្នកលក់ និងមានប្រសិទ្ធិភាពយ៉ាងឆាប់រហ័ស នោះកង្វះអនុលោមភាពនៃទំនិញមិនមែនជាការរំលោភបំពានជាមូលដ្ឋានទេ។

- ទីកន្លែងនៃការក្លែងបន្លំនៃទំនិញ នៅក្នុងរបៀបមួយដែលខុសច្បាប់រដ្ឋទាំងអ្នកលក់និងអ្នកទិញ ជាការរំលោភបំពានជាមូលដ្ឋាន។ ច្បាប់ដែរគ្រប់គ្រងការដឹកទំនិញមិនស្របតាមស្តង់ដាត្រូវអនុវត្តដូចគ្នា ប្រសិនបើអ្នកលក់ផ្តល់នូវទំនិញខុស។

- ទំនិញសម្រាប់មនុស្សប្រើប្រាស់ដែរមានភាពមិនប្រក្រតី គឺគ្រោះថ្នាក់នៅពេលប្រើប្រាស់ជាប្រចាំ ត្រូវចាត់ទុកថាជាការរំលោភបំពានជាមូលដ្ឋាន។

- ការដឹកជញ្ជូនទំនិញមិនអនុលោមតាមកិច្ចសន្យា ប្រសិនបើធាតុសំខាន់នៅក្នុងកិច្ចសន្យាគឺសំដៅទៅដល់ការដឹកជញ្ជូនតាមពេលវេលាកំណត់។ ក្នុងករណីមិនមានការដឹកជញ្ជូនអ្នកទិញអាចរំលាយកិច្ចសន្យាបន្ទាប់ពីអនុញ្ញាតឱ្យមាននូវរយៈពេលបន្ថែមនៃពេលវេលា។ គ្មានការរំលោភបំពានទេ ប្រសិនអ្នកលក់មានសិទ្ធិមិនប្រគល់ព្រោះតែតម្រូវឲ្យអ្នកទិញទូទាត់ប្រាក់ជាមុនដូចបានព្រមព្រៀង។

- ករណីអ្នកលក់បានបញ្ជូនសារធាតុស្បូមដែលបានកែប្រែហ្សែនផ្ទុយទៅនឹងការធានាតាមកិច្ចសន្យា ក៏ត្រូវចាត់ទុកថាជាការរំលោភបំពានជាមូលដ្ឋាន។

- ឯកសារមិនស្របតាមច្បាប់ កាតព្វកិច្ចរបស់អ្នកលក់ក្នុងការប្រគល់ឯកសារក៏អាចពាក់ព័ន្ធផងដែលសម្រាប់សម្រេចជាចុងក្រោយថាជាការរំលោភបំពានជាមូលដ្ឋាន។ ករណីឯកសារមិនមែនជាការរំលោភបំពានជាមូលដ្ឋានទេ ប្រសិនបើអ្នកទិញអាចដោះស្រាយភាពមិនប្រក្រតីបានយ៉ាងងាយស្រួលនៅក្នុងឯកសារ ដោយការស្នើសុំឯកសារថ្មីៗ និងប្រសិនបើអ្នកលក់អាចដោះ

ស្រាយបាននូវឯកសារដែលមិនស្របតាមពេលវេលានៃការអនុវត្ត ប៉ុន្តែបើគ្មានការផ្តល់ឯកសារឲ្យទាន់ពេលវេលាទេ ត្រូវចាត់ទុកថាជាការរំលោភបំពានជាមូលដ្ឋាន។ ការផ្តល់វិញ្ញាបនបត្រក្លែងក្លាយនៃប្រភពដើម មិនបានបង្កើតជាការរំលោភបំពានជាមូលដ្ឋានទេប្រសិនបើទំនិញមានគុណភាពជំនួញ និងប្រសិនបើអ្នកទិញខ្លួនឯងអាចទទួលបានវិញ្ញាបនប័ត្រត្រឹមត្រូវ។

- អ្នកលក់ដែរបានប្រគល់តែពាក់កណ្តាលនៃទំនិញដែលបានចុះកិច្ចសន្យា នោះត្រូវបានគេចាត់ទុកថានេះអាចជាការរំលោភបំពានជាមូលដ្ឋាននៃកិច្ចសន្យាទាំងមូល។

**២.ការកំណត់រយៈពេលបន្ថែមដោយអ្នកទិញ**

ដើម្បីរំលាយកិច្ចសន្យា អ្នកទិញត្រូវផ្តល់នូវរយៈពេលបន្ថែមក្នុងការអនុវត្តកាតព្វកិច្ចដោយអ្នកលក់ជាមុនសិន ប្រសិនបើអ្នកលក់ខកខានក្នុងការប្រគល់ទំនិញក្នុងរយៈពេលបន្ថែមទៀតដែរបានផុតកំណត់ អ្នកទិញអាចប្រកាសថារំលាយកិច្ចសន្យាបាន និងរក្សាសិទ្ធិក្នុងការទាមទារសំណងការខូចខាតសម្រាប់ការពន្យាពេលដើម្បីអនុវត្ត។ ប្រសិនបើអ្នកលក់ជូនដំណឹងដល់អ្នកទិញថានឹងមិនអនុវត្តក្នុងអំឡុងពេលបន្ថែមទៀតនោះទេ អ្នកទិញត្រូវមានសេរីភាពក្នុងការប្រើមធ្យោបាយដទៃទៀតដោះស្រាយ ក្នុងករណីដែលអ្នកលក់មិនត្រូវការការពារ។ ប៉ុន្តែប្រសិនបើអ្នកទិញមិនបានផ្តល់ពេលវេលាបន្ថែមទៀតក្នុងស្ថានភាពការដឹកជញ្ជូនយឺតទេ អ្នកទិញមានមិនមានសិទ្ធិដើម្បីរំលាយកិច្ចសន្យានោះទេ។[43]

លើសពីនេះ អ្នកទិញដែលមានសិទ្ធិដើម្បីរំលាយកិច្ចសន្យាមិនចាំបាច់រង់ចាំមើលថាអ្នកលក់នឹងដោះស្រាយក្នុងរយៈពេលបន្ថែមទេ អាចប្រកាសរំលាយកិច្ចសន្យាបានភ្លាមៗ ប្រសិនបើទទួលរងការរំលោភបំពានជាមូលដ្ឋាន ហើយអ្នកទិញនៅតែរក្សាសិទ្ធិក្នុងការទាមទារសំណងសម្រាប់ការខាតបង់បានបណ្តាលឲ្យរងគ្រោះ បើទោះបីជាបានដោះស្រាយដោយការរំលាយកិច្ចសន្យា។

អ្នកលក់អាចផ្តល់ការជូនដំណឹងអំពីឆន្ទៈរបស់ខ្លួនក្នុងការដោះស្រាយការខកខាននៃការអនុវត្តកាតព្វកិច្ចដល់អ្នកទិញក្នុងកំឡុងពេលជាក់លាក់មួយ ហើយស្នើសុំអ្នកទិញឲ្យបានដឹងថាអ្នកលក់ដោះស្រាយបញ្ហានោះ។ សេចក្តីជូនដំណឹងដែលបង្ហាញពីឆន្ទៈរបស់អ្នកលក់ដើម្បីដោះស្រាយត្រូវបានចាត់ទុកថារួមបញ្ចូលការស្នើសុំនូវរយៈពេលបន្ថែម។ ប្រសិនបើអ្នកទិញមិនឆ្លើយតបនឹងសំណើរបស់អ្នកលក់ក្នុងរយៈពេលសមរម្យ(ឬសន្មតថាឯកភាពចំពោះសំណើនេះ) អ្នកលក់អាចដោះស្រាយបានក្នុងរយៈពេលដែលបានបង្ហាញ អ្នកទិញមិនមានសិទ្ធិក្នុងអំឡុងពេលនោះងាកទៅដោះ

[43] យោងតាម មាត្រា៤៧ នៃអនុសញ្ញាCISG

ស្រាយណាមួយឡើយ។ អ្នកទិញត្រូវតែទទួលសំណើរសុំការឆ្លើយតបរបស់អ្នកលក់ទៅនឹងការដោះស្រាយដែលបានស្នើ ឬការជូនដំណឹងនៃចេតនាដើម្បីការដោះស្រាយដែលចាត់ទុកជាការស្នើរសុំ ឬការស្នើសុំ ឬសេចក្តីជូនដំណឹង ។

**គ. ការកាត់បន្ថយតម្លៃ**

ចំពោះលក្ខខណ្ឌដែលអ្នកទិញអាចប្រកាសរំលាយកិច្ចសន្យាចំពោះការរំលោភបំពានកិច្ចសន្យាមានដូចជា៖ ការរំលោភបំពានជាមូលដ្ឋានលើកាតព្វកិច្ចរបស់អ្នកលក់ និងនៅក្នុងករណីមិនបញ្ជូនទំនិញនៅក្នុងរយៈពេលបន្ថែម។ កាលៈទេសៈជាច្រើនដែលអ្នកទិញបាត់បង់សិទ្ធិក្នុងការប្រកាសរំលាយកិច្ចសន្យាប្រសិនបើគាត់ខកខានដើម្បីការស្នើសុំការជូនដំណឹង។

អ្នកទិញអាចស្នើសុំកាត់បន្ថយតម្លៃទៅជាសូន្យ មានន័យថាទំនិញមិនមានតម្លៃសម្រាប់ការទូទាត់។ នៅក្នុងស្ថានភាពនោះការកាត់បន្ថយតម្លៃអាចមានផលប៉ះពាល់ស្មើរតែដូចគ្នានឹងការរំលាយ និងសំណងដែរ លើកលែងតែវាមិនតម្រូវឱ្យអ្នកទិញប្រគល់ទំនិញទៅវិញទេ។ ការកាត់បន្ថយតម្លៃគឺជាផ្នែកមួយនៃដំណោះស្រាយរបស់អ្នកទិញ វាអាចផ្តល់ជូនអ្នកទិញនូវជម្រើសជំនួសឱ្យសិទ្ធិក្នុងការស្នើសុំអនុវត្តជាក់លាក់ ការខូចខាត ឬការរំលាយ អ្នកទិញគឺមានសេរីភាពក្នុងការជ្រើសរើសក្នុងចំណោមនោះ។ ការកាត់បន្ថយតម្លៃអាចត្រូវបានស្នើសុំទោះបីជារយៈពេលសមស្របនៃពេលវេលាដើម្បីរំលាយកិច្ចសន្យាត្រូវបានផុតកំណត់។ ជំនួសឱ្យ ឬរួមជាមួយការកាត់បន្ថយតម្លៃអ្នកទិញមានសិទ្ធិប្តឹងទាមទារសំណងការខូចខាតសំរាប់ដំណោះស្រាយណាមួយដែលនៅសល់បានបាត់បង់។[44]

បរិមាណនៃការកាត់បន្ថយតម្លៃត្រូវតែត្រូវបានគណនាជាសមាមាត្រដូចគ្នាទៅនឹងតំលៃដែលទំនិញមិនអនុលោមតាមកិច្ចសន្យា និងបដិសេធរាល់តម្លៃដែលស្របតាមទំនិញនឹងមាន។ តម្លៃពាក់ព័ន្ធត្រូវបានកំណត់ពីកាលបរិច្ឆេទនៃការដឹកជញ្ជូននៅកន្លែងដឹកជញ្ជូន ក្នុងករណីដែលប្រគល់ទំនិញដោយមិនមានតម្លៃទាំងអស់ តម្លៃអាចត្រូវបានកាត់បន្ថយទៅសូន្យ នោះអ្នកទិញបានបាត់បង់សិទ្ធិក្នុងការប្រកាសរំលាយកិច្ចសន្យា។ ភាគីមានសេរីភាពក្នុងការឯកភាពគ្នាលើវិធីជាក់លាក់មួយក្នុងការគណនាការកាត់បន្ថយតម្លៃ។

ប្រសិនបើមានការជំទាស់ដោយភាគី និងមិនអាចកំណត់បានទេនូវតម្លៃនីមួយៗអាចត្រូវបានវាយតម្លៃដោយសាក្សីជំនាញ។ ទីតាំងនៃការអនុវត្តការកាត់បន្ថយតម្លៃគឺជាកន្លែងដែលទំនិញ

[44] យោងតាម មាត្រា៥០ នៃអនុសញ្ញា CISG

ត្រូវបានដឹកជញ្ជូន(អាចនៅកន្លែងអ្នកលក់ ឬកន្លែងអ្នកទិញ)។ ប្រសិនបើអ្នកទិញបានបង់ប្រាក់រួច ហើយនូវតម្លៃ ការកាត់បន្ថយនូវតម្លៃអាចជាមូលដ្ឋានសម្រាប់ការទាមទារសំណងឡើងវិញរបស់អ្នកទិញ។ ក្នុងអនុសញ្ញាCISG មិនគ្របដណ្តប់លើករណីដែលអ្នកទិញបានបង់ថ្លៃរួចហើយ ប៉ុន្តែត្រូវបានស្នើសុំកាត់បន្ថយតម្លៃ និងការទូទាត់សងពីអ្នកលក់ ។

ការកាត់បន្ថយតម្លៃត្រូវបានអនុវត្តមិនថា ការមិនអនុលោមបង្កើតជាការរំលោភមូលដ្ឋាន ឬការរំលោភបំពានជាសាមញ្ញនៃកិច្ចសន្យា និងអ្នកលក់ប្រព្រឹត្តដោយធ្វេសប្រហែស ការកាត់បន្ថយតម្លៃអាចត្រូវបានសន្មត់ទុកជាមុន ទោះជាអ្នកទិញបានផ្តល់ការជូនដំណឹងអំពីកង្វះនៃការអនុលោមនៃទំនិញ ដោយអ្នកទិញបង្ហាញពីចេតនារបស់ខ្លួនក្នុងការកាត់បន្ថយតម្លៃ។ ការបដិសេធរបស់អ្នកទិញក្នុងការបង់ថ្លៃត្រូវបានចាត់ទុកថាគ្រប់គ្រាន់ក្នុងការដើម្បីទាមទារការកាត់បន្ថយតម្លៃ និងកាត់បន្ថយតម្លៃទៅសូន្យ។

ការដោះស្រាយនៃការកាត់បន្ថយតម្លៃគឺមិនអាចធ្វើទៅបានទេ ប្រសិនបើអ្នកលក់បានដោះស្រាយរាល់ការមិនអនុលោម ឬនៅក្នុងដោះស្រាយនូវរយៈពេលបន្ថែមក្រោយកាលបរិច្ឆេទសម្រាប់ការចែកចាយ ។

## កថាខណ្ឌទី២ ការទទួលខុសត្រូវដោយឡែកចំពោះការមិនអនុវត្តកាតព្វកិច្ចដោយអ្នកទិញ

លក្ខខណ្ឌនៃដំណោះស្រាយដែលត្រូវបានកំណត់ដោយអ្នកលក់ គឺដើម្បីអនុគ្រោះដល់អ្នកទិញនៅពេលមិនបានបំពេញនូវកាតព្វកិច្ចណាមួយរបស់ខ្លួន អ្នកលក់ត្រូវអនុវត្តសិទ្ធិទាមទារឲ្យអ្នកទិញបំពេញនូវកាតព្វកិច្ចទទួលយកទំនិញដែរខ្លួនបានទិញ។ ចំណែកការទាមទារសំណងសម្រាប់ការបាត់បង់ និងរំលាយកិច្ចសន្យាដោយអ្នកលក់ ក៏ត្រូវអនុវត្តបន្ទាប់ពីអ្នកទិញនៅតែមិនអនុវត្តនូវដំណោះស្រាយដែរអ្នកលក់ផ្តល់ឲ្យ។

### ក. ការទទួលយកទំនិញដែលខ្លួនបានទិញ

អ្នកលក់មានសិទ្ធិតម្រូវឱ្យអ្នកទិញបំពេញនូវកាតព្វកិច្ចរបស់ខ្លួន ដោយអ្នកលក់ស្នើសុំឱ្យអ្នកទិញទូទាត់តំលៃទំនិញដែលបានកំណត់ក្នុងកិច្ចសន្យា ហើយចំពោះការអនុវត្តកាតព្វកិច្ចជាក់លាក់គឺត្រូវទទួលយកការដឹកជញ្ជូនទំនិញពីអ្នកលក់។ ក្នុងករណីការប្រគល់ទំនិញនៅកន្លែងធ្វើអាជីវកម្មរបស់អ្នកលក់ អ្នកលក់ត្រូវជូនដំណឹងដល់អ្នកទិញដើម្បីមកទទួលយកទំនិញ ប៉ុន្តែប្រសិនបើអ្នក

ទិញមិនមកទទួលយកទំនិញ អ្នកលក់ត្រូវផ្តល់នូវរយៈពេលបន្ថែមបន្ទាប់មកទើបរំលាយកិច្ចសន្យា និងទាមទារសំណងការខូចខាត។[45]

ប្រសិនបើទាក់ទងនឹងការដឹកជញ្ជូនដោយក្រុមហ៊ុនដឹកជញ្ជូនទៅទីកន្លែងធ្វើអាជីវកម្មរបស់អ្នកទិញ នោះក្រុមហ៊ុនដឹកជញ្ជូននឹងបញ្ជូនទៅរោងចក្រ ឬទីកន្លែងស្តុកទំនិញរបស់អ្នកទិញ។ អ្នកទិញត្រូវតែទទួលយកការដឹកជញ្ជូននោះ និងត្រួតពិនិត្យ ប្រសិនបើអ្នកទិញបដិសេធមិនទទួលយកការដឹកជញ្ជូនទំនិញ ត្រូវជូនដំណឹងដល់អ្នកលក់ពីការមូលហេតុសមរម្យ បើមិនដូច្នោះទេ អ្នកទិញត្រូវតែទទួលយកទំនិញ។

### ខ. ការរំលាយកិច្ចសន្យាដោយអ្នកលក់

អ្នកទិញមានកាតព្វកិច្ចអនុវត្តតាមការព្រមព្រៀងដោយឆន្ទៈគូរភាគីក្នុងកិច្ចសន្យា ហើយអ្នកលក់ក៏ផ្តល់នូវដំណោះស្រាយផ្សេងៗបន្ថែមទៀតក្នុងករណីអ្នកទិញមិនបំពេញនូវកាតព្វកិច្ចរបស់ខ្លួន។ អ្នកលក់អាចរំលាយកិច្ចសន្យាមានពីរករណី[46]៖

- ទីមួយ បើការខកខានរបស់អ្នកទិញក្នុងការបំពេញកាតព្វកិច្ចតាមកិច្ចសន្យា ជាការរំលោភបំពានកិច្ចសន្យាជាមូលដ្ឋាន
- ទីពីរ បើអ្នកទិញខកខានក្នុងការបង់ថ្លៃទំនិញ ឬទទួលយកទំនិញជាមួយនឹងរយៈពេលបន្ថែមទៀតដែលបានកំណត់ ។

#### ១. ការរំលោភបំពានជាមូលដ្ឋាននៃកិច្ចសន្យា

ការរំលាយកិច្ចសន្យាគឺជាការដោះស្រាយចុងក្រោយដែលអាចរកបាននៅពេលដែលអ្នកលក់មិនអាចរំពឹងថានឹងបន្តកិច្ចសន្យា។ នៅក្នុងករណីមិនមានការទូទាត់តម្លៃ អ្នកលក់មានសិទ្ធិរំលាយកិច្ចសន្យានៅពេលណាមួយ បន្ទាប់ពីតម្រូវការទាំងអស់សម្រាប់ការរំលាយត្រូវបានបំពេញ។ សញ្ញាណនៃការរំលោភបំពានជាមូលដ្ឋានត្រូវបានបកស្រាយយ៉ាងទូលំទូលាយ ក្នុងគោលបំណងដើម្បីការពារការប្រើប្រាស់ហួសកំរិតនៃការរំលាយកិច្ចសន្យា ពោលគឺការខកខានក្នុងការបង់ថ្លៃ ការខកខានក្នុងការទទួលយកការដឹកជញ្ជូនទំនិញ និងការមិនបំពេញកាតព្វកិច្ចផ្សេងៗដែលបាន

[45] យោងតាម មាត្រា៦២ នៃអនុសញ្ញាCISG

[46] យោងតាម មាត្រា៦៤ នៃអនុសញ្ញាដដែល

កំណត់ដោយកិច្ចសន្យាលើអ្នកទិញ។ ការខកខានក្នុងការបង់ថ្លៃ ឬផ្នែកធំមួយនៃតម្លៃជាទូទៅគឺបង្កើតការរំលោភកិច្ចសន្យាជាមូលដ្ឋាន។

ផ្ទុយទៅវិញ ការពន្យារពេលក្នុងការទូទាត់តម្លៃមិនត្រូវបានបកស្រាយថាជាការរំលោភបំពានជាមូលដ្ឋានទេ លុះត្រាតែការអនុវត្តនៃកាតព្វកិច្ចក្នុងការបង់ថ្លៃទាន់ពេលវេលាគឺជាសារៈសំខាន់នៃកិច្ចសន្យា។ ការខកខានក្នុងការបើកលិខិតឥណទានក្នុងពេលកំណត់ដោយកិច្ចសន្យានេះមិនមែនជាមូលដ្ឋានគ្រឹះនៃការរំលោភបំពានទេ តែយោងទៅតាមកាលៈទេសៈនៃសំណុំរឿងប៉ុណ្ណោះ។ ការខកខានចុងក្រោយរបស់អ្នកទិញក្នុងការទទួលយកការដឹកជញ្ជូនទំនិញជាធម្មតាបង្កើតបានជាការរំលោភកិច្ចសន្យាជាមូលដ្ឋាន តែចំពោះការពន្យាពេលពីរបីថ្ងៃនៅក្នុងការទទួលយកទំនិញមិនត្រូវបានបកស្រាយថាជាការរំលោភជាមូលដ្ឋានទេ។ ការពន្យាពេលដែលអាចធ្វើឱ្យមានការរំលោភបំពានជាមូលដ្ឋានត្រូវមើលទៅលើកាលបរិច្ឆេទសម្រាប់ការទទួលយកគឺមានសារៈសំខាន់ជាពិសេសសម្រាប់អ្នកលក់ ។

អ្នកលក់អាចធ្វើការជូនដំណឹងដល់អ្នកទិញពីការរំលាយកិច្ចសន្យា បើពុំនោះទេការរំលាយកិច្ចសន្យាមិនមានប្រសិទ្ធភាពចំពោះអ្នកទិញទេ។ យោងទៅលើឆន្ទៈសេរីភាពក្នុងការជូនដំណឹងរបស់គូភាគី សេចក្តីជូនដំណឹងមិនចាំបាច់សរសេរជាលាយលក្ខណ៍អក្សរទេ អាចធ្វើឡើងដោយផ្ទាល់មាត់ ឬទាញយកពីសកម្មភាពរបស់អ្នកលក់ ។ ប្រសិនបើអ្នកទិញបានបង់តែផ្នែកមួយនៃតម្លៃអ្នកលក់ក៏នៅតែអាចបន្តនូវសិទ្ធិប្រកាសរំលាយបានក្នុងពេលវេលាណាមួយ។ បន្ទាប់ពីអ្នកទិញបានបង់ថ្លៃ អ្នកលក់បាត់បង់សិទ្ធិក្នុងការរំលាយកិច្ចសន្យា ប្រសិនបើអ្នកលក់មិនបានប្រកាសរំលាយកិច្ចសន្យាបន្ទាប់ពីរយៈពេលបន្ថែមដែលបានកំណត់ ។

### ២.ការកំណត់រយៈពេលបន្ថែមដោយអ្នកលក់

កំឡុងពេលដែលកំណត់ក្នុងកិច្ចសន្យាតម្រូវឲ្យអ្នកទិញអនុវត្តនូវកាតព្វកិច្ចរបស់ខ្លួន ប៉ុន្តែអ្នកទិញនៅតែមិនអនុវត្ត អ្នកលក់ត្រូវកំណត់រយៈពេលបន្ថែមបន្ទាប់ពីរយៈពេលដែលបានកំណត់សម្រាប់អ្នកទិញបានកន្លងផុតទៅដើម្បីអនុវត្តកាតព្វកិច្ច។[47] ការកំណត់នូវរយៈពេលបន្ថែមមានសារៈប្រយោជន៍ទាក់ទងនឹងសិទ្ធិរបស់អ្នកលក់ ដើម្បីប្រកាសរំលាយកិច្ចសន្យា ប្រសិនបើអ្នកទិញមិនបង់ថ្លៃ ឬទទួលយកទំនិញក្នុងកំឡុងពេលបន្ថែមនៃពេលវេលាកំណត់ អ្នកលក់អាចប្រកាសរំលាយកិច្ចសន្យា ។ យន្តការសម្រាប់ការរំលាយកិច្ចសន្យាអនុវត្តតែក្នុងករណីដែលអ្នកទិញមិនបង់ថ្លៃនៃទំនិញ

[47] យោងតាម មាត្រា៦៣ នៃអនុសញ្ញាCISG

ឬខកខានទទួលយកទំនិញ ហើយមានសិទ្ធិទាមទារសំណងការខូចខាតចំពោះការពន្យាពេលក្នុងការអនុវត្ត។ ផលប៉ះពាល់សម្រាប់អ្នកលក់នៃការកំណត់នូវរយៈពេលបន្ថែម គឺបម្រុងទុកដើម្បីការពារអ្នកទិញដែលមានសិទ្ធិទទួលបានជាពិសេស នៅពេលរៀបចំអនុវត្តកាតព្វកិច្ចរបស់ខ្លួន។

អ្នកលក់មានសិទ្ធិកំណត់រយៈពេលបន្ថែមទៀតសម្រាប់អ្នកទិញ ប៉ុន្តែមិនមានកាតព្វកិច្ចធ្វើនូវដំណោះស្រាយផ្សេងៗក្នុងកំឡុងពេលនៃរយៈពេលបន្ថែមរួមទាំងការរំលាយកិច្ចសន្យា។ ប្រសិនបើអ្នកទិញបានប្រកាសថាមានការរំលោភបំពានដោយកង្វះអនុលោមភាពនៃទំនិញដែលអ្នកលក់បានបញ្ជូនមក មុនពេលអ្នកលក់ផ្តល់រយៈពេលបន្ថែមនៃការទូទាត់តម្លៃ។ មិនអាចត្រូវបានបកស្រាយថាជាពេលវេលាបន្ថែមទេ ព្រោះកំឡុងពេលដែលអ្នកលក់ជួសជុលនូវកង្វះអនុលោមភាពនៃទំនិញ ត្រូវបានគិតថាជាកំឡុងពេលដាច់ដោយឡែកពីរយៈពេលបន្ថែមសម្រាប់អ្នកទិញទូទាត់តម្លៃ។ លុះត្រាតែអ្នកលក់បានជួសជុលនូវកង្វះអនុលោមរួចរាល់ ហើយអ្នកទិញមិនធ្វើការទូទាត់ នោះអ្នកលក់នឹងត្រូវផ្តល់នូវរយៈពេលបន្ថែម។ កាលបរិច្ឆេទសម្រាប់ការទូទាត់តម្លៃ គឺស្របតាមការជូនដំណឹងជាមុនរបស់អ្នកលក់ ហើយអាចកំណត់រយៈពេលបន្ថែមក្នុងសេចក្តីជូនដំណឹង និងតម្លៃដែលបានកំណត់។

រយៈពេលបន្ថែមដែលផ្តល់ដោយអ្នកលក់គឺបានបង្កើតឡើងដោយមធ្យោបាយនៃការជូនដំណឹងពីអ្នកលក់ទៅឱ្យអ្នកទិញ។ អ្នកលក់ត្រូវតែបង្ហាញយ៉ាងច្បាស់ថាអ្នកទិញត្រូវតែធ្វើការអនុវត្តក្នុងរយៈពេលបន្ថែមដែលបានកំណត់។ ការទាមទារទូទៅតម្រូវឱ្យអ្នកទិញអនុវត្ត ឬបំពេញកាតព្វកិច្ចរបស់ខ្លួនភ្លាមៗ ឬឆាប់ ក្នុងរយៈពេលកំណត់ដោយកាលបរិច្ឆេទដែលអនុវត្ត។ ឧទាហរណ៍៖ នៅត្រឹមថ្ងៃទី៣០ ខែកញ្ញា ឬក្នុងរយៈពេលមួយខែពីថ្ងៃនេះ ។

រយៈពេលបន្ថែមដែលកំណត់ដោយអ្នកលក់ត្រូវតែមានរយៈពេលសមហេតុផលដើម្បីឲ្យអ្នកទិញអាចបំពេញតម្រូវការសមរម្យនៃរយៈពេលបន្ថែម ដោយវាយតម្លៃអាស្រ័យទៅលើកាលៈទេសៈនៃករណី រួមទាំងការធ្វើពាណិជ្ជកម្ម និងការអនុវត្តន៍ដែលបានបង្កើតឡើងរវាងភាគី។ រយៈពេលសមស្របមួយទាក់ទងនឹងការទទួលយកទំនិញ នឹងយូរជាងការអនុវត្តការទូទាត់តម្លៃ ចំណែករយៈពេលបន្ថែមដែលខ្លីពេកត្រូវបានច្រានចោលដោយសារមិនសមរម្យនូវការអនុវត្ត។ អ្នកលក់ផ្តល់ឲ្យអ្នកទិញនូវឱកាសចុងក្រោយដោយផ្តល់នូវរយៈពេលបន្ថែមសម្រាប់អ្នកទិញដើម្បីអនុវត្តកាតព្វកិច្ចរបស់ខ្លួន។

ការរំលាយកិច្ចសន្យាអាចអនុវត្តបានតែក្នុងករណីមិនមានការទូទាត់តម្លៃ ឬខកខានទទួលយកទំនិញ អ្នកលក់អាចរំលាយកិច្ចសន្យាប្រសិនបើអ្នកទិញមិនបានបង់ថ្លៃ ឬទទួលយកទំនិញក្នុង

រយៈពេលបន្ថែមនៃពេលវេលាដែលបានកំណត់ដោយអ្នកលក់។ អ្នកលក់ក៏អាចរំលាយកិច្ចសន្យា ប្រសិនបើអ្នកទិញប្រកាសថានឹងមិនបង់ថ្លៃ ឬទទួលទំនិញនៅក្នុងរយៈពេលបន្ថែមដែលកំណត់។

## ផ្នែកទី២ បទបញ្ញត្តិរួមសម្រាប់កាតព្វកិច្ចរបស់អ្នកលក់ និងអ្នកទិញ

ដោយយោងតាមការបកស្រាយខាងលើនេះ យើងដឹងហើយអំពីការទទួលខុសត្រូវរបស់អ្នកលក់ និងអ្នកទិញ ប៉ុន្តែយ៉ាងណាមិញនៅក្នុងអនុសញ្ញាCISG ក៏បានបញ្ញត្តិបន្ថែមទៀតចំពោះការទទួលខុសត្រូវរបស់អ្នកលក់ និងអ្នកទិញដែលស្ថិតក្នុងបទបញ្ញត្តិរួមដែលនឹងត្រូវធ្វើការបកស្រាយដូចខាងក្រោម៖

### កថាខណ្ឌទី១ ការបំពានកាលាទិករណ៍ និងកិច្ចសន្យាប្រគល់ទំនិញជាបន្តបន្ទាប់

ក្នុងកិច្ចសន្យាបានកំណត់នៅកាលបរិច្ឆេទនៃការប្រគល់ទំនិញ និងការទូទាត់ប្រាក់ ដើម្បីឲ្យភាគីទាំងសងខាងបំពេញនូវកាតព្វកិច្ចរៀងៗខ្លួន។ ចំណែកការទាមទារឲ្យភាគីណាមួយអនុវត្តកាតព្វកិច្ចមុនភាគីម្ខាងទៀត ឬតម្រូវឲ្យអនុវត្តដំណាលគ្នាក៏ជាឆន្ទៈរបស់គូរភាគីក្នុងការព្រមព្រៀងផ្សេងទៀត។ ប៉ុន្តែបើភាគីណាមួយផ្អាកនូវការអនុវត្តកាតព្វកិច្ចរបស់ខ្លួនដែរបានកំណត់ នោះជាការបំពានកាលាទិករណ៍ ហើយប្រសិនបើកិច្ចសន្យាតម្រូវឲ្យភាគីអនុវត្តជាបន្តបន្ទាប់ភាគីនោះត្រូវបំពេញនូវកាតព្វកិច្ចរបស់ខ្លួន។

### ក. ការបំពានកាលាទិករណ៍

កិច្ចសន្យាត្រូវបានបង្កើត ដូចនេះគូរភាគីមានកាតព្វកិច្ចក្នុងការអនុវត្តតាមឆន្ទៈរបស់ខ្លួន។ ការបំពេញកាតព្វកិច្ចនេះដែររួមមាន៖ អ្នកលក់ត្រូវប្រគល់ទំនិញ ចំណែកអ្នកទិញត្រូវទទួលយកទំនិញ និងទូទាត់នូវតម្លៃ ប៉ុន្តែភាគីមួយនៃកិច្ចសន្យាអាចផ្អាកបំពេញកាតព្វកិច្ចរបស់ខ្លួនបាន ប្រសិនបើភាគីនោះច្បាស់ថាភាគីផ្សេងទៀតនឹងមិនបំពេញកាតព្វកិច្ចចាំបាច់របស់ខ្លួននោះ។ ចំពោះមូលហេតុដែលបណ្តាលឲ្យមានការបំពានរបស់ភាគីមួយអាចពន្យាពេលនៃការបំពេញកាតព្វកិច្ច គឺដោយសារមកពីភាគីម្ខាងទៀតនឹងមិនបំពេញកាតព្វកិច្ចមួយផ្នែកធំរបស់ខ្លួន អាចបណ្តាលមកពីកង្វះខាតយ៉ាងធ្ងន់ធ្ងរក្នុងលទ្ធភាពរបស់ខ្លួនដើម្បីបំពេញ ឬអសាធនភាពរបស់ខ្លួនក្នុងការបង់ប្រាក់។[48] ឧទាហរណ៍៖ អ្នកលក់ផ្អាកប្រគល់ទំនិញទៅឲ្យអ្នកទិញ ដោយសារតែអ្នកទិញនឹងមិនទូទាត់តម្លៃតាមពេលកំណត់ ព្រោះអ្នកទិញជួបបញ្ហាហិរញ្ញវត្ថុ។

[48] យោងតាម មាត្រា៧១ នៃអនុសញ្ញាCISG

ម្យ៉ាងវិញទៀត អ្នកលក់មានសិទ្ធិជំទាស់ការប្រគល់ទំនិញទៅឲ្យអ្នកទិញ ទោះបីទំនិញត្រូវបានបញ្ជូនចេញទៅហើយក៏ដោយ និងទោះបីជាអ្នកទិញមានឯកសារដែលបញ្ជាក់ថាអ្នកទិញមានសិទ្ធិលើទំនិញនោះក៏ដោយ។ ត្រង់ចំណុចនេះគោលការណ៍នៃអនុសញ្ញាCISGបានប្រគល់សិទ្ធិទៅអោយអ្នកលក់ក្នុងការបញ្ឈប់ការដឹកជញ្ជូនទំនិញអោយអ្នកទិញ នៅពេលអ្នកលក់អាចនឹងដឹងថាដំណាក់កាលក្រោយមិនអាចធ្វើទៅរួច។[49] ឧទាហរណ៍៖ ក្នុងករណីដែលអ្នកទិញជួបបញ្ហាហិរញ្ញវត្ថុដែលអាចធ្វើអោយគាត់គ្មានលទ្ធភាពបង់ថ្លៃទំនិញ។

អានុភាពនៃការផ្អាកការអនុវត្តកាតព្វកិច្ចមានដូចជា៖ ដោយភាគីមួយអាចទទួលបានសិទ្ធិផ្អាកការអនុវត្តកាតព្វកិច្ចរបស់ខ្លួន ។ ឧទាហរណ៍៖ នៅពេលដែលអ្នកទិញប្រឈមនឹងកាលៈទេសៈបដិសេធការអនុវត្តកាតព្វកិច្ចរបស់អ្នកលក់មួយចំនួន ដោយអ្នកលក់មិនប្រគល់ទំនិញ ឬដឹកជញ្ជូនទំនិញឲ្យអ្នកទិញ ឬករណីដែលអ្នកលក់មិនមានលទ្ធភាពដឹកទំនិញដោយសារគ្មានការផ្គត់ផ្គង់តម្លៃពីអ្នកទិញ ប្រសិនបើអ្នកលក់ដឹងថាអ្នកទិញនឹងមិនអាចទូទាត់តម្លៃបាន ឬពន្យារពេលបង់ប្រាក់។ ចំពោះអ្នកលក់ដឹកជញ្ជូនទំនិញដែលមិនស្រមតាមលក្ខខណ្ឌនៅក្នុងកិច្ចសន្យា នោះអ្នកទិញនឹងមិនអនុវត្តកាតព្វកិច្ចទទួលយកទំនិញដែរមិនអាចស្របតាមកិច្ចសន្យា ប្រសិនបើអ្នកទិញដឹងថាអ្នកលក់អលទ្ធភាពនឹងប្រគល់ទំនិញស្របតាមកិច្ចសន្យា។

ចំពោះការទាក់ទងនឹងរឿងផ្អាកការអនុវត្តកាតព្វកិច្ច ភាគីដែលផ្អាកការអនុវត្ត ទោះបីជាមុនពេល ឬក្រោយពេលបញ្ជូនទំនិញក្តី ត្រូវតែជូនដំណឹងជាបន្ទាន់អំពីការផ្អាក ឬការព្យួរកាតព្វកិច្ចនេះអោយភាគីមួយទៀតបានដឹង ហើយត្រូវបន្តការអនុវត្តកាតព្វកិច្ច ប្រសិនបើភាគីម្ខាងទៀតផ្តល់នូវការធានារ៉ាប់រងយ៉ាងគ្រប់គ្រាន់ទៅលើការអនុវត្តកាតព្វកិច្ចរបស់គាត់។[50] ឧទាហរណ៍៖ អ្នកលក់ផ្អាកប្រគល់ទំនិញទៅឲ្យអ្នកទិញ និងបានជូនដំណឹងពីមូលហេតុដែលមិនផ្តល់ទំនិញ ដូចនេះអ្នកទិញបានបង់ប្រាក់ជាមុនដើម្បីធានាថាអ្នកលក់អាចទទួលបានការទូទាត់តម្លៃ ដូចនេះអ្នកលក់ត្រូវប្រគល់ទំនិញទៅឲ្យអ្នកទិញជាចាំបាច់។

ប្រសិនបើមុនពេលកាលបរិច្ឆេទអនុវត្តកិច្ចសន្យា ភាគីម្ខាងដឹងច្បាស់ពីភាគីម្ខាងទៀតនឹងមិនអនុវត្តនូវកាតព្វកិច្ច នោះកិច្ចសន្យាអាចរំលាយចោលបាន។[51] បញ្ញត្តិពិសេសសម្រាប់កិច្ចសន្យាដែលអ្នកលក់ ឬអ្នកទិញមានសិទ្ធិប្រកាសថាកិច្ចសន្យារបស់ពួកគេគ្មានអានុភាព លុះត្រាតែភាគីរង

[49] បណ្ឌិតសាស្ត្រាចារ្យ Ingeborg Schwenzer, Christiana Fountoulakis & Mariel Dimsey *"International Sales Law: A Guide to CISG"* បោះពុម្ពលើកទី២ ឆ្នាំ២០១២ ទំព័រទី៥១២

[50] យោងតាម មាត្រា៧១ នៃអនុសញ្ញាCISG

[51] យោងតាម មាត្រា៧២ នៃអនុសញ្ញាដដែល

គ្រោះផ្តល់ការជូនដំណឹងដល់ភាគីម្ខាងទៀត។ ឧទាហរណ៍ៈ នៅពេលដែលអ្នកទិញដឹងច្បាស់ថាអ្នកលក់មិនអាចនឹងប្រគល់ទំនិញដែលជាកម្មវត្ថុនៃកិច្ចសន្យាបានទេ អ្នកទិញនឹងប្រកាសរំលាយកិច្ចសន្យា ហើយជូនដំណឹងទៅអ្នកលក់។

សិទ្ធិរបស់ភាគីរងគ្រោះក្នុងការរំលាយកិច្ចសន្យាត្រូវបានចែកដាច់ពីសិទ្ធិក្នុងការផ្អាកការអនុវត្តកាតព្វកិច្ច ដោយទាក់ទងនឹងការព្យាករណ៍ពីការរំលោភបំពាន។ ភាគីរងគ្រោះនៃកិច្ចសន្យាអាចរំលាយកិច្ចសន្យាមុនថ្ងៃអនុវត្តកាតព្វកិច្ចមកដល់ ប្រសិនបើកិច្ចសន្យានោះជាកិច្ចសន្យាដែលមានការដឹកជញ្ជូនតែមួយលើក។[52]

### ខ. កិច្ចសន្យាប្រគល់ទំនិញជាបន្តបន្ទាប់

គូរភាគីអាចបង្កើតកិច្ចសន្យាតែម្តង ហើយអនុវត្តជាបន្តបន្ទាប់តាមការព្រមព្រៀងដែលកំណត់ក្នុងកិច្ចសន្យា។ ប្រសិនបើភាគីណាមិនបំពេញកាតព្វកិច្ចដែលទាក់ទងទៅនឹងការប្រគល់ទំនិញជាបន្តបន្ទាប់នោះទេ នោះវាអាចក្លាយជាការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ ចំណែកភាគីម្ខាងទៀតអាចប្រកាសរំលាយកិច្ចសន្យាបាន។ ឬម្យ៉ាងទៀត ក្នុងករណីដែលភាគីណាមិនអាចអនុវត្តកាតព្វកិច្ចដែលទាក់ទងទៅនឹងការប្រគល់ទំនិញជាបន្តបន្ទាប់នាពេលអនាគត ភាគីម្ខាងទៀតក៏អាចប្រកាសរំលាយកិច្ចសន្យាបាន ដោយគ្រាន់តែបញ្ជាក់ថា ភាគីនោះមិនបានបំពេញកាតព្វកិច្ចក្នុងពេលសមរម្យមួយ។ អ្នកទិញដែលបានប្រកាសរំលាយកិច្ចសន្យាទទួលយកការប្រគល់ទំនិញណាមួយ ក៏អាចប្រកាសរំលាយកិច្ចសន្យានៅពេលការប្រគល់ទំនិញបានធ្វើរួច ឬការប្រគល់ទំនិញនឹងធ្វើនៅថ្ងៃមុខ ដោយហេតុផលថាការប្រគល់ទំនិញនោះមិនអាចប្រើសម្រាប់គោលបំណងដែលគាត់បានគិតទុកពេលធ្វើកិច្ចសន្យា។[53]

## កថាខណ្ឌទី២ ការខូចខាត និងការបង់ការប្រាក់

សកម្មភាពនៃការអនុវត្តរបស់គូរភាគី មានប្រសិទ្ធិភាពលុះត្រាតែមិនមានការខាតបង់នូវប្រយោជន៍របស់ភាគីម្ខាងទៀត។ ប៉ុន្តែប្រសិនបើមានការខូចខាតកើតឡើង ភាគីដែរំលោភបំពានត្រូវជួសជុលនៅការខូចខាតទៅភាគីម្ខាងទៀតអាចជាការប្រគល់ទំនិញជំនួស ឬសំណងជាប្រាក់។ ម្យ៉ាងទៀត ប្រសិនបើភាគីរំលោភបំពានពន្យាពេលនៃការទូទាត់សំណង ភាគីម្ខាងទៀតក៏អាចគិតជាការប្រាក់បន្ថែមផងដែរ។

[52] យោងតាម អត្ថបទសង្ខេបនៃរឿងក្តីនៃអនុសញ្ញាដដែល ឆ្នាំ២០១៦ ទំព័រទី៣២៤

[53] យោងតាម មាត្រា៧៣ កថាខណ្ឌ២ នៃអនុសញ្ញាCISG

### ក. ការខូចខាត

គូរភាគីអនុវត្តកាតព្វកិច្ចបន្ទាប់ពីបង្កើតកិច្ចសន្យា ប្រសិនបើភាគីណាមួយរំលោភបំពានកិច្ចសន្យា ហើយបណ្តាលឲ្យមានការខូចខាតត្រូវគិតរួមបញ្ចូលទាំងការខាតបង់លើប្រាក់ចំណេញដែលភាគីម្ខាងទៀតបានទទួល។[54] បន្ទាប់ពីការខូចខាត ភាគីដែររំលោភបំពានត្រូវបង់នូវសំណងពេញលេញដោយគិតទៅក្នុងស្ថានភាពសេដ្ឋកិច្ចប្រហាក់ប្រហែលគ្នា និងកិច្ចសន្យាដែលគួរតែត្រូវបានបំពេញយ៉ាងត្រឹមត្រូវ។

លើសពីនេះទៅទៀត ប្រសិនបើទំនិញជំនួសមានលក្ខណៈថ្លៃជាងតម្លៃទំនិញដែលភាគីប្តឹងទាមទារអោយសងការខូចខាត ដូច្នោះភាគីរងគ្រោះអាចយកទំនិញនោះទៅទូទាត់ ឬអាចរំលោះនូវភាពខុសគ្នារវាងតម្លៃនៃកិច្ចសន្យានោះបាន។[55] បន្ថែមពីនេះ ប្រសិនបើកិច្ចសន្យាត្រូវបានរំលាយនូវតម្លៃក្នុងកិច្ចសន្យា ភាគីអាចយកតម្លៃនៅលើទីផ្សារមកទូទាត់គ្នាបាន ប៉ុន្តែយកតែតម្លៃទំនិញដែរខុសគ្នាប៉ុណ្ណោះ។ តម្លៃនៅលើទីផ្សារ គឺជាតម្លៃដែរត្រូវបានគិតនៅទីកន្លែងធ្វើការប្រគល់ទំនិញ ឬទីកន្លែងផ្សេងទៀតដែលអាចរក្សាតម្លៃដូចគ្នានៅក្នុងការចំណាយលើការដឹកជញ្ជូនទំនិញ។[56] ជាធម្មតាតម្លៃទីផ្សារនៃទំនិញមានការផ្លាស់ប្តូរដែរត្រូវបានគិតជាទូទៅនៅលើទីផ្សារសម្រាប់ទំនិញដែលមានប្រភេទដូចគ្នា ។

ភាគីដែលរំលាយកិច្ចសន្យា ត្រូវតែមានវិធានការក្នុងការកាត់បន្ថយនូវការខាតបង់ប្រាក់ចំណេញដែលបណ្តាលមកពីការបំពានកិច្ចសន្យា បើមិនដូច្នោះទេភាគីដែលបំពានកិច្ចសន្យាអាចប្តឹងទាមទារអោយកាត់បន្ថយការខូចខាត ដោយគិតទៅតាមចំនួនដែលបាត់បង់ដែលគួរតែត្រូវបានកាត់បន្ថយពីភាគីរងគ្រោះ។[57]

### ខ. ការបង់ការប្រាក់

បន្ទាប់ពីការរំលោភបំពាននាំឲ្យមានការខូចខាត ភាគីដែររំលោភបំពានត្រូវជួសជុលនូវការខូចខាតដែលបណ្តាលមកពីសកម្មភាពរបស់ខ្លួន។ ប្រសិនបើភាគីណាមួយខកខានក្នុងការបង់ប្រាក់ ឬបំណុលផ្សេងទៀត ភាគីម្ខាងទៀតមានសិទ្ធិយកការប្រាក់លើថ្លៃទំនិញ និងបំណុលផ្សេងទៀត ប៉ុន្តែជាទូទៅភាគីយកការប្រាក់លើការខូចខាត និងការពិន័យផ្សេងៗទៀតដែលមានចែងក្នុងកិច្ច

[54] យោងតាម មាត្រា៧៤ នៃអនុសញ្ញាCISG
[55] យោងតាម មាត្រា៧៥ នៃអនុសញ្ញាដដែល
[56] យោងតាម មាត្រា៧៦ នៃអនុសញ្ញាដដែល
[57] យោងតាម មាត្រា៧៧ នៃអនុសញ្ញាដដែល

សន្យាតែប៉ុណ្ណោះ។[58] ចំពោះអត្រាការប្រាក់វិញយោងទៅតាមឆន្ទៈរបស់គូរភាគីក្នុងការសម្របសម្រួលគ្នា ប៉ុន្តែបើមិនអាចសម្របសម្រួលត្រូវពឹងផ្អែកលើអ្នកជំនាញដែលប្រៀបធៀបទៅលើការធ្វើពាណិជ្ជកម្មប្រហាក់ប្រហែលគ្នា ឬអាត្រាការប្រាក់នៃរូបិយប័ណ្ណ។[59] បញ្ហាអត្រាការប្រាក់គឺត្រូវពឹងផ្អែកទៅលើកិច្ចសន្យាដែលបានកំណត់ ឬយោងទៅលើច្បាប់ជាតិណាមួយដែលគូរភាគីយល់ព្រមទទួលយកហើយស្របក្នុងគោលការណ៍នៃអនុសញ្ញាCISG។

## កថាខណ្ឌទី៤ ការរក្សាទុកទំនិញ និងការរួចផុតពីការទទួលខុសត្រូវ

ការអនុវត្តតាមឆន្ទៈដែលបានព្រមព្រៀងក្នុងកិច្ចសន្យា ផ្តល់ឲ្យភាគីទាំងសងខាងទទួលបាននូវផលប្រយោជន៍ដែរខ្លួនរំពឹងទុក។ ចំពោះកាតព្វកិច្ចរបស់ភាគីមុនពេលប្រគល់ទំនិញទៅឲ្យភាគីម្ខាងទៀតត្រូវរក្សាទុកទំនិញឲ្យបានត្រឹមត្រូវ ជៀសវាងមានការខូចខាត ប៉ុន្តែប្រសិនបើភាគីដែររក្សាទុកទំនិញមិនអាចគ្រប់គ្រង និងរក្សាទុកទំនិញបាន ភាគីនោះត្រូវទទួលខុសត្រូវ ។ ប៉ុន្តែក៏មានករណីដែលភាគីនោះរួចផុតពីការទទួលខុសត្រូវដូចគ្នា។

### ក. ការរក្សាទុកទំនិញ

មុនពេលប្រគល់ទំនិញទៅឲ្យអ្នកទិញ អ្នកលក់ត្រូវរក្សាទុកទំនិញ និងមើលថែក្នុងនាមជាអ្នកកាន់កាប់នៃវត្ថុ ឬទំនិញដ៏ល្អ ចំណែកអ្នកទិញប្រសិនបើទំនិញដែលលើសចំនួនមិនស្របក្នុងកិច្ចសន្យា ហើយមិនទទួលយកក៏ត្រូវរក្សាទុកទំនិញមុនពេលប្រគល់ទៅឲ្យអ្នកលក់វិញ។ ដូចនេះការរក្សាទុកទំនិញ សំដៅដល់ការរក្សាទុកទំនិញដោយអ្នកលក់ និងដោយអ្នកទិញផងដែរ។ ម្យ៉ាងទៀតការរក្សាទុកទំនិញដោយអ្នកលក់ ប្រសិនបើក្នុងករណីអ្នកទិញមានការយឺតយ៉ាវក្នុងការទទួលយកទំនិញ ឬនៅពេលបង់ប្រាក់ និងការទទួលយកទំនិញត្រូវធ្វើដំណាលគ្នា ឬប្រសិនបើអ្នកទិញខកខានក្នុងការបង់ប្រាក់ ហើយអ្នកលក់កំពុងតែកាន់កាប់ទំនិញ អ្នកលក់ត្រូវចាត់វិធានការដែលសមរម្យដើម្បីរក្សាទំនិញទាំងនោះ មុនពេលអ្នកទិញមកទទួលយក។ ចំណែកអ្នកទិញក្នុងករណីដែលអ្នកលក់រក្សាទំនិញរហូតដល់អ្នកទិញមកទទួលត្រូវចេញរាល់ថ្លៃចំណាយផ្សេងៗដល់អ្នកលក់ក្នុងការថែរក្សាទំនិញ។[60]

---

[58] U.S. Court of Appeals (3rd Circuit), United States, 9 November 2011 (ECEM European Chemical Marketing B.V. v. The Purolite Co.), available on the Internet at www.cisg.law.pace.edu (interest on damages for lost profits)

[59] យោងតាម កថាខណ្ឌទី៩ នៃអត្ថបទសង្ខេបនៃរឿងក្តីនៃអនុសញ្ញាCISG ឆ្នាំ២០១៦ ទំព័រទី៣៦៥

[60] យោងតាម មាត្រា៨៥ នៃអនុសញ្ញាCISG

លើសពីនេះទៅទៀត ការរក្សាទុកទំនិញដោយអ្នកទិញ ប្រសិនបើក្នុងករណីអ្នកទិញបានទទួលទំនិញលើសពីបំណងប្រើប្រាស់ ហើយបានបដិសេធមិនទទួលយកទំនិញ នោះអ្នកទិញត្រូវមានវិធានការណ៍សមស្របទៅតាមកាលៈទេសៈដើម្បីរក្សាទុកទំនិញ។ អ្នកទិញមានសិទ្ធិរក្សាទុកទំនិញរហូតដល់ប្រគល់ទៅអ្នកលក់វិញ ចំណែកអ្នកលក់ត្រូវរាល់ការចំណាយទាំងឡាយដ៏សមហេតុផលទៅអ្នកទិញក្នុងការរក្សាទុកទំនិញ។[61]

បន្ថែមពីនេះទៅទៀត ភាគីទាំងពីរដែលមានកាតព្វកិច្ចក្នុងការចាត់វិធានការណ៍អាចរក្សាទុកទំនិញនៅក្នុងឃ្លាំងរបស់តតិយជន ចំណែកការចំណាយលើការរក្សាទុកទំនិញគឺជាបន្ទុករបស់ភាគីម្ខាងទៀតមិនត្រូវអោយចំណាយមានច្រើនហួសហេតុពេកឡើយ។[62] ភាគីដែលមានកាតព្វកិច្ចថែរក្សាទំនិញអាចលក់ទំនិញតាមមធ្យោបាយសមស្របណាមួយ ប្រសិនបើមានការពន្យារពេលមិនសមហេតុផលដោយភាគីម្ខាងទៀតក្នុងការទទួលយកទំនិញត្រលប់ទៅវិញ ឬការបង់ថ្លៃ ឬតម្លៃនៃការរក្សាទុកទំនិញ ប៉ុន្តែប្រសិនបើការជូនដំណឹងសមហេតុផលនៃការពន្យាពេលត្រូវផ្តល់ឱ្យភាគីដែលមកទទួលយកទំនិញ។ ប្រសិនបើទំនិញអាចនឹងខូចខាតយ៉ាងឆាប់រហ័ស ឬការរក្សាមានការចំណាយមិនសមហេតុផល ភាគីណាដែលត្រូវរក្សាទុកទំនិញត្រូវតែចាត់វិធានការសមហេតុផលដើម្បីលក់ ប៉ុន្តែភាគីដែលរក្សាទុកទំនិញមានបំណងចង់លក់ត្រូវជូនដំណឹងទៅភាគីម្ខាងទៀតនូវចេតនារបស់គាត់ក្នុងការលក់។ ភាគីដែលលក់ទំនិញមានសិទ្ធិរក្សាទុកប្រាក់ចំណូលនៃការលក់និងការចំណាយសមស្របនៃការរក្សាទុកទំនិញដែរបានលក់ទំនិញនោះ ភាគីដែលបានលក់ទំនិញដែរខ្លួនបានរក្សាទុកត្រូវគណនាតម្លៃដល់ភាគីម្ខាងទៀតឱ្យមានតុល្យភាព។[63]

### ខ. ការរួចផុតពីការទទួលខុសត្រូវ

ចំពោះភាគីដែលរំលោភបំពានកិច្ចសន្យា អាចរួចផុតពីការទទួលខុសត្រូវក្នុងករណីប្រធានសក្តិដែលបានកើតឡើងហើយមិនអាចគ្រប់គ្រងបាន។ ប្រសិនបើភាគីមួយបានបង្ហាញថា ការខកខានមិនអនុវត្តកាតព្វកិច្ចបណ្តាលមកពីឧបសគ្គដែលមិនអាចគ្រប់គ្រងបានដូចជា[64]៖ សង្គ្រាម រញ្ជួយដី ឬការហ៊ុំព័ទ្ធសេដ្ឋកិច្ច ភាគីនោះមិនត្រូវទទួលខុសត្រូវក្នុងការខកខានមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនទេ ។ ចំពោះប្រធានសិក្តត្រូវបានកំណត់នៅក្នុងកិច្ចសន្យាឲ្យបានច្បាស់លាស់

[61] យោងតាម មាត្រា៨៦ នៃអនុសញ្ញាCISG
[62] យោងតាម មាត្រា៨៧ នៃអនុសញ្ញាដដែល
[63] យោងតាម មាត្រា៨៨ នៃអនុសញ្ញាដដែល
[64] យោងតាម មាត្រា៧៩ នៃអនុសញ្ញាដដែល

ជៀសវាង ការទាមទារទទួលខុសត្រូវពីភាគីណាមួយ។ នៅក្នុងករណីប្រធានសក្តិ ភាគីរងគ្រោះមិនអាចប្តឹងទាមទារសំណងបានទេ ប៉ុន្តែអាចស្នើសុំរំលាយកិច្ចសន្យានោះបាន។

មួយវិញទៀត ប្រសិនបើការខកខាន ឬការខូចខាតបណ្តាលមកពីកំហុសរបស់តតិយជន ភាគីរងគ្រោះអាចទាមទារសំណងការខូចខាតពីតតិយជន ដោយសារតតិយជនជាអ្នកទទួលខុសត្រូវ ។ ការរួចផុតពីការទទួលខុសត្រូវតម្រូវឲ្យភាគីដែលមិនបានបំពេញកាតព្វកិច្ច ត្រូវតែជូនដំណឹងទៅឲ្យភាគីម្ខាងទៀតអំពីឧបសគ្គដែលបណ្តាលឲ្យខ្លួនពុំអាចអនុវត្តកាតព្វកិច្ចបាន។ ប្រសិនបើភាគីដែលមិនបានបំពេញកាតព្វកិច្ចបានដឹង ឬគួរតែដឹងថាភាគីម្ខាងទៀតមិនបានទទួលសេចក្តីជូនដំណឹងក្នុងរយៈពេលសមល្មមបន្ទាប់ពីគាត់បានជូនដំណឹងនោះ គាត់នឹងទទួលខុសត្រូវចំពោះការខូចខាតដែលកើតចេញពីការមិនផ្តល់ដំណឹង។

**កថាខណ្ឌទី៤ ការរំលាយកិច្ចសន្យា**

មុនពេលភាគីដោះស្រាយនូវជំណោះស្រាយចុងក្រោយ ដោយការរំលាយកិច្ចសន្យា ភាគីបានអនុវត្តនូវវិធីសាស្ត្រផ្សេងៗជាច្រើនដើម្បីជៀសវាងការរំលាយកិច្ចសន្យា។ ប៉ុន្តែប្រសិនបើការផ្តល់លក្ខខណ្ឌដោះស្រាយមានរួចជាស្រេច ហើយភាគីនៅតែមិនអនុវត្តនោះជម្រើសចុងក្រោយគឺរំលាយកិច្ចសន្យា។ អានុភាពនៃការរំលាយកិច្ចសន្យា គឺក្រោយពីការរំលាយ ភាគីទាំងសងខាងត្រូវបានរួចផុតពីកាតព្វកិច្ចរៀងៗខ្លួនដែរអនុលោមភាពតាមកិច្ចសន្យា ប៉ុន្តែចំពោះខចែងពីដំណោះស្រាយវិវាទនៅក្នុងកិច្ចសន្យានៅតែត្រូវយកមកអនុវត្តដដែល។

ភាគីដែលបានអនុវត្តកិច្ចសន្យាទាំងស្រុង ឬមួយផ្នែកអាចទាមទារសំណងពីភាគីម្ខាងទៀតនៅក្រោមកិច្ចសន្យាបាន។[65] ប្រសិនបើភាគីទាំងពីរបានកំណត់ឱ្យផ្តល់នូវសំណងត្រូវធ្វើឡើងតំណាលគ្នា ។[66] បន្ថែមពីនេះទៅទៀត អ្នកទិញបាត់សិទ្ធិក្នុងការរំលាយកិច្ចសន្យាក្នុងករណីដូចខាងក្រោមៈ

- ប្រសិនបើអ្នកលក់ពុំមានលទ្ធភាពក្នុងការរកទំនិញមកជំនួស ឬការសងទំនិញដែលខូចខាតស្ទើរតែទាំងស្រុងនោះ
- បើទំនិញទាំងនោះ ឬមួយផ្នែកត្រូវបានខូចខាត ដោយសារតែការត្រួតពិនិត្យរបស់អ្នកទិញ

[65] យោងតាមមាត្រា៨១ នៃអនុសញ្ញាCISG

[66] យោងតាមមាត្រា៨១ នៃអនុសញ្ញាដដែល

- បើទំនិញទាំងនោះ ឬមួយផ្នែកត្រូវបានលក់នៅក្នុងដំណើរការធម្មតានៃជំនួញ ឬបានប្រើប្រាស់ ឬបានផ្ទេរដោយអ្នកលក់នៅក្នុងដំណើរនៃការប្រើប្រាស់ធម្មតាមុនពេលដែលអ្នកទិញបានរកឃើញ ឬគួរតែបានរកឃើញថាមានកង្វះខាតលើអនុលោមភាពនៃទំនិញ។

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមរយៈការបកស្រាយ ព្រមទាំងមានអំណះអំណាងបញ្ជាក់ និងឯកសារយោងទៅលើប្រធានបទនេះ ពិតជាបានផ្តល់នូវចំណេះដឹង និងសារៈប្រយោជន៍ជាច្រើនទាក់ទងទៅនឹងអានុភាពនៃកិច្ចសន្យាលក់ទំនិញអន្តរជាតិ។ បន្ទាប់ពីបង្កើតកិច្ចសន្យា ភាគីមានកាតព្វកិច្ចអនុវត្តនូវសកម្មភាពរបស់ខ្លួនដើម្បីទទួលបានផលប្រយោជន៍ដែរគូរភាគីរំពឹងទុកពីកិច្ចសន្យារួមមាន៖

អ្នកលក់ត្រូវអនុវត្តនូវសកម្មភាពនៃការប្រគល់ទំនិញ និងការប្រគល់ឯកសារទៅតាមទីកន្លែង និងពេលវេលានៃកាលបរិច្ឆេទដែលបានកំណត់ក្នុងកិច្ចសន្យាទៅឲ្យអ្នកទិញ ។ ចំណុចសំខាន់មួយទៀតគឺអនុលោមភាពនៃទំនិញដែលអ្នកលក់ត្រូវប្រគល់ទំនិញទៅឲ្យអ្នកទិញ ស្របតាមស្តង់ដា គុណភាព បរិមាណ ការពិពណ៌នា និងការវេចខ្ចប់តាមគោលបំណងរបស់អ្នកទិញដែលបានចរចាជាមួយអ្នកលក់ពេលបង្កើតកិច្ចសន្យា។ ចំណែកអ្នកទិញត្រូវអនុវត្តនូវសកម្មភាពនៃការបង់ប្រាក់ និងការទទួលយកទំនិញនៅទីកន្លែង និងពេលវេលាដែលបានកំណត់តាមឆន្ទៈរបស់គូរភាគីក្នុងកិច្ចសន្យា។ ចំពោះការទទួលយកទំនិញ ភាគីអ្នកទិញត្រូវតែត្រួតពិនិត្យទំនិញ និងជូនដំណឹងពីវិការៈណាមួយដែរកើតឡើងពីការមិនអនុលោមតាមកិច្ចសន្យា ឬការបដិសេធពីការទទួលយកទំនិញដោយមូលហេតុណាមួយទៅឲ្យអ្នកលក់ ដើម្បីទទួលបានដំណោះស្រាយផ្សេងៗពីអ្នកលក់។

បន្ទាប់ពីភាគីអនុវត្តនូវកាតព្វកិច្ចរបស់ខ្លួន តែបែបជាបណ្តាលឲ្យមានហានិភ័យណាមួយកើតឡើងនាំឲ្យមានការទទួលខុសត្រូវ នោះភាគីដែលរំលោភបំពានកិច្ចសន្យានឹងទទួលខុសត្រូវ មិនថាជាតតិយជនដែលនាំឲ្យមានការខូចខាតនូវផលប្រយោជន៍របស់គូរភាគី ក៏ត្រូវទទួលខុសត្រូវដូចគ្នា។ ប៉ុន្តែមានករណីដែលគូរភាគីមិនទទួលខុសត្រូវ នោះគឺប្រធានសក្តិដែរកើតឡើងធ្វើឲ្យមានហានិភ័យ ហើយគូរភាគីមិនអាចដឹងទុកជាមុន និងមិនមែនជាការធ្វេសប្រហែស ព្រមទាំងមិនអាចគ្រប់គ្រងបាន។ បើទោះបីជាភាគីមិនទទួលខុសត្រូវក្នុងករណីប្រធានសក្តិ ប៉ុន្តែការមិនទទួលខុសត្រូវគឺនៅក្នុងកំឡុងនៃការខូចខាតដែលបណ្តាលមកពីប្រធានសក្តិប៉ុណ្ណោះ។ ចំណែកបន្ទាប់ពីប្រធានសក្តិកើតឡើង គូរភាគីណាមួយមិនបានចាត់វិធានការការពារ ឬទប់ទល់ហានិភ័យណាមួយដែរអាចដឹងថានឹងកើតមាន ត្រូវទទួលខុសត្រូវចំពោះហានិភ័យនោះ។

ភាគីអនុវត្តទៅតាមការព្រមព្រៀង ចំណែកការទទួលខុសត្រូវក៏បានកំណត់ក្នុងករណីមានការរំលោភបំពានកើតឡើង ដោយផ្តល់នូវដំណោះស្រាយទាំងភាគីអ្នកលក់ និងភាគីអ្នកទិញយកមកអនុវត្ត៖ ការទទួលខុសត្រូវដោយឡែកចំពោះការមិនអនុវត្តកាតព្វកិច្ចដោយអ្នកលក់ ត្រូវអនុវត្តនូវដំណោះស្រាយដែលបានកំណត់របស់អ្នកទិញ ។ អ្នកលក់មានសិទ្ធិនឹងទទួលបាននូវ

ដំណោះស្រាយមុនពេលអ្នកទិញរំលាយកិច្ចសន្យាដូចជា៖ ការប្រគល់ទំនិញជំនួសនូវទំនិញដែលមិនអនុលោមតាមកិច្ចសន្យា រយៈពេលបន្ថែមបន្ទាប់ពីរយៈពេលដែរបានកំណត់បានកន្លងហួសទៅ ការកាត់បន្ថយនូវតម្លៃជំនួសការបញ្ជូនទំនិញត្រឡប់មកវិញ។ ប៉ុន្តែក្នុងករណីអ្នកទិញជ្រើសរើសយកការកាត់បន្ថយតម្លៃ នោះអ្នកលក់មិនចាំបាច់ធ្វើការប្រគល់ទំនិញជំនួស។ ចំណែកអ្នកទិញក៏មិនអាចរំលាយកិច្ចសន្យាបានដែរ។

ការទទួលខុសត្រូវដោយឡែកចំពោះការមិនអនុវត្តកាតព្វកិច្ចដោយអ្នកទិញ ត្រូវអនុវត្តនូវដំណោះស្រាយដែលបានកំណត់របស់អ្នកលក់។ អ្នកទិញមានសិទ្ធិទទួលបាននូវរយៈពេលបន្ថែមដើម្បីអនុវត្តកាតព្វកិច្ចរបស់ខ្លួន ចំណែកអ្នកលក់ក៏មានសិទ្ធិតម្រូវឲ្យអ្នកទិញអនុវត្តនូវកាតព្វកិច្ចទទួលយកទំនិញ និងទទូទាត់តម្លៃក្នុងរយៈពេលបន្ថែមដែលខ្លួនបានផ្តល់ឲ្យ មុនពេលអ្នកលក់រំលាយកិច្ចសន្យា និងទាមទារសំណងការខូចខាត។ ចំណែកចំណុចរួមដែលគ្រប់គ្រងនូវការទទួលខុសត្រូវរបស់អ្នកលក់ និងអ្នកទិញមានដូចជា៖ ការបំពានកាលាទិករណ៍ កិច្ចសន្យាប្រគល់ទំនិញជាបន្តបន្ទាប់ ការខូចខាត ការបង់ការប្រាក់ ការរក្សាទុកទំនិញ និងការរួចផុតពីការទទួលខុសត្រូវ និងការរំលាយកិច្ចសន្យារួចរាល់។

សរុបជារួមមកភាគីតម្រូវឲ្យអនុវត្តនូវកាតព្វកិច្ចដែលបានព្រមព្រៀងគ្នាក្នុងកិច្ចសន្យាជៀសវាងការរំលោភបំពាននានា។ ប៉ុន្តែប្រសិនបើមានការរំលោភបំពាន ភាគីត្រូវអនុវត្តនូវដំណោះស្រាយដែរបានកំណត់ក្នុងកិច្ចសន្យា និងតាមរយៈតុលាការ ឬមជ្ឈត្តករដែលគូរភាគីបានជ្រើសរើស។

បន្ទាប់ពីបានយល់ដឹងបន្ថែមនូវអានុភាពនៃកិច្ចសន្យាលក់ទំនិញអន្តរជាតិ វាជាជំនួយបន្ថែមដល់ប្រទេសកម្ពុជាដែលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក និងជាប្រទេសដែលប្រកាន់ភ្ជាប់នូវរបបទីផ្សារសេរី និងសេដ្ឋកិច្ចបើកចំហរ។ ការបើកឲ្យទីផ្សារលក់ទំនិញអន្តរជាតិកើនឡើងយ៉ាងទូលំទូលាយ ហើយទាក់ទាញវិនិយោគិនក្រៅប្រទេសមកធ្វើការបណ្តាក់ទុននៅប្រទេសកម្ពុជាឲ្យកាន់តែច្រើនឡើង។ ម្យ៉ាងទៀតដោយសារការអភិវឌ្ឍន៍លើវិស័យសេដ្ឋកិច្ចឲ្យកាន់តែរីកចម្រើនជាងមុនទៅទៀត ប្រទេសកម្ពុជានឹងអាចចូលជាសមាជិកក្នុងអង្គការសហប្រជាជាតិស្តីកិច្ចសន្យាលក់ទំនិញអន្តរជាតិក្នុងពេលខាងមុខ។

ꕥꕥꕥ📖ꕥꕥ

# ឯកសារយោង


១. អនុសញ្ញា

- អនុសញ្ញាអង្គការសហប្រជាជាតិស្តីកិច្ចសន្យាលក់ទំនិញអន្តរជាតិ (អនុសញ្ញាCISG) ឆ្នាំ១៩៨០។

២.សៀវភៅ

- គណៈកម្មការអង្គការសហប្រជាជាតិលើច្បាប់ពាណិជ្ជកម្មអន្តរជាតិ (UNCITRAL) *"Digest of Case Law on the United Nations Convention on Contracts for the International Sale of Good"* 2016 Edition អត្ថបទសង្ខេបនៃរឿងក្តីក្នុងអនុសញ្ញាអង្គការសហប្រជាជាតិនៃកិច្ចសន្យាលក់ទំនិញអន្តរជាតិឆ្នាំ២០១៦។
- បណ្ឌិតសាស្ត្រាចារ្យ Ingeborg Schwenzer និង Christiana Fountoulakis *"International Sales Law"* បោះពុម្ពលើកទី១ នៅទីក្រុងញ៉ូយក ដោយRouledge-Cavendish ក្នុងឆ្នាំ២០០៧។
- បណ្ឌិតសាស្ត្រាចារ្យ Ingeborg Schwenzer និង Christiana Fountoulakis និង Mariel Dimsey *"International Sales Law: A Guide to CISG"* បោះពុម្ពលើកទី២ ក្នុងឆ្នាំ២០១២ ។

៣. វាចនានុក្រម និង សៀវភៅវាក្យសព្ទគតិយុត្ត

- វចនានុក្រមអេឡិចត្រូនិចខ្មែររបស់សម្តេចសង្ឃ ជួន ណាត ឆ្នាំ២០១១ ។
- សមាគមស្រាវជ្រាវ និងផ្សព្វផ្សាយច្បាប់ខ្មែរ *"វចនានុក្រមច្បាប់តាមបទដ្ឋានគតិយុត្តខ្មែរ"* បោះពុម្ពលើកទី២ នៅរាជធានីភ្នំពេញដោយលោក អ៊ី ប៊ូរ៉ា សុភាវត្តី ឆ្នាំ២០១៦ ។
- សាស្ត្រាចារ្យ ហាប់ ផល្លី *"Legal Terminology Gordon W. Brown"* បោះពុម្ពលើកទី៣ ឆ្នាំ២០១៧ ។
- លោកបណ្ឌិត ឈាង វណ្ណារិទ្ធ និងសាស្ត្រាចារ្យច្បាប់ លោក អ៊ិន ហ៊ឹង *"វចនានុក្រមអង់គ្លេស-ខ្មែរពាក្យច្បាប់"* បោះពុម្ពលើកទី១ បណ្ណាគារ នគរធំ ឆ្នាំ២០១៣។

៤. គេហទំព័រ

- http://www.uncitral.org/uncitral/en/uncitral_texts/sale_goods/1980CISG.html ពីគ្រោះនៅថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០១៨។
- https://www.cisg.law.pace.edu/cisg/text/treaty.html ពីគ្រោះនៅថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៨។
- http://tarlton.law.utexas.edu/CISG ពីគ្រោះនៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៨។
- https://www.lawteacher.net/free-law-essays/commercial-law/rights-and-obligations-law-essays.php ពីគ្រោះនៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ ២០១៨ ។

## រាយនាមឯកសារនៅក្នុងឧបសម្ព័ន្ធ

- **ឧបសម្ព័ន្ធទី១៖** អនុសញ្ញាអង្គការសហប្រជាជាតិស្តីកិច្ចសន្យាលក់ទំនិញអន្តរជាតិ ដែលត្រូវបានអនុម័តនៅថ្ងៃទី១១ ខែ មេសា ឆ្នាំ១៩៨០ នៅទីក្រុងវីយែន ប្រទេសអូទ្រីស និងចូលជាធរមាននៅថ្ងៃទី០១ ខែមករា ឆ្នាំ ១៩៨៨ ។
- **ឧបសម្ព័ន្ធទី២៖** បញ្ជីរាយនាមប្រទេសហត្ថលេខីរបស់អនុសញ្ញាអង្គការសហប្រជាជាតិស្តីកិច្ចសន្យាលក់ទំនិញអន្តរជាតិ ដោយគិតពីឆ្នាំ១៩៨០ រហូតមកដល់ឆ្នាំ២០១៨។
- **ឧបសម្ព័ន្ធទី៣៖** ដកស្រង់សេចក្តីពន្យល់នៃមាត្រាដែលពាក់ព័ន្ធក្នុង អត្ថបទសង្ខេបនៃរឿងក្តីនៃអនុសញ្ញាអង្គការសហប្រជាតិស្តីពីកិច្ចសន្យាលក់ទំនិញអន្តរជាតិ នៅឆ្នាំ ២០១៦ (Digest of Case Law on the United Nations Convention on Contracts for the International Sale of Goods 2016 Edition) ។
- **ឧបសម្ព័ន្ធទី៤៖** គំរូនៃកិច្ចសន្យាលក់ទំនិញអន្តរជាតិ។

# United Nations Convention on Contracts for the International Sale of Goods



UNITED NATIONS

*Further information may be obtained from:*

UNCITRAL secretariat, Vienna International Centre,
P.O. Box 500, 1400 Vienna, Austria

Telephone: (+43-1) 26060-4060 Telefax: (+43-1) 26060-5813
Internet: www.uncitral.org E-mail: uncitral@uncitral.org

UNITED NATIONS COMMISSION ON INTERNATIONAL TRADE LAW

# United Nations Convention on Contracts for the International Sale of Goods

UNITED NATIONS
New York, 2010

**NOTE**

Symbols of United Nations documents are composed of capital letters combined with figures. Mention of such a symbol indicates a reference to a United Nations document.

UNITED NATIONS PUBLICATION
Sales No. E.10.V.14
ISBN 978-92-1-133699-3

© United Nations, November 2010. All rights reserved.

The designations employed and the presentation of material in this publication do not imply the expression of any opinion whatsoever on the part of the Secretariat of the United Nations concerning the legal status of any country, territory, city or area, or of its authorities, or concerning the delimitation of its frontiers or boundaries.

Publishing production: English, Publishing and Library Section, United Nations Office at Vienna.

This publication has not been formally edited.

# Contents


| | | Page |
|---|---|---|
| I. | **United Nations Convention on Contracts for the International Sale of Goods** | 1 |
| | PREAMBLE | 1 |
| | **Part I. Sphere of application and general provisions** | 1 |
| | CHAPTER I. Sphere of application | 1 |
| | Article 1 | 1 |
| | Article 2 | 2 |
| | Article 3 | 2 |
| | Article 4 | 2 |
| | Article 5 | 3 |
| | Article 6 | 3 |
| | CHAPTER II. General provisions | 3 |
| | Article 7 | 3 |
| | Article 8 | 3 |
| | Article 9 | 4 |
| | Article 10 | 4 |
| | Article 11 | 4 |
| | Article 12 | 4 |
| | Article 13 | 5 |
| | **Part II. Formation of the contract** | 5 |
| | Article 14 | 5 |
| | Article 15 | 5 |
| | Article 16 | 5 |
| | Article 17 | 6 |
| | Article 18 | 6 |
| | Article 19 | 6 |
| | Article 20 | 7 |
| | Article 21 | 7 |
| | Article 22 | 7 |
| | Article 23 | 7 |
| | Article 24 | 7 |

*Page*

**Part III. Sale of goods** ... 8

CHAPTER I. General provisions ... 8
Article 25 ... 8
Article 26 ... 8
Article 27 ... 8
Article 28 ... 8
Article 29 ... 8

CHAPTER II. Obligations of the seller ... 9
Article 30 ... 9

Section I. Delivery of the goods and handing over of documents ... 9
Article 31 ... 9
Article 32 ... 9
Article 33 ... 10
Article 34 ... 10

Section II. Conformity of the goods and third-party claims ... 10
Article 35 ... 10
Article 36 ... 11
Article 37 ... 11
Article 38 ... 11
Article 39 ... 12
Article 40 ... 12
Article 41 ... 12
Article 42 ... 12
Article 43 ... 13
Article 44 ... 13

Section III. Remedies for breach of contract by the seller ... 13
Article 45 ... 13
Article 46 ... 14
Article 47 ... 14
Article 48 ... 14
Article 49 ... 15
Article 50 ... 16
Article 51 ... 16
Article 52 ... 16

CHAPTER III. Obligations of the buyer ... 16
Article 53 ... 16

*Page*

Section I. Payment of the price ........ 17
Article 54 ........ 17
Article 55 ........ 17
Article 56 ........ 17
Article 57 ........ 17
Article 58 ........ 17
Article 59 ........ 18

Section II. Taking delivery ........ 18
Article 60 ........ 18

Section III. Remedies for breach of contract by the buyer ........ 18
Article 61 ........ 18
Article 62 ........ 19
Article 63 ........ 19
Article 64 ........ 19
Article 65 ........ 20

CHAPTER IV. Passing of risk ........ 20
Article 66 ........ 20
Article 67 ........ 20
Article 68 ........ 21
Article 69 ........ 21
Article 70 ........ 21

CHAPTER V. Provisions common to the obligations of the seller and of the buyer ........ 21

Section I. Anticipatory breach and instalment contracts ........ 21
Article 71 ........ 21
Article 72 ........ 22
Article 73 ........ 22

Section II. Damages ........ 23
Article 74 ........ 23
Article 75 ........ 23
Article 76 ........ 23
Article 77 ........ 24

Section III. Interest ........ 24
Article 78 ........ 24

Section IV. Exemptions ........ 24
Article 79 ........ 24
Article 80 ........ 25

*Page*

Section V. Effects of avoidance .......... 25
Article 81 .......... 25
Article 82 .......... 25
Article 83 .......... 26
Article 84 .......... 26

Section VI. Preservation of the goods .......... 26
Article 85 .......... 26
Article 86 .......... 26
Article 87 .......... 27
Article 88 .......... 27

**Part IV. Final provisions** .......... 27

Article 89 .......... 27
Article 90 .......... 27
Article 91 .......... 28
Article 92 .......... 28
Article 93 .......... 28
Article 94 .......... 29
Article 95 .......... 29
Article 96 .......... 30
Article 97 .......... 30
Article 98 .......... 30
Article 99 .......... 31
Article 100 .......... 32
Article 101 .......... 32

**II. Explanatory note by the UNCITRAL Secretariat on the United Nations Convention on Contracts for the International Sale of Goods** .......... 33

Introduction .......... 33

**Part One. Scope of application and general provisions** .......... 34

A. Scope of application .......... 34
B. Party autonomy .......... 35
C. Interpretation of the Convention .......... 36
D. Interpretation of the contract; usages .......... 36
E. Form of the contract .......... 36

**Part Two. Formation of the contract** .......... 37

*Page*

**Part Three. Sale of goods** ........ 38

A. Obligations of the seller ........ 38
B. Obligations of the buyer ........ 38
C. Remedies for breach of contract ........ 39
D. Passing of risk ........ 39
E. Suspension of performance and anticipatory breach ........ 40
F. Exemption from liability to pay damages ........ 40
G. Preservation of the goods ........ 40

**Part Four. Final clauses** ........ 41

Complementary texts ........ 41

# 1. United Nations Convention on Contracts for the International Sale of Goods

## PREAMBLE

*The States Parties to this Convention*,

*Bearing in mind* the broad objectives in the resolutions adopted by the sixth special session of the General Assembly of the United Nations on the establishment of a New International Economic Order,

*Considering* that the development of international trade on the basis of equality and mutual benefit is an important element in promoting friendly relations among States,

*Being of the opinion* that the adoption of uniform rules which govern contracts for the international sale of goods and take into account the different social, economic and legal systems would contribute to the removal of legal barriers in international trade and promote the development of international trade,

*Have agreed* as follows:

## Part I. Sphere of application and general provisions

### CHAPTER I. SPHERE OF APPLICATION

#### *Article 1*

(1) This Convention applies to contracts of sale of goods between parties whose places of business are in different States:

*(a)* when the States are Contracting States; or

*(b)* when the rules of private international law lead to the application of the law of a Contracting State.

(2) The fact that the parties have their places of business in different States is to be disregarded whenever this fact does not appear either from the contract or from any dealings between, or from information disclosed by, the parties at any time before or at the conclusion of the contract.

(3) Neither the nationality of the parties nor the civil or commercial character of the parties or of the contract is to be taken into consideration in determining the application of this Convention.

### *Article 2*

This Convention does not apply to sales:

*(a)* of goods bought for personal, family or household use, unless the seller, at any time before or at the conclusion of the contract, neither knew nor ought to have known that the goods were bought for any such use;

*(b)* by auction;

*(c)* on execution or otherwise by authority of law;

*(d)* of stocks, shares, investment securities, negotiable instruments or money;

*(e)* of ships, vessels, hovercraft or aircraft;

*(f)* of electricity.

### *Article 3*

(1) Contracts for the supply of goods to be manufactured or produced are to be considered sales unless the party who orders the goods undertakes to supply a substantial part of the materials necessary for such manufacture or production.

(2) This Convention does not apply to contracts in which the preponderant part of the obligations of the party who furnishes the goods consists in the supply of labour or other services.

### *Article 4*

This Convention governs only the formation of the contract of sale and the rights and obligations of the seller and the buyer arising from such a contract. In particular, except as otherwise expressly provided in this Convention, it is not concerned with:

*(a)* the validity of the contract or of any of its provisions or of any usage;

*(b)* the effect which the contract may have on the property in the goods sold.

### *Article 5*

This Convention does not apply to the liability of the seller for death or personal injury caused by the goods to any person.

### *Article 6*

The parties may exclude the application of this Convention or, subject to article 12, derogate from or vary the effect of any of its provisions.

## CHAPTER II. GENERAL PROVISIONS

### *Article 7*

